ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Aug-2015, 14:14
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៣០៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ស្រ៊ា រតនៈ

លោក ដេល លីសាក់*(Mr. Dale Lysak)*

លោក ចូសេហ្វ អេនឌ្រូ ប៊ យលី
*(Mr. Joseph Andrew BOYLE)*

លោក ត្រាវីស ហ្វារ*(Mr.* Mr. Travis FARR)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក កាន ផុល (2-TCW-881 ) | ខ្មែរ |
| លោក ឡុត សួយ (2-TCW-889 ) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កាន ថុល** (2-TCW-881)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៣
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ១១
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ២៣
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៣១

**ការសួរសំណួរទៅសាក្សី៖ លោក ឡុត សួយ** (2-TCW-889)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៣៦
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................ទំព័រ ៣៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី កាន ថុល បន្តបញ្ចប់ និងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-889។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែសហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺ លោក កាន ថុល លោកមានវត្តមានរួចហើយនៅបន្ទប់សវនាការនេះ។ នៅថ្ងៃនេះ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-889។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិពន្ធ ឬញាតិលោហិតជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែក នៅព្រឹកនេះមុនពេលផ្តល់សក្ខីកម្ម។ សាក្សីមានមេធាវីប្រឹក្សា គឺលោកមេធាវី ម៉ម រិទ្ធា។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខ-ភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥។

[០៩:០២:២៥]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ។ ផ្តល់អនុសាសន៍ថាសូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះលោកចៅក្រមមានសំណួរចំពោះសាក្សីរូបនេះទេ?

សូមអញ្ជើញលោក ហ្វង់ម៉ាក!

**ចៅក្រម ហ្វង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្វង់ម៉ាក ឡាវែន៖**

**ស៖** ជម្រាបសួរលោក កាន ថុល ខ្ញុំជាចៅក្រម ឡាវែន ខ្ញុំមានសំណួរមួយចំនួនតូច សួរលោក

ដើម្បីបំភ្លឺអំពីចម្លើយរបស់លោក ដែលលោកបានឆ្លើយកាលពីម្សិលមិញ។ កាលពីម្សិលមិញនៅពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជជាតិ លោកបានឆ្លើយថា លោកធ្វើការកាន់តួនាទីមួយនៅក្នុងកងចល័ត។ លោកក៏បានបញ្ជាក់ថែមទៀតថា លោកមិនមានសេចក្តីក្លាហានក្នុងការបដិសេធអ្វីនោះទេ ពីព្រោះលោកមានការភ័យខ្លាច លោកខ្លាចអំពីច្បាប់ ហើយនិងរបៀបដែលគេប្រព្រឹត្តមកលើលោក ហើយលោកបានបញ្ចប់ចម្លើយរបស់លោកនៅពេលនោះ ដោយលោកបានបញ្ជាក់ថា លោកខ្លាចគេនាំលោកយកទៅសម្លាប់ចោល។ សំណួរដំបូងរបស់ខ្ញុំ តើខ្ញុំច្បាស់អំពីចម្លើយរបស់លោកទេថា អ្វីដែលខ្ញុំរៀបរាប់អម្បាញ់មិញនេះ គឺពិតជាដូចនឹងអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញហ្នឹងមែនទេ?

**លោក កាន ថុល៖**

**ឆ៖** បាទ ពិតមែន។

**ស៖** តើលោកអាចពន្យល់ជូនតុលាការបានទេថាហេតុអ្វីបានជាលោកនិយាយថាលោកខ្លាចគេនាំយកទៅសម្លាប់ចោលនោះ?

**ឆ៖** បាទ ពេលនោះពេលដែលថ្នាក់លើដាក់ទិសឲ្យខ្ញុំធ្វើអ្វី ដូចជាដឹកនាំកងកម្លាំងធ្វើការងារក្នុងមួយថ្ងៃ ៣ម៉ែត្រគូប គឺខ្ញុំមិនហ៊ានប្រឆាំងទេ។

[០៩:០៦:២៨]

**ស៖** ខ្ញុំយល់អំពីចំណុចនេះ ក៏ប៉ុន្តែលោកបាននិយាយថា លោកខ្លាចគេនាំលោកយកទៅសម្លាប់។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើលោកខ្លួនឯងហ្នឹងមានបានឃើញផ្ទាល់ភ្នែក ឬក៏ធ្លាប់ឮថាមានគេនាំមនុស្សណាមួយយកចេញទៅទេ? លោកមានឃើញផ្ទាល់ភ្នែកថាមនុស្សបាត់ខ្លួនទេ?

**ឆ៖** បាទ ពុំធ្លាប់ឃើញទេ។

**ស៖** អ៊ីចឹង បើលោកមិនដែលឃើញផង ហេតុអីបានជាលោកខ្លាចគេនាំលោកយកចេញទៅ?

**ឆ៖** បាទ ព្រោះឮគេនិយាយថា "បើអ្នកណាហ៊ានប្រឆាំង អ្នកនោះនឹងត្រូវបាត់ខ្លួន"។

**ស៖** លោកឮពាក្យសម្តីហ្នឹងពីអ្នកណាដែរ?

**ឆ៖** បាទ ពួកគ្នាតាមកម្មាភិបាលខាងលើៗ។

**ស៖** អ៊ីចឹងមានន័យថា មានការនិយាយតៗគ្នាមកថានឹងមានការនាំចេញទៅអ៊ីចឹង ហើយមួយៗចេះតែនាំគ្នាខ្លាចទាំងអស់គ្នាអ៊ីចឹងទៅ។ តើមែនទេ?

**ឆ៖** បាទ ពិតណាស់។

**ស៖** ហើយអ្នកដែលខ្លាចគេនាំយកចេញទៅហ្នឹងមានប្រាប់លោកថា មានមនុស្សបាត់ខ្លួនទេ?

**ឆ៖** បាទ គឺមាន។

**ស៖** អ៊ីចឹង អ្នកដដែលហ្នឹងទេ ដែលអ្នកប្រាប់លោកថា មានមនុស្សត្រូវបានគេសម្លាប់នោះ?

**ឆ៖** បាទ គឺអ្នកផ្សេងទៀតក៏មានដែរ។

**ស៖** លោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ? ខ្ញុំមិនច្បាស់ទេ អ្នកផ្សេងទៀតហ្នឹងអ្នកណាខ្លះ? ហើយគាត់បាននិយាយអ្វីខ្លះ?

**ឆ៖** បាទ អ្នកផ្សេងនោះគឺអ្នកដែលនៅរួមរស់ក្នុងកងធំជាមួយគ្នា។

[០៩:១០:០០]

**ស៖** កងធំហ្នឹងជាអ្វីដែរ? ជាកងរបស់តំបន់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ កងធំនោះ គឺគេក្ដាប់ចំនួន ១00នាក់ បីកងតូច។

**ស៖** ខ្ញុំចង់អានចម្លើយរបស់លោកដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំនឹងសួរលោកដើម្បីរំឭកការចងចាំរបស់លោក។ គឺឯកសារលេខ E3/7803, ERN ជាភាសាបារាំងគឺ 00486083, ជាភាសាអង់គ្លេស 00277821, ជាភាសាខ្មែរគឺ 00267755។ លោកបានឆ្លើយថា៖ "ថ្ងៃមួយខ្ញុំឃើញគេចាប់ខ្លួនមនុស្ស គេចង បន្ទាប់មកបណ្ដើរទៅជិតកន្លែងដែលខ្ញុំសម្រាកនៅពេលយប់ ក៏ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះគេទេ។ អ្នកដែលគេបណ្ដើរទៅនោះគឺ -- អ្នកបណ្ដើរនោះ គឺពាក់ខោអាវខ្មៅហើយមានកាន់កាំភ្លើង។ ដូច្នេះខ្ញុំគិតថាពួកនោះគឺជាទាហាន។ នៅក្នុងក្រុមរបស់ខ្ញុំមានអ្នកឃ្លាំមើលពេលយប់ខ្លះ គឺពួកគេមកដេក១នៅក្បែរ១យើង ដើម្បីលួចស្ដាប់យើង។ នៅក្នុងក្រុមរបស់ខ្ញុំមានមនុស្សម្នាក់បាត់ខ្លួន ខ្ញុំដើររកទៅដល់ផ្ទះគាត់ ហើយរកមិនឃើញគាត់ទេ។ អ្នកដែលបាត់ខ្លួននោះឈ្មោះ គិន គឺគាត់មកពីភ្នំពេញ គឺជាអ្នក ១៧ មេសា គឺឈ្មោះគាត់ ឃឿន ហើយគាត់ -- ឃឿន ហ្នឹងគាត់បាត់ខ្លួនមករហូតដល់ពេលនេះរហូត។ តើលោកចង់ចាំអំពីចម្លើយនេះរបស់លោកនេះទេ?

**ឆ៖** បាទ គឺពិតមែន ជាម្លើយរបស់ខ្ញុំ។

**ស៖** តើអ្នកណាជាអ្នកដែលមកលួចស្ដាប់ មកនៅជិត១ពេលយប់នុ៎ង? ជាពួកឈ្លប ជាគិញ ឬក៏ជាអ្នកណា? អ៊ីចឹងនៅក្នុងរបស់លោកហ្នឹងមានគិញទេ ជាអ្នកដែលមានភារកិច្ចរាយការណ៍ថា ឬក៏ ប្រាប់ថាអ្នកណាជាខ្មាំងហ្នឹង?

**ឆ៖** បាទ ពួកនោះខ្ញុំមិនស្គាល់គេថាជាស្អីទេ។

**ស៖** លោកមិនស្គាល់ពួកគេទេ ក៏ប៉ុន្តែលោកដឹងទេថា នៅក្នុងកងរបស់លោកហ្នឹង មានអ្នកណាជាអ្នកទទួលបន្ទុកឃ្លាំមើល ឬក៏តាមដានទេ?

**ឆ៖** បាទ នៅក្នុងកងនោះពុំមានអ្នកណាឃ្លាំមើលទេ។ ពេលឃើញគេមកដេកនៅក្បែររោង នៅតាមបណ្តោយរោងនោះ អ្នកខ្លះមិនបានទាំងសួរទៀត។

**ស៖** អ៊ីចឹងអ្នកណាដែលជាអ្នកដែលមកលួចស្តាប់នៅពេលយប់នុ៎ង? អ្នកណាដែលជាអ្នកមកឃ្លាំមើល ឬក៏មកស្តាប់ លបស្តាប់នុ៎ង?

**ប្រធានអង្គជំនុំ៖**

សុំលោកសាក្សីឆ្លើយម្តងទៀត រង់ចាំមីក្រូហ្វូនប្រតិបត្តិការសិន។

[០៩:១៥:០០]

**លោក កាន ផុល៖**

**ឆ៖** បាទ ខ្ញុំមិនបានស្គាល់គេទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើលោកអាចជម្រាបបានទេថា អ្នកណាជាអ្នកតែងតាំងលោកឲ្យកាន់ជាអនុប្រធានក្រុមរបស់លោកនៅក្នុងក្រុមកងចល័តនោះ? អ្នកណាជាអ្នកតែងតាំងលោក?

**ឆ៖** បាទ គឺប្រធានវរៈ។

**ស៖** ប្រធានវរៈហ្នឹងគាត់ឈ្មោះអ្វីដែរ?

**ឆ៖** បាទ ឈ្មោះ រុន។

**ស៖** តើលោកធ្លាប់ចូលរួមវគ្គរៀនសូត្រនយោបាយទេ?

**ឆ៖** បាទ មិនដែលទេ។

**ស៖** តើគេមានប្រាប់លោកទេថា បក្សកុម្មុយនីស្តកម្ពុជាមានខ្មាំង? ហើយអាចប្រាប់ទេអ្នកណាខ្លះជាខ្មាំងនោះ?

**ឆ៖** បាទ មិនដឹង។

**ស៖** តើលោកមានកត់សម្គាល់ឃើញថា អ្នក១៧មេសាត្រូវបានគេប្រព្រឹត្តផ្សេងខុសពីអ្នកដទៃទៀត? លោកអម្បាញ់មិញនេះលោកនិយាយថា មានអ្នក១៧មេសាហ្នឹងបាត់ខ្លួន។ អ៊ីចឹងលោកធ្លាប់ស្តាប់ឮ ឬក៏ឃើញដោយផ្ទាល់ភ្នែកអំពីការប្រព្រឹត្តដោយឡែកចំពោះអ្នក១៧មេសា ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំក៏អ្នក១៧មេសាដែរ។

**ស៖** ប្រហែលជាមានបញ្ហា។ យើងយល់អត់គ្នា -- ស្តាប់អត់បាន។ អ្នក១៧មេសា គឺជាអ្នកដែលត្រូវបានគេជម្លៀសចេញពីទីក្រុង ក៏ប៉ុន្តែលោកបើខ្ញុំយល់មិនច្រឡំទេ គឺលោកកើតនៅត្រពាំងថ្មលោករស់នៅទីនោះរហូត លោកមិនត្រូវបានធ្លាប់គេជម្លៀសទេ។ អ៊ីចឹងនៅក្នុងសម័យនោះ លោកគឺត្រូវបានគេចាត់ទុកថាជាអ្នកមូលដ្ឋានទេ ឬក៏អាចហៅថាជាអ្នកចាស់។ ខ្ញុំសួរអម្បាញ់មិញនេះ ខ្ញុំសួរអំពីអ្នក១៧មេសា ឬក៏ប្រជាជនថ្មី។ អ៊ីចឹងខ្ញុំចង់ដឹងថាតើអ្នក១៧មេសា ដែលគេជម្លៀសពីទីក្រុងមកនេះមានទទួលរងនូវការប្រព្រឹត្តដោយឡែកផ្សេងពីប្រជាជនដទៃទៀតទេ?

**ឆ៖** បាទ ហ្នឹងគឺខ្ញុំស្តាប់បាន។ ខ្ញុំនៅតំបន់ខ្ញុំ គេហៅថាអ្នកមូលដ្ឋានចាស់ ប៉ុន្តែសូមបញ្ជាក់ថាខ្ញុំនេះនៅតំបន់ខ្ញុំនេះ ពួកខ្មែរក្រហមមិនបានរំដោះតំបន់ខ្ញុំបានទេ គឺខ្ញុំនៅរហូតដល់ថ្ងៃ១៧ មេសា ដែរ។

[០៩:១៩:១៩]

**ស៖** បាទ ខ្ញុំយល់ថា ការរំដោះប្រទេសគឺនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥។ អ៊ីចឹងខ្ញុំចង់ដឹងថា តើមានការប្រព្រឹត្តខុសគ្នាទេរវាងប្រជាជនចាស់និងប្រជាជនថ្មី? គឺមានអ្នកថ្មីៗហ្នឹង គឺអ្នកជម្លៀសពីភ្នំពេញពីបាត់ដំបង ឬពីក្រុងផ្សេងទៀត។ ដូច្នេះតើគេមានប្រព្រឹត្តអ្វីដោយឡែក ឬក៏មានការធ្វើបាបអីទៅលើអ្នក១៧មេសាហ្នឹងទេ? ឧទាហរណ៍ដូចជា អតីតអ្នករដ្ឋការ ឬអតីតទាហានរបស់លន់ នល់ នោះមានគេ -- គេមានស្វែងរកចាប់ខ្លួនទេ?

**ឆ៖** បាទ គឺមាន។

**ស៖** នៅពេលដែលគេរកឃើញថា អ្នកណាម្នាក់ជាអតីតយោធានៃរបប លន់ នល់ នោះ តើគេធ្វើយ៉ាងម៉េចចំពោះអ្នកហ្នឹង?

**ឆ៖** បាទ បើគេរកឃើញថា អ្នកនោះបានមានពាក់ស័ក្តិនៅសម័យលន់នល់ គឺគេនឹងហៅយកទៅរៀនសូត្រ។

**ស៖** នៅពេលដែលគេកោះហៅអ្នកណាម្នាក់ឲ្យទៅប្រជុំរៀនសូត្រនោះ តើមានន័យថាម៉េច? គេកោះឲ្យទៅចូលរួមប្រជុំហ្នឹង ពេលដែលប្រជុំហើយហ្នឹងមានត្រឡប់មកធ្វើការនៅការដ្ឋានវិញទេ?

**ឆ៖** បាទ នៅកន្លែងខ្ញុំគឺអត់មានទេ។

**ស៖** នៅក្នុងកងរបស់លោក មានអ្នកណាជាជនជាតិវៀតណាមទេ?

**ឆ៖** បាទ គឺគ្មានទេ។

**ស៖** តើលោកធ្លាប់ឮថាមានគោលនយោបាយមួយដែលសំដៅរើសអើង ឬក៏ប្រព្រឹត្តអ្វីមួយទៅលើជនជាតិវៀតណាម ហើយមានការចាប់ខ្លួនជនជាតិវៀតណាមអីទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំមានឮដែរ។

[០៩:២២:៣០]

**ស៖** ខ្ញុំអត់យល់ លោកឆ្លើយថាលោកស្តាប់ឮមែនទេ អម្បាញ់មិញនេះ? ហើយបើសិនជាលោកឮមែននោះ លោកឮគេនិយាយអ្វីខ្លះ?

**ឆ៖** បាទ ឮគេនិយាយថា ឲ្យតែជនជាតិវៀតណាម គឺគេនឹងយកទៅសម្លាប់ចោល។

**ស៖** អ្នកណាជាអ្នកនិយាយហ្នឹង? ថ្នាក់លើរបស់លោក ឬក៏អ្នកណាដែលជាអ្នកនិយាយប្រាប់លោកថា ឲ្យតែជនជាតិវៀតណាម គេយកទៅសម្លាប់ចោលនោះ?

**ឆ៖** បាទ គឺគេនិយាយទូទៅ ទាំងកងចល័ត អ្នកណាក៏ដឹងដែរ។

**ស៖** ដូច្នេះ មានន័យថា អ្នកគ្រប់គ្នាហ្នឹង ឬក៏បានស្តាប់ឮថា ប្រសិនបើគេរកឃើញថា អ្នកណាជាជនជាតិវៀតណាមនោះ គេចាប់ខ្លួន ហើយនិងសម្លាប់ចោល។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីបញ្ហាវិន័យ។ តើលោកធ្លាប់ស្តាប់ឮ ថាមាន "កងករណី" គឺចង់សំដៅទៅលើអ្នកដែលមានបញ្ហាវិន័យ គាត់មិនធ្វើការឲ្យបានគ្រប់គ្រាន់ ហើយមិនគោរពវិន័យអីតើមានទេ មានគេបង្កើតជាកងករណីអ៊ីចឹងទេ?

**ឆ៖** បាទ គឺមាន។

**ស៖** តើអ្នកដែលធ្វើការនៅក្នុងកងករណីនេះ ទទួលរងនូវការប្រព្រឹត្តធ្ងន់ធ្ងរ ឬក៏ធ្វើការលំបាកជាងអ្នកផ្សេងទៀតទេ?

**ឆ៖** បាទ អ្នកដែលជាប់កងករណី គេឲ្យធ្វើការនៅពេលថ្ងៃពេញមួយថ្ងៃ ព្រោះអ្នកនោះឯងពេលយប់ គេថាខ្វាក់មាន់។

**ស៖** តើអ្នកដែលធ្វើការនៅក្នុងកងករណីហ្នឹង មានបានទទួលផែនការឲ្យធ្វើការធ្ងន់ធ្ងរជាងអ្នកផ្សេងទៀតទេ ឧទាហរណ៍ដូចជាថា ជាទូទៅហ្នឹងគឺថាមានឲ្យធ្វើការរែកដីឲ្យបាន ៣ម៉ែត្រគូបក្នុងមួយថ្ងៃ ហើយអ៊ីចឹងអ្នកដែលធ្វើការនៅក្នុងកងករណីហ្នឹង ត្រូវធ្វើឲ្យបានលើសពី ៣ម៉ែត្រគូបទៀតមែនទេ?

**ឆ៖** បាទ ត្រង់នោះខ្ញុំពុំបានដឹងទេ។

**ស៖** កាលពីម្សិលមិញលោកបានឆ្លើយ ថាមានអ្នកធ្វើពុតជាឈឺ ដែលគេហៅថា "ឈឺសតិអារម្មណ៍"។ តើគេធ្វើយ៉ាងម៉េចបានជាគេដឹងថា អ្នកហ្នឹងធ្វើពុត ឈឺសតិអារម្មណ៍អីនោះ គេធ្វើយ៉ាងម៉េចបានគេដឹង? គេកំណត់យ៉ាងម៉េចបានដឹងថាអ្នកហ្នឹងឈឺសតិអារម្មណ៍ហ្នឹង? ហើយអ្នកណាជាអ្នកសម្រេចថាអ្នកណាឈឺមែន ឬក៏អ្នកណាឈឺពុតនោះ?

**ឆ៖** បាទ ពេលនោះគឺមានពេទ្យៗគេនៅប្រចាំការ គេតាមដានឃ្លាំមើល ថាបើអ្នកឈឺសតិអារម្មណ៍ពេលគេចេញទៅធ្វើការផុត គាត់នៅដេកប្រលែងគ្នា។

**ស៖** អ៊ីចឹងមានន័យថានៅៗពេលដែលអ្នកណាឈឺ ហើយនៅដេកប្រលែងគ្នាអ៊ីចឹង នៅជជែកគ្នានៅអ៊ីចឹង គេចាត់ទុកអ្នកហ្នឹងថាជាអ្នកឈឺសតិអារម្មណ៍មែនទេ? ឲ្យតែអ្នកជំងឺហ្នឹងគាត់ជជែកគ្នាអ៊ីចឹង គេស្ដាប់ឮគេថាអ្នកហ្នឹងហើយគឺឈឺសតិអារម្មណ៍។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតមែន។

[០៩:២៨:២៦]

**ស៖** នៅពេលដែលគេចាត់ទុកនរណាម្នាក់ជាអ្នកឈឺសតិអារម្មណ៍ហ្នឹង តើគេមានប្រព្រឹត្តតឹងរ៉ឹងចំពោះអ្នកហ្នឹងទេ ឧទាហរណ៍ដូចជាកាត់បន្ថយរបបអាហារ ឧទាហរណ៍ដូចជាឲ្យធ្វើការធ្ងន់ជាងអ្នកផ្សេងទៀត ឲ្យរែកដី រែកអីបន្ថែមអ៊ីចឹង។ តើស្ថានភាពយ៉ាងម៉េចដែរនៅពេលដែលគេចាត់ទុកនរណាម្នាក់ជាអ្នកឈឺសតិអារម្មណ៍ហ្នឹង?

**ឆ៖** បាទ ពេលទទួលបានការរាការណ៍ពីពេទ្យហើយ គឺមេកងត្រូវហៅបុគ្គលនោះ មកទិតៀនស្វ័យទិតៀនជាបន្ទាន់ ដើម្បីឲ្យជននោះកែប្រែទៅថ្ងៃក្រោយ។

**ស៖** ចុះគេមានកាត់បន្ថយរបបអាហារទេ?

**ឆ៖** បាទ បើមាននៅតែឃើញរបៀបនោះទៀត គឺគេកាត់បន្ថយហើយ។

**ស៖** គេមានបញ្ជាឲ្យអ្នកឈឺសតិអារម្មណ៍ហ្នឹងធ្វើការឲ្យបានច្រើនជាងអ្នកផ្សេងទៀតដើម្បីធ្វើការឲ្យទាន់គេទេ?

**ឆ៖** បាទ អត់មានទេ។ បើឈ្មោះនោះ -- ក្រោយពីការទិតៀនហើយ កែប្រែ គឺគេឲ្យធ្វើការតាមធម្មតា។

**ស៖** លោកបាននិយាយអំពីអ្នកដែលខ្វាក់មាន់ គឺមើលមិនឃើញពេលយប់ ហើយដែលត្រូវ

ធ្វើការពេញមួយថ្ងៃ ហើយយប់ឡើងគឺអត់ធ្វើការទេ។ តើគេមានធ្វើតេស្តអីសាកល្បងចំពោះអ្នកដែលអះអាងថាខ្លួនខ្វាក់មាន់ហ្នឹងទេ ដើម្បីដឹងថាតើអ្នកហ្នឹងនិយាយពិត ឬក៏កុហកអីទេ? គេកំណត់យ៉ាងម៉េចបានថា អ្នកហ្នឹងប្រាប់ថាគាត់ខ្វាក់មាន់ហ្នឹង គេកំណត់យ៉ាងម៉េចបានថាគាត់និយាយពិត ឬក៏កុហកនោះ?

**ឆ៖** បាទ ពេលនោះគេបានធ្វើតេស្ត គេបានដឹកដៃគាត់ដើរឲ្យស្ទុះក្នុងអន្លង់។ ដល់ពេលគាត់ដើរទៅស្ទុះអន្លង់ គេថាគាត់ពិតជាខ្វាក់មែន បើគាត់ដើរទៅគេចអន្លង់គឺមិនមែនខ្វាក់ទេ។

**សៈ** ចុះអន្លង់ហ្នឹងជាអន្លង់ធម្មតា ឬក៏អន្លង់គេទៅបត់ដៃបត់ជើងដាក់ ដែលជាអន្លង់គេជីកសម្រាប់បត់ដៃបត់ជើងដាក់លាមកហ្នឹង ឬក៏ជាអន្លង់ធម្មតាទេ?

**ឆ៖** បាទ គឺអន្លង់គេចាក់ទឹកបាយ។

[០៩:៣២:៥៨]

**សៈ** កាលពីម្សិលមិញ លោកនិយាយអំពីអ្នកដែលឈឺ អំពីជំងឺគ្រុន ឬក៏រាក។ តើមានអ្នកណាស្លាប់នៅការដ្ឋានទេ?

**ឆ៖** បាទ ពុំដែលមានទេ។

**សៈ** តើគេទុកអ្នកជំងឺឲ្យនៅការដ្ឋានហ្នឹងដដែល ឬក៏គេដឹកយកទៅកន្លែងពេទ្យ ឬក៏មន្ទីរពេទ្យអ្វីមួយ? ហើយបើសិនជាមានកន្លែងពេទ្យ ឬក៏មន្ទីរពេទ្យហ្នឹង មានទីតាំងស្ថិតនៅកន្លែងណាដែរ?

**ឆ៖** បាទ បើអ្នកជំងឺនោះ ឈឺលើសពីប្រាំថ្ងៃ គឺគេនឹងដឹកតាមរទេះគោឲ្យទៅដេកពេទ្យនៅពយតាអុង បាទជាកន្លែងពេទ្យរបស់សង្កាត់ប៉ោយចារ។

**សៈ** ពេទ្យហ្នឹងជាពេទ្យរបស់ស្រុកត្រពាំងថ្មមែនទេ? ហើយមន្ទីរពេទ្យហ្នឹងមានទីតាំងនៅកន្លែងណា? ហើយអ្នកណាជាអ្នកធ្វើការព្យាបាល?

**ឆ៖** បាទ កន្លែងនោះគេហៅថា "ពេទ្យសង្កាត់" បាទ ពេទ្យសង្កាត់ហ្នឹងគឺមានន័យថា សង្កាត់ប៉ោយចារ។ កាលសម័យនោះគេពុំដែលហៅឃុំទេ គឺគេហៅ សង្កាត់ – ភូមិត្រពាំងថ្ម សង្កាត់ប៉ោយចារ។

[០៩:៣៥:០០]

**សៈ** មន្ទីរពេទ្យហ្នឹងធំទេ? ហើយមានអ្នកជំងឺច្រើនទេ? ហើយអ្នកដែលឈឺទៅពេទ្យហ្នឹងជាសះស្បើយទេ ឬក៏ស្លាប់នៅនឹងពេទ្យហ្នឹងតែម្តង?

**ឆ៖** បាទ មានជាសះស្បើយខ្លះ ខ្លះទៀតបានស្លាប់។

**ស៖** ខ្ញុំមានប្រធានបទចុងក្រោយសម្រាប់សួរលោក។ កាលពីម្សិលមិញលោកបានឆ្លើយថា មានគណៈប្រតិភូចិនមកទស្សនកិច្ច។ តើលោកចាំទេថា គណៈប្រតិភូចិនហ្នឹងមកទស្សនកិច្ចនៅការដ្ឋានទំនប់ហ្នឹងនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំពុំចាំថ្ងៃខែទេ។

**ស៖** តើមានអ្នកណាផ្សេងទៀត អមដំណើរគណៈប្រតិភូចិនហ្នឹងទេ? មានថ្នាក់ដឹងនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាអមដំណើរគណៈប្រតិភូចិនមកការដ្ឋានទេ?

**ឆ៖** បាទ គឺមាន តាញឹម នោះឯង។

**ស៖** តើមានការចាក់បញ្ចាំងកុនឃោសនា មានការប្រជុំ ប្រាប់ទេថា អ្នកណានឹងមកទស្សនកិច្ចអីចឹង?

**ឆ៖** បាទ គឺមានគេបញ្ចាំងកុន។

[០៩:៣៧:៤២]

**ស៖** នៅក្នុងកុនគេមានពន្យល់អីខ្លះ? ខ្លឹមសារនៃកុនយ៉ាងម៉េចខ្លះ? គេមានបង្ហាញអំពី ឧទាហរណ៍ដែលបានអ្វីដែលកើតឡើងនៅចិនឲ្យយើងមើលទេ?

**ឆ៖** បាទ កុននោះគឺគេនិយាយអំពីឈ្មោះ តាចាយ គាត់វាយភ្នំធ្វើស្រែ។

**ស៖** សម្រាប់ជាប្រតិចារឹក ខ្ញុំគិតថាឈ្មោះជាចិនគឺ អាត់ហ្សៃ។ លោកសាក្សី តើលោកអាចជម្រាបបានទេថា នៅការដ្ឋានតើមានជនជាតិ ឬក៏អ្នកបច្ចេកទេសចិនទេ? មានកម្មាភិបាលចិនដែលគ្រប់គ្រងការសាងសង់ទំនប់ហ្នឹងទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** សំណួរចុងក្រោយ។ លោកៗកើតនៅតំបន់នោះ ហើយនៅសម័យខ្មែរក្រហមលោករស់នៅទីនោះ តើលោកធ្លាប់ឮ ឬក៏ធ្លាប់ឃើញថាមានរណ្ដៅដែលគេកប់មនុស្សដែលគេសម្លាប់ចោលទេ?

**ឆ៖** បាទ ធ្លាប់ឃើញ។

**ស៖** តើរណ្ដៅសាកសពទាំងនុ៎ង មានទីតាំងនៅកន្លែងណា?

**ឆ៖** បាទ គឺឃើញនៅខាងកើតអាងទឹកត្រពាំងថ្មហ្នឹង នៅក្បែរផ្លូវហ្នឹងមួយកន្លែង។

**ស៖** នៅក្នុងរណ្ដៅនោះមានសាកសពច្រើនទេ?

**ឆ៖** បាទ ក្នុងរណ្ដៅនោះមិនច្រើនទេ ប្រហែលជាបីនាក់។

**ស៖** ដូច្នេះមានន័យថា លោកឃើញរណ្ដៅពីរ ហើយមានសាកសពបី មែនទេ?

**ឆ៖** បាទ ខ្ញុំឃើញរណ្ដៅតែមួយទេ។

**ស៖** អ៊ីចឹងគឺរណ្ដៅមួយហ្នឹងគឺមានសាកសពបីនៅក្នុងហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកចៅក្រម។

ជាបន្តទៀត អង្គជំនុំជម្រះសូមផ្ដល់វេទិកាដល់ក្រុមមេធាវីការពារក្ដីក្នុងការតាំងសំណួរដេញដោលទៅសាក្សីរូបនេះ ដែលចាប់ផ្ដើមដំបូងដោយក្រុមមេធាវីការពារក្ដីលោកនួន ជា។

សូមអញ្ជើញលោក កូប៉េ!

[០៩:៤២:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកចៅក្រម ហើយនិងភាគីទាំងអស់ ហើយនិងសាក្សីផងដែរ។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនសម្រាប់លោក ហើយខ្ញុំនឹងសួរនៅព្រឹកនេះ។ កាលពីម្សិលមិញ ហើយនិងនៅក្នុងចម្លើយរបស់លោកនៅសហចៅក្រមស៊ើបអង្កេត លោកនិយាយថា លោកចាប់ផ្ដើមធ្វើការងារនៅការដ្ឋានត្រពាំងថ្ម នៅថ្ងៃទី១៤ ខែកុម្ភៈ។ តើលោកអាចប្រាប់ខ្ញុំបានទេថា ហេតុអ្វីបានលោកចាំថ្ងៃថាថ្ងៃទី១៤ ខែកុម្ភៈ ច្បាស់ម្ល៉េះ? ហើយហេតុអ្វីក៏--

**ប្រធានអង្គជំនុំ៖**

សូមកាត់លោកមេធាវី មានបញ្ហាមីក្រូហ្វូន។

*(សម្រាករយៈពេលខ្លី - មានបញ្ហាបច្ចេកទេស)*

[០៩:៤៥:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីកូប៉េ បន្តទៀតបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំនឹងសួរសំណួរឡើងវិញទាំងស្រុង។ បាទ តើស្តាប់ឮទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយបាទ រង់ចាំគេជួសជុលហើយសិន មីក្រូហ្វូន លោកមេធាវី។

*(សម្រាករយៈពេលខ្លី - មានបញ្ហាបច្ចេកទេស)*

[០៩:៥០:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្ត!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីម្សិលមិញលោកបានឆ្លើយដោយបញ្ជាក់ថាលោកបានចាប់ផ្តើមធ្វើការងារនៅត្រពាំងថ្ម នៅការដ្ឋាននោះគឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៧។ សូមលោកប្រាប់ខ្ញុំ ហេតុអ្វីក៏លោកបានជាចាំកាលបរិច្ឆេទជាក់លាក់ម្ល៉េះ? ហេតុអ្វីក៏ថ្ងៃទី១៤ ខែកុម្ភៈ តើមានហេតុកត្តាអ្វីដែលធ្វើឲ្យលោកចាំច្បាស់ម្ល៉េះ?

[០៩:៥០:៤២]

**លោក កាន ថុល៖**

**ឆ៖** បាទ មូលហេតុដែលខ្ញុំបានចាំ គឺមុននឹងចេញដំណើរទៅលើកអាង គេបានប្រជុំប្រាប់ថាកងកម្លាំងចល័តទាំងអស់ យើងត្រូវមានមុខ នៅថ្ងៃទី១០ ខែ០២ ទាំងអស់គ្នានៅការដ្ឋាន។ រួចហើយនាំគ្នាសម្រាកបីថ្ងៃនោះគឺនាំគ្នាធ្វើរោង បាទ ក្នុងពេលបីថ្ងៃនោះ គឺធ្វើរោងឲ្យហើយ រួចដល់ថ្ងៃទី១៤ យើងចុះអនុវត្តទាំងអស់គ្នា។

**ស៖** សូមអរគុណលោកសាក្សី។ ម្សិលមិញលោកក៏បានឆ្លើយដែរថា ការសាងទំនប់នោះបាន

បញ្ចប់មុនបុណ្យចូលឆ្នាំខ្មែរ។ តើលោកចាំទេថាតើប៉ុន្មានថ្ងៃមុនពេលថ្ងៃចូលឆ្នាំខែ ដែលការងារនោះចប់?

**ឆ៖** បាទ គឺចប់ហើយ ដល់ចូលឆ្នាំខ្មែរតែម្តង។

**ស៖** លោកទើបតែបានទទួលសំណួរ ហើយលោកបានឆ្លើយអំពីការប្រជុំដែលនិយាយថា គេបានទទួលប្រតិភូចិនដែលនៅក្នុងកិច្ចប្រជុំនោះ តាញ៉ឹម គាត់បាននិយាយ។ តើលោកនៅចាំអ្វីខ្លះដែល តាញ៉ឹម បាននិយាយទាក់ទងទៅនឹងការបញ្ចប់ទំនប់នោះឲ្យចប់មុនរយៈពេលពីរខែនោះ តើលោកចាំអ្វីខ្លះពីសម្តីរបស់គាត់?

**ឆ៖** បាទ ពេលនោះខ្ញុំមិនបានឮគាត់និយាយអ្វីទេ។

[០៩:៥៣:១៥]

**ស៖** ហើយមានសេចក្តីលម្អិតមួយចំនួន ដែលខ្ញុំចង់សួរលោកទាក់ទងទៅនឹងសុន្ទរកថារបស់លោក វស់ ញ៉ឹម ហើយសូមអនុញ្ញាតតុលាការដើម្បីអានឯកសារ E3/7, អង់គ្លេស ERN 00498181 ហើយបារាំង ERN 00606-- ហើយខ្មែរ 0069260។ ហើយលោកសាក្សីខ្ញុំនឹងអានឯកសារនេះ៖ “សមមិត្ត វស់ ញ៉ឹម ហើយជាអនុប្រធាននៃគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ ហើយជាលេខានៃគណៈភូមិភាគពាយ័ព្យនៃបក្សកុម្មុយនីស្តកម្ពុជា ហើយនិងជាប្រធាននៃគណៈភូមិភាគ ហើយថាទំនប់នេះត្រូវឲ្យបញ្ចប់ក្នុងរយៈពេលពីរខែនៅក្នុង ហើយៗភូមិភាគពាយ័ព្យត្រូវតែឆ្លើយតបទៅនឹងផែនការរបស់គណៈមជ្ឈិមនៅក្នុងការដ្ឋានដ៏ធំមួយ។ ហើយនៅក្នុងឆ្នាំនេះគឺបាន មានទទួលបានទឹកច្រើនលានម៉ែត្រគូប ហើយនិងមានប្រឡាយបីធំៗ ហើយនិងសម្រាប់ផ្គត់ផ្គង់ទៅវាលស្រែជាច្រើនពាន់ហិកតា ហើយនិងមាន អាចនឹង៣០០លានម៉ែត្រគូបនៃទឹកសម្រាប់ផ្សព្វផ្សាយ សម្រាប់ជាផ្តល់ធារាសាស្ត្រនោះ ហើយនៅពេលដែលយើងចាប់ផ្តើមកសាងអាងទឹកនេះ មនុស្ស ២០.០០០នាក់ដែលពាក់ពាន់ទៅនឹងការលើកនេះ ហើយយើង គេអាចកោតសរសើរអំពីគោលបំណងដ៏មោះមុតនៅក្នុងការកសាងប្រទេស ហើយក្នុងរយៈពេលខ្លី ពីរឆ្នាំបន្ទាប់ពីចប់សង្គ្រាម។ ឥឡូវនេះគឺថា អាងទឹកធំ ឬតូចដែលធ្វើឲ្យចែកចាយទឹកឲ្យដំណាំស្រូវដុះដាលបានគ្រប់ទីកន្លែងទាំងអស់។” ពេលដែលខ្ញុំអានពាក្យទាំងអស់នេះដែល តើលោកអាចនឹងនឹកឃើញអំពីសម្តីដែលខ្ញុំទើបតែអានអម្បាញ់មិញនេះទេ បាទ?

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា របៀបនៃការអានសម្រង់ហ្នឹង គឺថាអាចនឹងខ្លឹមសារទាំង

អស់ដែលថាជាពាក្យពេចន៍របស់ រស់ ញឹម នេះ គឺថា តាមដែលខ្ញុំយល់ហ្នឹងគឺមិនឯកសារនោះគឺថា ការដកស្រង់នូវកថាខណ្ឌដោយឡែកពីគ្នា ហើយភាសាអំពីពីភ្នាក់ងារព័ត៌មានដែលផ្សព្វផ្សាយអំពីដំណើរនេះ។ ប្រសិនបើមេធាវីសម្រួលសំណួរនោះឡើងវិញដោយផ្តោតទៅលើការដកស្រង់ ដែលឯកសារនេះថាជាសម្តីរបស់ រស់ ញឹម គឺជាការល្អជាង បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា ខ្ញុំយល់ស្របមួយផ្នែក ប៉ុន្តែខ្ញុំ ផ្នែកមួយគឺជាការដកស្រង់ផ្ទាល់ដែលថានៅក្នុងអត្ថន្តរៈនៅក្នុងភាសាអង់គ្លេស ហើយផ្សេងទៀតគឺថា ជាការដកស្រង់ដោយមិនផ្ទាល់ ដែលសមមិត្ត រស់ ញឹម បាននិយាយ។ ដូច្នេះ ការដកស្រង់ទាំងពីរនេះ ទំនងជាការដកស្រង់ដោយផ្ទាល់អំពីលោក រស់ ញឹម មួយដោយផ្ទាល់, មួយដោយមិនផ្ទាល់ ជាសម្តីរបស់គាត់ហ្នឹង។ ហើយសំណួររបស់ខ្ញុំ ខ្ញុំអាចនឹងកែសម្រួល ហើយការដកស្រង់គឺជាសម្តីដែលអាចនឹងលោក រស់ ញឹម បាននិយាយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយសួរសាក្សីថា តើលោកចាំពាក្យសម្តីដែលខ្ញុំបានអានខាងដើមទេ នៅពេលដែលលោក រស់ ញឹម ទៅទីនោះ បាទ?

[០៩:៥៧:៥៣]

**លោក កាន ថុល៖**

**ឆ៖** បាទ ខ្ញុំពុំបានចាំទេ។

**ស៖** សេចក្តីលម្អិតមួយ ខ្ញុំនឹងបន្តទៅទៀត លោកបាននិយាយថា លោកបានឮ គឺថាមានកម្មករ ១៥.០០០នាក់ធ្វើការនៅនេះ ប៉ុន្តែនៅឯកសារនេះ គឺថាអាច ២០.០០០នាក់។ តើតួលេខណាមួយដែលលោកអាចនឹងនឹកឃើញបានទេ? លោកដឹងថាតួលេខមួយណា?

**ឆ៖** បាទ កាលនោះ គាត់បាននិយាយថាកម្លាំងមាន ១៥.០០០នាក់ចេញមកពីគ្រប់ស្រុក ប៉ុន្តែដោយឡែកនៅក្នុងស្រុកភ្នំស្រុក គឺមានកម្លាំងជួយៗជាបណ្តោះអាសន្នមួយចំនួនទៀតបាទ។

**ស៖** ហើយលោកក៏បានឆ្លើយនឹងសំណួរមួយចំនួនទាក់ទងទៅនឹង តាញឹម និង រស់ ញឹម ដែរ។ តើមានអ្វីដែលលោកចងចាំបានថា លោកបានឮអំពីគាត់ ថាតើគាត់មានមុខងារអ្វី? តើក្នុងរយៈឆ្នាំ ១៩៧៥ ដល់ ៧៩ តើលោកបានដឹងអ្វីខ្លះអំពីលោក រស់ ញឹម នេះ?

**ឆ៖** បាទ ខ្ញុំពុំដែលបានដឹងទេ។

**ស៖** តើលោកដឹងថា កូនប្រុសរបស់គាត់ឈ្មោះ ជាល –ឈ្មោះ ឆ្នាំង– តើលោកដឹងទេ? ឬក៏ស្គាល់គាត់ទេ?

[១០:០០:០០]

**ឆ៖** បាទ ខ្ញុំឮតែឈ្មោះ គេថាកូន តាញ៉ឹម ឈ្មោះ ជាល ។ ឮមែន។

**ស៖** តើលោកចាំបានអ្វីខ្លះដែលលោកបានឮនោះថាតើ តាជាល ហ្នឹង គាត់មានមុខងារឋានៈជាអ្វីបាទ?

**ឆ៖** បាទ កាលនោះ ដែលខ្ញុំឮៗថាឈ្មោះ ជាល នេះជាប្រធានយុវជនតំបន់៥។

**ស៖** តើលោកបានឮថា គាត់មានមុខងារជាអ្នកកំពូលប្រធានគេនៅតំបន់៥ ដែរឬទេ?

**ឆ៖** បាទ មិនដែលឮទេ។

**ស៖** តើលោកបានឃើញ តាជាល ធ្លាប់ដើរទៅមើលការដ្ឋានទំនប់នោះដែរទេ?

**ឆ៖** បាន មិនដែលឃើញទេ។

**ស៖** តើលោកចាំដែរទេថា តាជាល គាត់វត្តមាននៅក្នុងការប្រជុំដែលឪពុករបស់គាត់ តាញ៉ឹម បាននិយាយទៅកាន់គណៈប្រតិភូចិននោះដែរទេ?

**ឆ៖** បាទ គឺខ្ញុំមិនបានដឹង។

[១០:០២:០៦]

**ស៖** កាលពីម្សិលមិញ លោកបាននិយាយអំពី តាហ៊ឹង្ស តើលោកស្គាល់ឈ្មោះពិត ឬក៏ឈ្មោះពេញជានាមត្រកូលរបស់ តាហ៊ឹង្ស ទេ?

**ឆ៖** បាទ មិនដែលស្គាល់ត្រកូលរបស់គាត់ទេ គឺស្គាល់តែឈ្មោះ ហ៊ឹង្ស។

**ស៖** តើឈ្មោះ ម៉ែន ជឿន នេះ លោកអាចនៅនឹកឃើញឈ្មោះ ម៉ែន ជឿន នេះដែរទេ?

**ឆ៖** បាទ ពុំដែលឮទេ។

**ស៖** ចុះតើលោកធ្លាប់ដែលឮគេហៅគាត់ថា បងទី៧ ដែរទេ?

**ឆ៖** បាទ មិនដែលឮ។

**ស៖** តើលោកដឹងថាឈ្មោះ ហ៊ឹង្ស នេះធ្លាប់ដែលបានត្រូវបានគេចាប់ខ្លួនទេ? ហើយបើធ្លាប់ត្រូវបានគេចាប់ខ្លួន គេចាប់ខ្លួននៅពេលណា?

**ឆ៖** បាទ មិនដឹងទេ។

**ស៖** លោកដឹងថា តារ៉ាល់ ដែលលោកបាននិយាយអំពីឈ្មោះគាត់កាលពីម្សិលមិញ តើគាត់ធ្លាប់ដែលត្រូវបានគេចាប់ខ្លួនទេ? ហើយបើសិនណាធ្លាប់ត្រូវបានគេចាប់ខ្លួន គេចាប់នៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំមិនដឹង។

**ស៖** លោកដែលដឹងថា តាជាល ត្រូវបានគេចាប់ខ្លួនទេ? ហើយបើចាប់ហ្នឹងគេចាប់នៅពេលណា?

**ឆ៖** បាទ អត់ដឹង។

**ស៖** តើលោកធ្លាប់ដែលឮថាគេចាប់ខ្លួន រស់ ញឹម ទេ – តាញឹម? ហើយបើគេចាប់ខ្លួនហ្នឹង គេចាប់ខ្លួន រស់ ញឹម នៅពេលណា?

**ឆ៖** បាទ អត់ដឹង។

**ស៖** ហើយជាចុងក្រោយនេះ ម្សិលមិញលោកនិយាយអំពីឈ្មោះ តាឃ្លាំង -- លោកនិយាយអំពីឈ្មោះ តាខ្លែង ហើយ តាខ្លែង តើធ្លាប់ៗបានគេចាប់ខ្លួនទេ? បើចាប់ហ្នឹងគេចាប់នៅពេលណាដែរ?

**ឆ៖** បាទ អត់ដឹង។

**ស៖** ក្រោយមកនៅក្នុង -- ក្រោយឆ្នាំ១៩៧៩ តើលោកមានធ្លាប់ដែលឮអំពីមូលហេតុនៃការចាប់ខ្លួនអ្នកទាំងនេះដែរទេ?

**ឆ៖** បាទ មិនដែលឮ។

[១០:០៦:០៥]

**ស៖** តើលោកធ្លាប់ឮក្រដាសប្រាក់ហ្នឹងត្រូវបានគេបោះពុម្ព ហើយប្រាក់ខែត្រូវបានគេបើកជូនទៅឲ្យខាងភូមិភាគឧត្តរនោះដែរឬទេនៅក្នុងឆ្នាំ១៩៧៧?

**ឆ៖** បាទ មិនដឹង។

**ស៖** លោកដែលឮថា តាហ៊ីង្ស ចល័តកងទ័ពរត់ចូល ចល័តកងទ័ព ដឹកនាំកងទ័ពរត់ចូលទៅក្នុងព្រៃដើម្បីធើបបះបោរដែរឬទេ?

**ឆ៖** បាទ មិនដែលដឹង។

**ស៖** លោកដែលឮសួរថា មានគេបាញ់ប្រតិភូចិនដែរទេ?

**ឆ៖** បាទ មិនដែលដឹង។

**ស៖** អ្នកដែល -- លោកដែលឮសួរថា កម្លាំងកងទ័ពរបស់ តាញឹម លួចដឹងអាវុធចូលទៅលាក់ក្នុងព្រៃដែរទេ?

**ឆ៖** បាទ មិនដែលដឹង។

**ស៖** តើលោកធ្លាប់ដែលឮថា កងទ័ពបូព៌ាហ្នឹងរួមកម្លាំងគ្នាជាមួយនឹងកម្លាំងកងទ័ពពីភូមិភាគពាយ័ព្យហើយនិងបូព៌ា រួមកម្លាំងគ្នាដែរទេ?

**ឆ៖** បាទ មិនដែលដឹង។

**ស៖** កាលពីម្សិលមិញលោកនិយាយអំពីកម្មាភិបាលភូមិភាគនិរតី ទៅភូមិភាគពាយ័ព្យ។ ចុះលោកធ្លាប់ដែលឮសួរថាមានកម្មាភិបាលពីភូមិភាគបស្ចិមត្រូវបានគេយកឱ្យទៅធ្វើការនៅភូមិពាយ័ព្យដែរទេក្នុងឆ្នាំ១៩៧៧?

[១០:០៨:៥០]

**ឆ៖** បាទ មានឃើញ។

**ស៖** លោកបានឃើញអ្វីខ្លះ?

**ឆ៖** បាទ គឺគាត់នោះឈ្មោះ តាសន គាត់នៅក្តាប់ចល័ត នៅក្នុងឆ្នាំ៧៨ គាត់ថាគាត់នៅភូមិភាគបស្ចិម។

**ស៖** តើគាត់មាននិយាយថា គាត់មកពីផ្នែកណា? ទីកន្លែងណាដែរទេនៅក្នុងភូមិភាគបស្ចិមហ្នឹង?

**ឆ៖** បាទ មិនដែលដឹង។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ នាពេលនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ អញ្ជើញចូលមកវិញ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីនិងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ត្រឡប់មកវិញកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:២៩ នាទី)*

[១០:២៩:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តទៀត សូមអញ្ជើញលោកមេធាវីកូប៉េ បន្តសំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនៅសល់សំណួរតិចតួចទេ។ បើខ្ញុំយល់មិនច្រឡំទេ តាមរយៈសក្ខីកម្មរបស់លោក លោកបានឆ្លើយថា លោកមិនដែលបានឃើញអ្នកណាម្នាក់ស្លាប់នៅឯការដ្ឋានទំនប់ត្រពាំងថ្មទេ ប៉ុន្តែនៅក្នុងចម្លើយរបស់លោក លោកពិតជាបាននិយាយអំពីមនុស្សម្នាក់នៅក្នុងកងរបស់លោកដែលក្រោយមកស្លាប់នៅមន្ទីរពេទ្យ។ មនុស្សនេះ ឈ្មោះ ដៅ។ តើលោកចាំបានច្បាស់ប៉ុនណាដែរ អំពីមនុស្សម្នាក់ឈ្មោះ ដៅ នេះ តើមានអ្វីកើតឡើងចំពោះអ្នកនេះ?

**លោក កាន ថុល៖**

**ឆ៖** បាទ គេនោះ គឺឈ្មោះ ដូ គាត់ស្លាប់នៅមន្ទីរពេទ្យមែន ដោយគាត់មានជំងឺ គេហៅថាភាសាខ្មែរយើងថា “អ្នកតាចូល”។ បាទ ពេលនោះលោកគ្រូសង្គមកិច្ចគាត់បានយកម្ទេស និងម្រេចផ្តុំបញ្ចូលច្រមុះដើម្បីឱ្យអ្នកតាចេញ។ ពេលផ្តុំរួចហើយ ស្រាប់តែចេញមកសុទ្ធតែឈាម។ ម្ល៉ោះហើយគាត់ក៏ឈ្មោះ ដូ នោះស្លាប់នៅមន្ទីរពេទ្យទៅ។

**ស៖** ខ្ញុំខ្លាចតែខ្ញុំយល់លោកមិនបានពេញលេញទេ។ តើបុគ្គលរូបនេះ ស្លាប់នៅឯមន្ទីរពេទ្យដោយសារតែការព្យាបាលរបៀបហ្នឹង ឬក៏យ៉ាងណា? សូមលោកពន្យល់ឱ្យបានលម្អិតបន្តិចបានទេ?

**ឆ៖** បាទ ពេលនោះ ពេលដែលកំពុងតែឈឺធ្ងន់ ខ្ញុំមិនបានឃើញគាត់ទេ។ ពេលក្រោយដែលស្លាប់ គឺខ្ញុំបានទៅដល់ៗ ហើយបានសួរនៅក្នុងមន្ទីរពេទ្យនោះថា “ហេតុអ្វីបានជាគាត់ស្លាប់?” បាទនៅមន្ទីរពេទ្យនោះ ក៏បានប្រាប់ថា ជំងឺនេះគេហៅថា “អ្នកតាចូល”។ ហើយគាត់បើកភ្នែកទៅតែលើៗគាត់មិននិយាយ ភ្នែកឡើងពណ៌ក្រហម។ ដល់រួចហើយ លោកគ្រូសង្គមកិច្ចគាត់បានដាក់ថ្នាំទៅ ស្រាប់តែស្លាប់។

[១០:៣២:២២]

**ស៖** កាលណាលោកនិយាយអំពីថា អ្នកតាៗចូលអ៊ីចឹង គឺលោកចង់និយាយថាម៉េចនុ៎ង?

**ឆ៖** បាទ នេះជាជំនឿអរូបី។

**ស៖** ដូច្នេះ បើខ្ញុំយល់មិនច្រឡំទេ គឺការស្លាប់ដោយអកុសលនេះ គឺថាមិនមែនជាការស្លាប់ដោយសារតែស្ថានភាពការងារនៅការដ្ឋានទំនប់ត្រពាំងថ្មទេ បើខ្ញុំយល់យ៉ាងដូច្នេះ តើវាត្រឹមត្រូវទេ ឬក៏មិនត្រឹមត្រូវទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** សំណួរមួយទៀត លោកសាក្សី ម្សិលមិញ លោកត្រូវបានសួរថាតើ ដោយសហព្រះរាជអាជ្ញា លោកដែលឮសូរពាក្យថា "សមរភូមិក្តៅ" ដែរឬក៏អត់នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម? កងចល័តរបស់លោកនេះ ក៏បានរៀបចំជាកងតូច ហើយលោកនិយាយអំពីកងវរៈនិយាយអំពីប្រធានកងវរសេនាធំ វរសេនាតូច។ លោកដឹងទេថា ហេតុអ្វីបានជាគេយករចនាសម្ព័ន្ធកងទ័ពនេះយកទៅប្រើប្រាស់ជាមួយនឹងកងចល័តដែរនោះ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ។

**ស៖** ហើយកាលពីម្សិលមិញ លោកក៏បាននិយាយអំពីការធ្វើការងារនៅពេលយប់ចាប់ពីម៉ោងប្រាំពីរ ដល់ម៉ោងដប់យប់។ ប៉ុន្តែការងារនេះ គេធ្វើតែពេលខ្លះទេ គឺកងរបស់លោក ជួនកាលធ្វើការនៅពេលយប់ពីម៉ោងប្រាំពីរ ដល់ម៉ោង ដប់យប់។ ហេតុអ្វីបានជាគេធ្វើការនៅពេលយប់តែក្នុងពេលខ្លះយ៉ាងដូច្នេះ? សូមលោកជួយពន្យល់បន្តិចបានទេ?

[១០:៣៤:៥៤]

**ឆ៖** បាទ ពេលនោះ គេថា វាយសម្រុកយកឱ្យហើយ គេហៅថា "វាយផ្តាច់ព្រ័ត្រ"។

**ស៖** លោកបានធ្វើការនៅការដ្ឋាននោះអស់រយៈពេលប្រហែលជាពីរខែ។ ពេលខ្លះ គឺលោកធ្វើការ -- នៅពេលលោកធ្វើការនៅការដ្ឋានអស់រយៈពេលប្រមាណជាពីរខែហ្នឹង តើការងារនៅពេលយប់ហ្នឹង លោកធ្វើបានញឹកញាប់ប៉ុនណា? បានតែពីរដង ឬក៏ប៉ុន្មានដងដែរ?

**ឆ៖** បាទ នៅពេលដំបូង ធ្វើបានប្រហែលជាពីរទៅបីដង ដោយពេលនោះ គឺខែវាភ្លឺ តែពេលដែលខែងងឹត គឺពុំបានធ្វើទេ ព្រោះកាប់ដីមិនកើត និងរែកដើរមកមិនរួច ដោយសារវាងងឹត បាទ។ ដល់ពេលដែលវ៉ៃសម្រុកផ្តាច់ព្រ័ត្រនោះ ពេលនោះគឺខែភ្លឺពេញ បាទ ខែភ្លឺពេញក្នុងមួយយប់នោះគឺមួយយប់ពីរយប់គឺរដូវខាងខ្នើត គឺចុងខ្នើតហ្នឹង គឺខែភ្លឺនោះវាពេញ បាទ បានភ្លឺបានលើកបាទ។

**ស៖** បាទ ច្បាស់ហើយលោកសាក្សី។ សំណួរមួយទៀត ពីម្សិលមិញលោកត្រូវបានសួរអំពីទឹកផឹក ហើយលោកបានឆ្លើយថា ទឹកហូបនៅឯការដ្ឋានហ្នឹងគឺបានមកពីស្ទឹងបឹងនៅក្បែរការដ្ឋាននោះ។ លោកកើតមក និងធំធាត់នៅក្នុងតំបន់ជិតការដ្ឋាននោះ ហើយមុនឆ្នាំ១៩៧៥ ឬក្រោយឆ្នាំ១៩៧៩ តើលោកនៅតែហូបទឹកចេញមកពីអូរ ចេញមកពីស្ទឹងហ្នឹងដដែលដែរឬទេ?

**ឆ៖** បាទ គឺតាមទម្លាប់នៅស្រុកភូមិខ្ញុំ គឺហូបទឹកស្រះ។

[១០:៣៧:៥៦]

**ស៖** ហើយមកដល់សព្វថ្ងៃនេះ វានៅតែធម្មតាទេឬអីដែលប្រជាជននៅតែ អ្នកភូមិអ្នកស្រុកនៅតែហូបទឹកមកពីអូរមកពីស្ទឹងហ្នឹងជាធម្មតាដដែលទេឬ?

**ឆ៖** បាទ សព្វថ្ងៃនេះ គេហូបតែទឹកបរិសុទ្ធ។

**ស៖** ឥឡូវខ្ញុំរៀបសំណួរឡើងវិញ។ តើគេនៅតែអាចហូបទឹកពីស្ទឹង ពីអូរហ្នឹងដដែល ដោយមិនមានការប៉ះពាល់ទៅដល់សុខភាពអីទេ ឬយ៉ាងម៉េចសព្វថ្ងៃនេះ?

**លោក ចូសេហ្វ អេនគូ្រ ប៊ិយលើ៖**

សូមអរគុណលោកប្រធាន។ សាក្សី គឺថានិយាយតែពីបទពិសោធន៍របស់គាត់ទេ ប៉ុន្តែគាត់មិនអាចនិយាយអំពីបទពិសោធន៍ពាក់ព័ន្ធទៅនឹងអ្នកភូមិថា តើអ្នកភូមិនេះនៅតែហូបទឹកពីអូរពីស្ទឹងហ្នឹងដដែលសព្វថ្ងៃនេះ ឬក៏យ៉ាងម៉េច? ខ្ញុំសុំជំទាស់។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំយល់អំពីការជំទាស់នេះ ខ្ញុំអាចរៀបសំណួរឡើងវិញលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** សព្វថ្ងៃនេះ ឬក៏មុននេះ លោកមានហាមឃាត់កូនចៅរបស់លោកមិនឲ្យហូបទឹក ផឹកទឹកពីអូរហ្នឹង ឬក៏យ៉ាងណា?

**លោក កាន ផុល៖**

**ឆ៖** បាទ សព្វថ្ងៃនេះ គឺបានហាមកូនចៅទាំងអស់ ពន្យល់ថា ទឹកតាមបឹង តាមស្ទឹងគឺសុទ្ធតែជាតិគីមី មិនអាចហូបបានទេ គឺឲ្យហូបតែទឹកបរិសុទ្ធ។

**ស៖** ប៉ុន្តែលោកបាននិយាយថា លោកធ្លាប់ នៅពេលនោះ នៅពេលមុននោះ លោកថានៅតែផឹកពីស្ទឹង ពីអូរហ្នឹងដដែល។ តើប្រជាជនមានធ្លាប់ខ្លួនឈឺដោយសារការហូបទឹកអូរ ហូបទឹកស្ទឹងហ្នឹង

ឬក៏យ៉ាងណា?

**ឆ៖** បាទ នៅពេលមុន ដែលពុំទាន់មានៗមានទឹកបរិសុទ្ធ គឺប្រជាពលរដ្ឋនៅទីនោះក៏អាចហូប ទឹកស្រះ ហើយនិងទឹកបឹងខ្លះៗដែរ។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយសម្រាប់ប្រធានបទនេះ ម្សិលមិញក៏សួរ អំពីបញ្ហាប្រជាជនវៀតណាម ប្រជាជននៅក្នុងតំបន់របស់លោក លោកបានឆ្លើយថា លោកធ្លាប់បានឮ ជនជាតិវៀតណាមត្រូវបានគេចាប់ខ្លួន។ លោកដឹងទេថា ហេតុអ្វីបានប្រជាជនវៀតណាមត្រូវបានគេ ចាប់ខ្លួន?

**ឆ៖** បាទ គឺខ្ញុំមិនដឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

ជាបន្តសូមផ្តល់វេទិកាដល់មេធាវីការពារក្តីលោក ខៀវ សំផន។ សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោកចៅក្រម។

[១០:៤១:៥៦]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ហើយជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះកញ្ញា អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវី អន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរសុំការបំភ្លឺពីលោកមួយចំនួន។ អម្បាញ់មិញលោក បានឆ្លើយទៅលោកចៅក្រម ឡាវែន៍ ថា លោកត្រូវបានគេចាប់តាំងឲ្យធ្វើអនុប្រធានកង៣០ ដោយមេ របស់លោក។ តើលោកដឹងថា អ្នកណាជាអ្នកតែងតាំងមេរបស់លោកដែរទេ?

**លោក កាន ធុល៖**

**ឆ៖** បាទ មិនដឹងទេ។

**ស៖** តើប្រធានកងរបស់លោកនោះ លោកដឹងថាអ្នកណាជាអ្នកតែងតាំងគាត់ដែរឬទេ?

**ឆ៖** បាទ ប្រធានកងរបស់ខ្ញុំគឺមានប្រធានវរៈនេះឯងអ្នកតែងតាំង។

**សៈ** លោកបានឆ្លើយថានៅកងធំនុ៎ង មានកងតូចបីដែលមានសមាជិក៣០នាក់។ តើប្រធានកងតូចពីរនាក់ទៀត កង៣០ ពីរនាក់នោះត្រូវបានតែងតាំងដោយប្រធានកងវរសេនាតូចដែរ ឬក៏យ៉ាងណា?

**ផៈ** បាទ ពេលគេតែងតាំង គឺគេតែងតាំងសរុបទាំងអស់តែម្តង មានប្រធាន អនុប្រធាន និងសមាជិក។

[១០:៤៣:៥០]

**សៈ** តើលោកដឹងថា ការតែងតាំងនៅក្នុងកងមួយរយនាក់នៅក្រុមផ្សេងទៀតដែលធ្វើការនៅទំនប់ត្រពាំងថ្មនោះ គេធ្វើយ៉ាងដូចម្តេចដែរ ការតែងតាំងប្រធានកងមួយរយផ្សេងទៀតនុ៎ង?

**ផៈ** បាទ មិនដែរដឹងទេ។

**សៈ** តាមចម្លើយរបស់លោក គឺថានៅក្នុងកងរបស់លោកមានអ្នក១៧ មេសា ហើយនិងប្រជាជនមូលដ្ឋាន។ តើខ្ញុំយល់ដូច្នេះជាការយល់ត្រឹមត្រូវដែរឬទេ?

**ផៈ** បាទ ជាត្រឹមត្រូវ។

**សៈ** នៅក្នុងឋានៈជាអនុប្រធានកងនោះ តើលោកមានដាក់លក្ខខណ្ឌការងារខុសគ្នាទៅដល់ប្រជាជន ១៧មេសា ដែរឬទេ?

**ផៈ** អត់មាន។

**សៈ** តើរបបអាហារហ្នឹងសម្រាប់ អ្នក១៧មេសា ដែលនៅក្នុងកងរបស់លោកហ្នឹង គឺរបបអាហារគាត់ខុសពីរបបអាហាររបស់អ្នកផ្សេងទៀត ឬក៏យ៉ាងណា?

**ផៈ** បាទ ទទួលអាហាររួមគ្នាទាំងអស់។

**សៈ** ជាទូទៅ តើលោកធ្លាប់ទទួលការណែនាំពីប្រធានកង ឬក៏ប្រធានវរៈដើម្បីឱ្យប្រព្រឹត្តទៅលើប្រជាជន១៧មេសា ហ្នឹង ខុសពីប្រជាជនផ្សេងទៀតដែរឬទេ?

**ផៈ** បាទ អត់មានទេ។

**សៈ** ក្នុងសេចក្តីណែនាំដែលលោកបានទទួល តើមានការណែនាំដែលតម្រូវឱ្យការធ្វើទារុណកម្មទៅលើអ្នកធ្វើការដែលស្ថិតនៅក្រោមបញ្ជាលោកដែរឬទេ?

[១០:៤៦:២៤]

**ផៈ** បាទ សុំសិទ្ធិមិនឆ្លើយ។

**ស៖** ខ្ញុំសួរបែបផ្សេងទៀត។ តើលោកធ្លាប់ធ្វើទារុណកម្មទៅលើអ្នកធ្វើការនៅក្រោមបង្គាប់លោកដែរឬទេ?

**ឆ៖** បាទ ហ្នឹងក៏សុំសិទ្ធិមិនឆ្លើយដូចគ្នា។

**ស៖** នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោក ក្រៅពីបញ្ជាពីថ្នាក់លើមក តើលោកមានលទ្ធភាពប្រចាំថ្ងៃនោះក្នុងការ -- មានគំនិតផ្តួចផ្តើមធ្វើអ្វីមួយ?

**លោក ចូសេហ្វ អេនទ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងសិទ្ធិរបស់សាក្សីក្នុងការលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ទាក់ទងទៅនឹងសិទ្ធិរបស់គាត់មិនឆ្លើយទម្លាក់កំហុស ទម្លាក់ពិរុទ្ធភាពលើខ្លួនឯង។ ដូច្នេះសាក្សីគួរតែត្រូវបានអនុញ្ញាតមិនឆ្លើយទៅនឹងសំណួរណាមួយដែលយល់ថា ជាការដាក់ពិរុទ្ធភាពលើខ្លួនឯង។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤៩:១០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបសិទ្ធិដល់សាក្សីរួចហើយ។ ដូច្នេះសំណួរសួរហើយត្រូវដាក់បន្ទុកលើខ្លួនគាត់ៗមានសិទ្ធិមិនឆ្លើយ ដូច្នេះសូមលោកមេធាវីបន្តសំណួរបន្តទៀត។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីជាប្រចាំថ្ងៃ តើលោកទទួលបញ្ជាពីអ្នកណាដែរជាទូទៅ?

**លោក កាន ថុល៖**

**ឆ៖** បាទ គឺខ្ញុំកងតូច ទទួលពីកងធំ។

**ស៖** ពេលដែលលោកនិយាយថា ថ្នាក់លើហ្នឹង លោកចង់និយាយពីប្រធានកងលោក ឬអ្នកណាលោកអាចឲ្យឈ្មោះ ផ្តល់ឈ្មោះជាក់លាក់បានទេ?

**ឆ៖** សូមសួរម្តងទៀត។

**ស៖** ដែលលោកនិយាយអំពីថ្នាក់លើ អ៊ីចឹងខ្ញុំសួរលោកថា នៅពេលដែលលោកនិយាយថា

ថ្នាក់លើនុំង គឺលោកសំដៅលើប្រធានកង ឬក៏សំដៅលើអ្នកណាផ្សេង?

**ឆ៖** បាទ ថ្នាក់លើនោះ គឺឲ្យតែគេចាប់ពីកងធំវរៈហ្នឹងទៅលើ គឺថ្នាក់លើហើយ។

**ស៖** អ៊ីចឹងខ្ញុំត្រូវយល់ថា ពេលខ្លះនុំង គឺលោកទទួលបញ្ជាដោយផ្ទាល់ពីប្រធានកងវរសេនាតូច ដោយមិនឆ្លងកាត់តាមមេផ្ទាល់របស់លោកទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលនោះ គេបញ្ជារួម បាទបញ្ជារួម ដាក់ឲ្យមកប្រធានកងតូច ហើយមេកងតូច ហ្នឹង គាត់អ្នកចាត់ចែងរាល់កិច្ចការងារ កងតូច។ ប្រធាន គាត់ចាត់មកលើអនុប្រធាន ប្រធានក៏ -- បាទ បន្តទៅក្រោមទៀត។

[១០:៥២:០៧]

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេនោះ គឺថាលោកមិនបានទទួលបញ្ជាអំពីប្រធានកងវរសេនាតូចនោះទេ គឺលោកទទួលបញ្ជាពីមេផ្ទាល់របស់លោកតែម្តង។ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ ពេលទទួលបញ្ជា គឺបញ្ជារួមគ្នា បាទ។

**ស៖** សំណួរខ្ញុំអម្បាញ់មិញហ្នឹងខុសពីនេះបន្តិច ខ្ញុំសួរលោកថាតើលោកទទួលបញ្ជាដោយផ្ទាល់ពីអ្នកណាដែរ ថាជានិច្ចកាលហ្នឹង ពីប្រធានកងរបស់លោកម្តង ឬក៏មានអ្នកផ្សេងទៀត ដែលដាក់បញ្ជាមកលោកដែរ?

**ឆ៖** បាទ ពេលណាដែលអវត្តមានប្រធានកង គឺខ្ញុំអនុកងត្រូវទទួលបន្ទុក ប៉ុន្តែពេលណាដែលនៅទាំងអស់គ្នា គឺត្រូវទទួលរួមគ្នា។

**ស៖** នៅពេលដែលប្រធានកងរបស់លោកអវត្តមាននោះ តើលោកត្រូវនិយាយជាមួយអ្នកណា ពិភាក្សាជាមួយអ្នកណា នៅពេលដែលលោកត្រូវការសេចក្តីសម្រេចពីលើនោះ ក្នុងករណីដែលមានបញ្ជាមកពីប្រធានវរសេនាតូចជាដើមនោះ ករណីអវត្តមានគាត់ ហើយត្រូវការពិភាក្សាអីនោះ ពិភាក្សាជាមួយអ្នកណា?

**ឆ៖** បាទ គឺនៅសមាជិកម្នាក់ទៀត។

**ស៖** ខ្ញុំយល់ចម្លើយរបស់លោកមិនច្បាស់ទេ។ លោកនិយាយអម្បាញ់មិញថា មានសមាជិកម្នាក់ទៀត។ ខ្ញុំយល់មិនច្បាស់ទេ លោកអាចបញ្ជាក់បានទេ លោកចង់និយាយមានន័យយ៉ាងម៉េចដែរ សមាជិកហ្នឹង?

**ឆ៖** បាទ ក្នុងមួយកងតូចគឺមានអ្នកទទួលខុសត្រូវបីនាក់ មានប្រធាន អនុប្រធាន និងសមាជិកម្នាក់។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថានៅពេលដែលប្រធានកងរបស់លោកអវត្តមាន លោកធ្វើសេចក្ដីសម្រេចដោយពិគ្រោះជាមួយនឹងសមាជិកដែលជាអ្នកធ្វើការជាមួយលោកដែរ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[១០:៥៥:១៨]

**ស៖** តើកាលនោះ ប្រធានកងនោះគាត់អវត្តមានយូរ ឬក៏គាត់ធ្វើការនៅលើការដ្ឋានហ្នឹង នៅទំនប់ហ្នឹងរាល់តែថ្ងៃដែរ ពេញមួយថ្ងៃដែរ?

**ឆ៖** បាទ ជួនកាលគេហៅគាត់ទៅប្រជុំ ហើយអវត្តមាន អាល័យតែទៅប្រជុំជំនួសដោយអនុប្រធាន។

**ស៖** តើលោកធ្លាប់អវត្តមានដែរឬទេ? ឬក៏រៀងរាល់ថ្ងៃ លោកធ្វើការនៅលើការដ្ឋានហ្នឹងរហូត?

**ឆ៖** បាទ មានធ្លាប់អវត្តមានខ្លះ។

**ស៖** នៅពេលដែលលោកអវត្តមាន តើអ្នកណាជាអ្នកទទួលបន្ទុកបន្តពីលោក ដើម្បីគ្រប់គ្រងការងារបន្ត? ចង់និយាយថា មានអ្នកដែលធ្វើការនៅក្រោមបង្គាប់លោក។ អ៊ីចឹងពេលលោកអវត្តមានអ្នកណាជំនួសលោក?

**ឆ៖** បាទ ពេលខ្ញុំអវត្តមាន គឺមានមេកងអ្នកជំនួស។

**ស៖** លោកបាននិយាយអំពីផែនការដែលត្រូវបំពេញឲ្យបានដោយពលករ។ អ៊ីចឹង ខ្ញុំសួរលោកថា តើលោកធ្វើយ៉ាងម៉េចដែរ ដើម្បីត្រួតពិនិត្យឲ្យដឹងថា អ្នកធ្វើការនោះបានបំពេញផែនការគ្រប់គ្រាន់ត្រឹមត្រូវ តើការងារហ្នឹងធ្វើយ៉ាងម៉េចដែរដើម្បីឲ្យដឹង?

**ឆ៖** បាទ គឺគេមានកាត់ដើមឫស្សីធ្វើជាម៉ែត្រ ហើយវាស់ ក្នុង១ម៉ែត្រគូប បើអ្នកជីកបណ្ដោយ២ម៉ែត្រ ទទឹងកន្លះម៉ែត្រ។ បើអ្នកជីកចុះទៅក្រោមគឺ ១ម៉ែត្របួនជ្រុង គឺគេវាស់នឹងឫស្សី។

**ស៖** ហើយលោកក៏បានឆ្លើយផងដែរកាលពីម្សិលមិញថា នៅពេលដែលធ្វើការមិនគ្រប់ផែនការនោះទេ ក្នុងឋានៈលោកជាអនុប្រធាននោះ លោកជួយធ្វើឲ្យចប់ផែនការ ជួយអ្នកធ្វើការហ្នឹង ដើម្បីឲ្យបំពេញផែនការបានចប់។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកជួយគេរបៀបម៉េចដែរ នៅពេលដែលគេ

បំពេញផែនការមិនបាន?

**ឆ៖** បាទ ពេលនោះ គឺបើទៅទាំងអស់គ្នា ប្រធានជួយក្រុមទី១ អនុប្រធានជួយក្រុមទី២ សមាជិកម្នាក់ជួយក្រុមទី៣។ ហើយនៅក្នុងក្រុមនោះ បើអ្នកណាទន់ខ្សោយជាងគេ គាត់រែកទៅវាហត់ វាលំបាកខ្លាំង គឺត្រូវជួយអ្នកហ្នឹង។

**ស៖** កាលពីម្សិលមិញ លោកបាននិយាយពីការធ្វើការងារពេលយប់ ហើយបកប្រែជាភាសាបារាំងនោះមិនសូវច្បាស់ អ៊ីចឹងខ្ញុំសុំឲ្យលោកជួយបំភ្លឺ គឺលោកបាននិយាយអំពីករណីបួន លោកនិយាយអំពីករណីមួយ គឺថាម៉ោងដប់បួនកន្លះ--

[១០:៥៩:០៣]

**អ្នកបកប្រែ៖**

លោកប្រធានសុំឲ្យលោកមេធាវីនិយាយម្តងទៀតលោកប្រធាន ព្រោះអីអ្នកបកប្រែតាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីនិយាយម្តងទៀត សូមឲ្យអ្នកបកប្រែបានស្តាប់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសុំនិយាយឡើងវិញម្តងទៀត។ ម្សិលមិញ គឺលោកបាននិយាយអំពីករណីមួយភាគបួនមានពាក្យ ម៉ោងប្រាំពីរល្ងាច ដល់ម៉ោងប្រាំបីល្ងាច។ មួយទៀត ពីម៉ោងដប់យប់ ដល់ម៉ោងមួយព្រឹក ហើយមួយទៀត ពីម៉ោងមួយដល់ម៉ោងបីព្រឹក ហើយវេនមួយទៀត ពីម៉ោងបីព្រឹកដល់ម៉ោងប្រាំព្រឹក។ លោកនិយាយពីវេនធ្វើការចំនួនបួន។ អ៊ីចឹង ខ្ញុំចង់សួរលោកថា តើអ្នកដែលធ្វើការនៅក្នុងវេនទាំងបួននេះ ជាក្រុមដដែលទេ ឬក៏មានក្រុមផ្សេងៗគ្នាដែលធ្វើការនៅក្នុងវេនទាំងបួននេះ? អ៊ីចឹង តើខ្ញុំសួរហ្នឹងលោកយល់ច្បាស់ទេ? គឺថាអ្នកដែលធ្វើការពីម៉ោងប្រាំពីរយប់ ដល់ម៉ោងដប់យប់នោះ ជាមនុស្សដដែលដែលធ្វើការបន្តទៀតពីម៉ោងដប់យប់ដល់ម៉ោងមួយភ្លឺនោះ? ឬក៏ពីក្នុងវេនមួយៗហ្នឹង អ្នកធ្វើការសុទ្ធតែមនុស្សក្រុមផ្សេងគ្នាទាំងអស់ទេ?

**លោក កាន ថុល៖**

**ឆ៖** បាទ គឺក្នុងមនុស្សនៅកងតែមួយ បាទ។ ឧទាហរណ៍ ក្រុមទី១ ចុះម្តងពីម៉ោងប្រាំពីរយប់ ដល់ម៉ោងដប់ គឺក្រុមទី២សាង សាងពីម៉ោងដប់ ដល់ម៉ោងមួយបាទ។ ដល់ក្រុមទី២ សាងម៉ោងមួយ បាទគឺក្រុមទី៣ សាងពីម៉ោងមួយ ដល់ម៉ោងបី។ បាទ ពេលនេះ វាដល់ក្រុមពេលល្ងាចវិញ។

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបំភ្លឺ ពីព្រោះថា កាលដែលលោកឆ្លើយលើកមុនហ្នឹងមិនសូវច្បាស់ ឥឡូវនេះច្បាស់ហើយ សូមអរគុណ។ លោកក៏បាននិយាយផងដែរអំពីរបៀបបែងចែកក្រុមរបស់លោក ជាពិសេសទាក់ទងនឹងរបបអាហារ។ លោកនិយាយថាមានមនុស្សម្នាក់ដែលទទួលបន្ទុកក្នុងការធ្វើម្ហូប ចុងភៅ។ អ៊ីចឹង សំណួរទី១ ខ្ញុំសួរថា តើស្បៀងអាហារដែលគេធ្វើម្ហូបសម្រាប់អ្នកធ្វើការទាំងអស់ហ្នឹងបានមកពីណាដែរ?

**ឆ៖** បាទ អង្ករ ដំបូងបើកចេញពីគេហៅថាសេដ្ឋកិច្ចស្រុក ទាំងម្ហូប ទាំងអាហារបន្លែបង្ការសព្វមុខ។ ក្រោយមកទៀត គឺបើកចេញពីកន្លែងតំបន់។ បាទ គេហៅថាចល័តតំបន់ហ្នឹង គឺគេមានឃ្លាំងមួយសម្រាប់ចល័តតំបន់នោះគឺមានឃ្លាំងមួយ បាទគឺបើកតាមហ្នឹង។

[១១:០៣:៤៥]

**ស៖** លោកបាននិយាយថា ដំបូងមកពីស្រុក បន្ទាប់មកទៀតមកពីតំបន់។ អ៊ីចឹងក្នុងរយៈពេលពីរខែដែលលោកធ្វើការនៅទំនប់ហ្នឹង តើលោកមានចាំថា ពេលណាដែលស្រុកជាអ្នកចែកឱ្យ ហើយពេលណាដែលតំបន់ជាអ្នកចែកឱ្យ?

**ឆ៖** បាទ ខ្ញុំពុំចាំថ្ងៃខែទេ ប៉ុន្តែចាំថា រយៈពេលលើកមួយខ្សែត្រៀមនោះ គឺបើកចេញពីស្រុកតែដល់ចូលខ្សែត្រៀមទី២ គឺលើកដំណាក់ទៅមួយកន្លែងទៀត គឺបើកចេញពីតំបន់។

**ស៖** លោកក៏បាននិយាយផងដែរថាមានមនុស្សម្នាក់ដែលទទួលបន្ទុកខាងរកត្រី បើសិនជាខ្ញុំយល់ចម្លើយលោកមិនខុសទេនោះ។ អ៊ីចឹង លោកអាចជម្រាបជូនតុលាការបានដែរឬទេថា អ្នកណាជាអ្នកសម្រេចថាឱ្យមានមនុស្សម្នាក់ដើម្បីទៅរកត្រីដើម្បីមកធ្វើម្ហូបសម្រាប់ឱ្យក្រុមលោកហូបចុកនោះ?

**ឆ៖** បាទ នោះគឺគេចាត់តាំងពីថ្នាក់លើមក បាទ គឺថាក្នុងមួយកង គឺឱ្យមានមនុស្សម្នាក់ជួយរកត្រី បើរកត្រីបានហើយ ថ្ងៃណាក៏ជួយទៅបោចវល្លិ៍ ឬក៏រពាក់មកជួសជុលបង្គី។

**ស៖** ពេលដែលលោកនិយាយថា ថ្នាក់លើថា ឱ្យអ្នកសម្រេចហ្នឹង អ៊ីចឹងលោកអាចបញ្ជាក់បានទេថា អ្នកណាដែរជាប្រធានកង ឬក៏ជាប្រធានវរសេនាតូច អ្នកដែលសម្រេចហ្នឹង?

**ឆ៖** បាទ ពេលនោះ គឺខ្ញុំមិនបានដឹងថាអ្នកណាជាអ្នកសម្រេចទេ ប៉ុន្តែគឺមេកងគាត់ទៅប្រជុំគាត់ថាឱ្យម្នាក់ទៅរកត្រី។ បាទ គឺឮ បានដឹងពិតប្រាកដ។

**ស៖** លោកបាននិយាយថានៅក្នុងភូមិរបស់លោកនោះ បើខ្ញុំយល់មិនច្រឡំទេ គឺថាលោកនិយាយថាបដិវត្តន៍បានទៅដល់ទៅនោះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយទេ។ អ៊ីចឹងខ្ញុំចង់សួរសំណួរមួយចំនួន

មុនរបបកម្ពុជាប្រជាធិបតេយ្យ និងមុនពេលដែលខ្មែរក្រហមចូលទៅដល់នៅទីនោះ។ លោកបាននិយាយអំពីគ្រូខ្មែរជាច្រើនដង ថ្នាំបុរាណ។ អ៊ីចឹងសំណួរខ្ញុំទី១ គឺចង់ដឹងថា នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើនៅក្នុងភូមិរបស់លោកនុំងមានពេទ្យដែរឬទេ? តើ ឬក៏រាល់ដងពេលដែលមានជំងឺឈឺថ្កាត់អីនោះ ទៅរកតែគ្រូខ្មែរទេ ថ្នាំបុរាណទេ?

**ឆ៖** បាទ កាលមុនឆ្នាំ៧៥ នៅភូមិរបស់ខ្ញុំមានពេទ្យ ហើយក៏មានគ្រូខ្មែរដែរ អ្នកខ្លះទៅក៏គេទៅគ្រូខ្មែរ អ្នកខ្លះក៏មកពេទ្យ ប៉ុន្តែពេទ្យនោះពុំមានមណ្ឌល ពុំមានកន្លែងទេ គឺនៅតាមផ្ទះ។

[១១:០៨:០៨]

**ស៖** ចុះអ្នកដែល គ្រូខ្មែរនោះជាអ្នកដែលអ្នកចេះអក្សរដែរ ចង់និយាយថាគាត់ជាអ្នកចេះដឹងដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ គឺលោកគ្រូខ្មែរនោះ គឺគាត់បានចេះ បាទចេះបាលី។

**ស៖** លោកផ្ទាល់ហ្នឹង តើលោកធ្លាប់ទៅពឹងពាក់គ្រូខ្មែរហ្នឹងដែរឬទេ មុនឆ្នាំ១៩៧៥ហ្នឹង?

**ឆ៖** បាទ ជួនកាលខ្ញុំទៅរកពេទ្យ តែបើថ្ងៃណាគេអត់នៅ គឺខ្ញុំទៅរកគ្រូខ្មែរ។

**ស៖** ឥឡូវខ្ញុំត្រឡប់ចូលមកនិយាយអំពីរយៈពេលក្រោយឆ្នាំ១៩៧៥ គឺថាពីពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មវិញម្តង។ លោកបាននិយាយថា លោកបានចូលរួមប្រជុំមួយចំនួន សហភាតារបស់ខ្ញុំគាត់បាននិយាយអំពីសុន្ទរកថារបស់ តាញឹម ដែលគាត់បានថ្លែងនៅក្នុងកិច្ចប្រជុំមួយក្នុងចំណោមកិច្ចប្រជុំទាំងអស់នោះ។ អ៊ីចឹងខ្ញុំសួរលោកថាតើក្នុងកិច្ចប្រជុំហ្នឹងគេមានធ្លាប់និយាយអំពីលោក អំពីមូលហេតុនៃការលើកទំនប់ហ្នឹងដែរឬទេ? ថាគេលើកទំនប់ហ្នឹងដើម្បីអ្វីដែរ?

**ឆ៖** បាទ គឺខ្ញុំបានឮថា លើកទំនប់អាងទឹកត្រពាំងថ្មនេះដើម្បីធ្វើធារាសាស្ត្រ។

**ស៖** លោកបានឆ្លើយថា លោកនៅតំបន់ហ្នឹងរហូត។ តើលោកចាំដែរឬទេថា មុនឆ្នាំ១៩៧៥នោះ តើមានគ្រោះរាំងស្ងួតដែរឬទេ មុនឆ្នាំ១៩៧៥? លោកមានចាំទេ?

**ឆ៖** បាទ គឺមានរាំងស្ងួតខ្លះៗដែរ។

**ស៖** ហើយជាក់លាក់តែម្តងនោះ តើលោកមានចាំរយៈពេលមួយដែលតំបន់លោកនោះមានគ្រោះរាំងស្ងួតនៅក្នុងឆ្នាំ១៩៧៤ ដែរឬទេ?

[១១:១១:៤៥]

**ឆ៖** បាទ ខ្ញុំពុំបានចាំទេ។

**ស៖** លោកនៅទីនោះរហូតក្រោយដែលសង់ទំនប់ហ្នឹងចប់ហើយនោះ តើលោកនៅទីនោះដែរ។ អ៊ីចឹងខ្ញុំសួរថា ពេលដែលធ្វើទំនប់ចប់ហើយ តើលោកមានសង្កេតឃើញថា ការប្រកបរបរកសិកម្មហ្នឹងមានភាពប្រសើរឡើងទេ ក្រោយពីពេលដែលធ្វើទំនប់ហ្នឹងហើយមានធារាសាស្ត្រហើយហ្នឹង?

**ឆ៖** បាទ ក្រោយពីការធ្វើទំនប់ហើយ ឃើញថានៅក្នុងអាងទឹកត្រពាំងថ្មនេះ សម្បូរទៅដោយត្រី ហើយក្រោមអាងត្រពាំងថ្មនេះក៏បានធ្វើស្រែ ពុំសូវដែលស្កកទេ។

**ស៖** ហើយត្រីនោះគេនេសាទហ្នឹង ដើម្បីជាប្រយោជន៍ដល់ប្រជាជន ឬក៏យ៉ាងណា?

**ឆ៖** បាទ គឺគេនេសាទដើម្បីជីវភាពផង គ្រាន់បានលក់ដូរខ្លះផង។

**ស៖** ឥឡូវខ្ញុំសូមចូលមកនិយាយអំពីចំណុចមួយចំនួនដែលបានលើកឡើងដែល -- នៅពេលដែលលោកចៅក្រម ឡាវ៉ែន៍ សួរលោក ៗបាននិយាយថា លោកចេះតែឮគេនិយាយតៗគ្នាទាក់ទងនឹងជនជាតិវៀតណាម។ អ៊ីចឹងសំណួរទី១ របស់ខ្ញុំៗចង់ដឹងថា តើរូបលោកផ្ទាល់នោះលោកធ្លាប់ឃើញគេចាប់វៀតណាមណាម្នាក់ដែរឬទេនៅលើទំនប់ត្រពាំងថ្មនោះ?

**ឆ៖** បាទ ខ្ញុំមិនដែលឃើញទេ។

[១១:១៤:១៤]

**ស៖** តើលោកធ្លាប់ឃើញ ក្រោយមកឃើញមានគេចាប់វៀតណាម ឬក៏សម្លាប់វៀតណាមដែរឬទេនៅលើទំនប់ត្រពាំងថ្មនោះ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** តើក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩ គឺរបបកម្ពុជាប្រជាធិបតេយ្យនោះ តើលោកធ្លាប់ដឹងថាមានជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមដែរឬទេ?

**ឆ៖** បាទ មិនដឹង។

**ស៖** លោកឆ្លើយទៅនឹងសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ ដដែលទាក់ទងទៅនឹងកងករណី។ អ៊ីចឹងសំណួរទី១ របស់ខ្ញុំនោះ ខ្ញុំចង់ដឹងថា តើនៅក្នុងកងរបស់លោកដែលមានសមាជិក ១០០នាក់នោះ តើមានកងករណីដែរឬទេនៅក្នុងកង១០០ របស់លោកហ្នឹង?

**ឆ៖** បាទ ពុំមានទេ។ កងករណីហ្នឹង គឺគេដាក់ទៅកន្លែងផ្សេង។

**ស៖** តើលោកធ្លាប់ឃើញ ជួបប្រទះនឹងករណីដែរឬទេ នៅលើការដ្ឋានការងាររបស់លោកនោះ?

**ឆ៖** បាទ ខ្ញុំពុំដែលបានឃើញកងករណីកំពុងតែធ្វើការនុ៎ង គឺមិនបានឃើញទេ។

**ស៖** អ៊ីចឹងបើខ្ញុំមិនច្រឡំទេ គឺថាលោកគ្រាន់តែឮគេនិយាយពីកងករណីនេះទេ លោកមិនដែលបានឃើញដោយផ្ទាល់ភ្នែកទេ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតមែន។

[១១:១៦:៣១]

**ស៖** ហើយអ៊ីចឹងបើសិនជាលោកបានត្រឹមតែឮហ្នឹង លោកឮពីអ្នកណាដែរ?

**ឆ៖** បាទ ឮគេនិយាយទូទៅ បាទគេថាកងករណីៗនោះ គឺលើកដីនៅម្តុំត្រង់នោះ ប៉ុន្តែនៅឆ្ងាយគ្នា បាទ ពុំដែលឃើញ។

**ស៖** តាមរយៈចម្លើយរបស់លោកហ្នឹង ខ្ញុំយល់ថា នៅក្នុងកងករណីនេះ មានអ្នកដែលខ្វាក់មាន់អ៊ីចឹងលោកចង់និយាយថា នៅក្នុងកងករណីហ្នឹង គឺថាមានតែអ្នកខ្វាក់មាន់ទេ ឬក៏កងករណីនេះមិនមែនមានន័យតែប៉ុណ្ណឹងទេ គឺអ្នកធ្វើការនោះ អាចមានអ្នកខ្លះមិនខ្វាក់មាន់អី អ្នកផ្សេងដែរ?

**ឆ៖** បាទ រឿងនោះខ្ញុំពុំបានដឹង។

**ស៖** អ៊ីចឹងអម្បាញ់មិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួរលោកចៅក្រម ឡាវែន៍ នោះគឺថាលោកឆ្លើយតាមដែលលោកបានឮតពីគេដែរឬទេ ហើយរូបលោកផ្ទាល់ហ្នឹង មិនដឹងថា កងករណីនេះយ៉ាងណាទេ ហើយក៏មិនដឹងថាកងករណីហ្នឹងធ្វើការរបៀបណាដែរ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណ ដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ ឥឡូវខ្ញុំសូមផ្តល់វេទិកាទៅលោកមេធាវី គង់ សំអុន ដើម្បីសួរបន្តទៀត។ ខ្ញុំគិតថា យើងៗ -- បើតាមយើងដកពេលវេលាដែលលោកចៅក្រម ឡាវែន៍ គាត់បានសួរអម្បាញ់មិញនេះ អ៊ីចឹងគឺថាម៉ោងសួររបស់យើងហ្នឹង គឺថាក្រោយអាហារថ្ងៃត្រង់ហើយហ្នឹង គឺយើងមានដល់ទៅ៤០នាទីទៀត។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ លោកចៅក្រម?

**ប្រធានអង្គជំនុំ៖**

ពិតជាត្រឹមត្រូវអ៊ីចឹងហើយ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន មានសំណួរ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំប្រហែលជាមិនត្រូវការពេលវេលាច្រើនទេ សួរខ្លីទេទៅលើសាក្សី ចំពោះសំណួរដែលនៅសល់បន្តិចបន្តួច។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំចង់បញ្ជាក់លោកសាក្សី កាន ថុល។ សូមជម្រាបសួរ! ខ្ញុំចង់សួរបញ្ជាក់ទៅលើទីតាំងដែលលោកធ្វើការពិតប្រាកដ។ អម្បាញ់មិញ ខ្ញុំបានស្តាប់ឮថា លោកមានការងារហ្នឹង ហាក់ដូចជាមានការផ្លាស់ប្តូរពីទីតាំងជាក់លាក់ នៅលើខ្នង -- នៅលើទំនប់ត្រពាំងថ្មនេះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ថា កន្លែងណាជាក់លាក់ដែលលោកធ្វើការជីកទំនប់ហ្នឹង? លោកអាចបញ្ជាក់បានទេ?

[១១:២០:០១]

**លោក កាន ថុល៖**

**ឆ៖** បាទ ជំហានដំបូង គឺកន្លែងដែលខ្ញុំនៅគឺខាងលិច កូនត្រចៀកអាងត្រពាំងថ្ម បាទ។ ទី២ បានផ្លាស់កន្លែងទៅនៅគេហៅថា "ត្រពាំងក្រចាប់" នៅក្នុងផ្ទៃអាងត្រពាំងថ្ម នៅខាងក្នុង។ ប៉ុន្តែទៅលើកខាងក្រៅ។ ហ្នឹងគឺពីរទីតាំង។ នេះជំហានដំបូង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីចម្ងាយពីកន្លែងទី១ ទៅកន្លែងទី២ ហ្នឹងចម្ងាយពីគ្នាប៉ុន្មានដែរ?

**ឆ៖** បាទ ពីកន្លែងទី១ ទៅកន្លែងទី២ ប្រហែលជា ២,៥គីឡូ។

**ស៖** បាទ សូមអរគុណ។ ចុះបើធៀបទៅនឹងទំនប់ត្រពាំងថ្មទាំងមូលតែម្តង តើលោកស្ថិតនៅចំផ្នែកខាងណា? ចំកណ្តាល ឬក៏ចំចុងខាងណាមួយ?

**ឆ៖** បាទ សូមបញ្ជាក់ម្តងទៀត។

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់ឲ្យលោកប្រៀបធៀបទៅលើខ្នងទំនប់ ឬក៏ប្រវែងទំនប់ត្រពាំងថ្មទាំងមូល តើលោកធ្វើការនៅចំចំណុចត្រង់ណានៃទំនប់នោះ ពាក់កណ្តាល ឬក៏ចុងខាងលិច ឬក៏ចុងខាងកើតនៃទំនប់ជាដើម?

**ឆ៖** បាទ គឺនៅចំកៀកហ្នឹងគេហៅថា ស្ពានទី១។ ចម្ងាយពីក្រោមទំនប់ គឺ១០០ម៉ែត្រ។

**ស៖** បាទ សូមអរគុណ។ លោកដឹងអំពីការងារដែលលោកបានធ្វើហ្នឹងក្នុងផ្នែកនៃទំនប់ហ្នឹង តើប្រវែងប៉ុន្មាននៅក្នុងផ្នែកទី១ ដែលលោកនិងក្រុមរបស់លោកបានលើកក្នុងរយៈពេលដែលលោកធ្វើការហ្នឹង តាមសក្ខីកម្មរបស់លោក លោកបញ្ជាក់ថា លោកធ្វើការពីខែ០២ អាចខ្ទង់ថ្ងៃទី១០ ខែ០២ រហូតដល់មុនចូលឆ្នាំខ្មែរ គឺក្នុងខែ៤ ដូច្នេះគឺវាមានរយៈពេលប្រហែលជាពីរខែ។ ខ្ញុំចង់សួរថាក្នុងក្រុមរបស់លោកហ្នឹងលើកបានប្រវែងប៉ុន្មានម៉ែត្រដែរ ក្នុងក្រុម៣០នាក់ ឬក៏ក្រុម១០០នាក់របស់លោកហ្នឹង?

លោកអាចបញ្ជាក់ក្រុមណាមួយក៏បាន។

[១១:២៣:០៨]

**ឆះ** បាទ ជំហានទី១ គឺគេចាប់ផ្ដើមវាស់ឲ្យ។ ឧទាហរណ៍កម្លាំងយើង៣០នាក់ គឺគេវាស់ឲ្យបណ្ដោយ៣០។ បាទ នេះផ្អែកលើខ្នងទំនប់។ គ្នា១០០នាក់ គឺគេវាស់ឲ្យ ១០០ម៉ែត្រ។

**សះ** បាទ សូមអរគុណ។ ហើយក្នុងប្រវែង ៣០ម៉ែត្រ នៅលើខ្នងទំនប់នេះ តើក្រុមរបស់លោកត្រូវធ្វើការក្នុងរយៈពេលប៉ុន្មានដែរ?

**ឆះ** បាទ តាមខ្ញុំនៅចាំ គឺប្រហែលជាង ២០ថ្ងៃ។

**សះ** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់ឲ្យច្បាស់ទៅលើ ទំហំការងារដែលក្រុមរបស់លោកបានធ្វើជាពិសេសក្នុងកង៣០នាក់របស់លោក ដែលលោកមានតួនាទីជាអនុប្រធានកង។ តើប្រវែងសរុបនៃខ្នងទំនប់ក្នុងដំណាក់កាលទី១ ដែលលោកបានលើកហ្នឹងប្រវែងប៉ុន្មានម៉ែត្រ សម្រាប់ក្រុម៣០នាក់របស់លោកហ្នឹង?

**ឆះ** បាទ គឺជំហានទី១ គឺ៣០ម៉ែត្រ ហ្នឹងឯង។

**សះ** បាទ សូមអរគុណ។ ចុះដំណាក់កាលទី២?

**ឆះ** បាទ ដំណាក់កាលទី២ គឺទៅជួយក្រុមផ្សេង ដែលកន្លែងនោះគឺវាទំនាបជាងគេ។

**សះ** បាទ សូមអរគុណ។ លោកមានរង្វាស់ជាប្រវែងដែលអាចវាស់វែងបានពីទំហំការងារដែលក្រុមរបស់លោកជួយក្រុមផ្សេងនោះដែរទេ?

**ឆះ** បាទ មិនដឹងទេ។

**សះ** បាទ សូមអរគុណ។ ឥឡូវ ត្រឡប់មកដំណាក់កាលទី១ ដែលលោកបានបញ្ជាក់ថា ក្រុមរបស់លោកគ្នា៣០នាក់ បានធ្វើការនៅលើខ្នងទំនប់ដែលមានប្រវែង៣០ម៉ែត្រ ហើយលោកបានចំណាយពេល២០ថ្ងៃក្នុងក្រុមរបស់លោកដើម្បីធ្វើការនៅលើខ្នងទំនប់នោះ។ លោកអាចបញ្ជាក់បានទេថាខ្នងទំនប់កន្លែងទីតាំងដែលលោកធ្វើហ្នឹងមានកម្ពស់ប៉ុន្មាន? បាតក្រោមប៉ុន្មាន និងខាងលើប៉ុន្មានដែរ ក្នុងទីតាំងជាក់លាក់ដែលលោកធ្វើការ?

**ឆះ** បាទ កន្លែងដែលធ្វើការហ្នឹងគឺលើកកម្ពស់៥ម៉ែត្រ បាតក្រោមហ្នឹងពី ១៨ ទៅ ២០ម៉ែត្រ។

**សះ** បាទ ចុះបាតខាងលើ?

**ឆះ** បាទ ខ្នងលើ ១០ម៉ែត្រ។

[១១:២៧:៤៥]

**ស៖** លោកចាំពីការងារប្រចាំថ្ងៃរបស់លោកក្នុងក្រុមរបស់លោកថា ក្នុងមួយថ្ងៃលោកសម្រេចបានយ៉ាងដូចម្ដេចដែរទេ? មានផែនការដែលកំណត់ឱ្យត្រូវលើកនៅក្នុងទំហំដី ៣០ម៉ែត្រនៃទំនប់នេះដែរទេ?

**ឆ៖** បាទ សូមបញ្ជាក់ថា ក្នុងការលើកនេះ ពុំទៀងទាត់ ថ្ងៃណាមានកម្លាំងឈឺ ឧទាហរណ៍ ថ្ងៃណាឈឺបី, ថ្ងៃណាឈឺប្រាំ បាទកម្លាំងទៅលើកនោះគឺពុំបានគ្រប់ចំនួនទេ ហើយក៏មិនអាចប៉ាន់ស្មានថាក្នុងមួយថ្ងៃហ្នឹងបានប៉ុន្មានប្រាកដ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំឆ្លងទៅចំណុចមួយទៀត ទាក់ទងទៅនឹងសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ សួរលោកមុននេះអំពីការឈឺសតិអារម្មណ៍។ ខ្ញុំស្ដាប់ទៅហាក់ដូចជាមានចំណុចខ្វែងគ្នាចំពោះសក្ខីកម្មរបស់លោក ដែលដំបូងឡើយលោកបានឆ្លើយថា អ្នកណាដែលឈឺគេឱ្យនៅនឹងរោង ហើយមិនបានទៅធ្វើការទេ ក៏ប៉ុន្តែមានពេទ្យមកពិនិត្យ។ ក្នុងខណៈដែលពេទ្យមក ឃើញប្រឡែងគ្នាលេង ពេទ្យហ្នឹងរាយការណ៍ទៅថ្នាក់លើ អំពីថាអ្នកជំងឺហ្នឹង ថាឈឺ ប៉ុន្តែឃើញប្រឡែងគ្នាលេង។ អ៊ីចឹងលោកបញ្ជាក់ថា ការឈឺសតិអារម្មណ៍តាមការឱ្យនិយមន័យរបស់លោក ទៅតាមទស្សនៈរបស់ពេទ្យនោះ។ ក៏ប៉ុន្តែនៅពេលដែលលោកចៅក្រម ឡាវ៉ែន៍ គាត់សួរៗ មិនមែនទាក់ទងនឹងពាក្យថា ប្រឡែងគ្នាលេងទេ គឺពាក្យថា “និយាយគ្នា” ឬក៏ “និយាយគ្នាលេង” ហើយលោកក៏ឆ្លើយថា “បាទ ទទួលស្គាល់ថាហ្នឹងហើយ នៅពេលដែលពេទ្យមកឃើញនិយាយគ្នាលេង ហ្នឹងគេថាឈឺសតិអារម្មណ៍”។ អ៊ីចឹងចំណុចវាមានពាក្យខុសគ្នាមួយ គឺថាទី១ ពេទ្យដែលមកមើលឃើញប្រឡែងគ្នាលេង ហើយនិងទី២ ឃើញថានិយាយគ្នា ឬក៏និយាយគ្នាលេង។ អ៊ីចឹងសូមឱ្យលោកបញ្ជាក់មើលថាមួយណាពិតប្រាកដ? ប្រឡែងគ្នាលេង ឬមួយក៏គ្រាន់តែនិយាយគ្នា ហ្នឹងគេហៅថា “ឈឺសតិអារម្មណ៍”?

**ឆ៖** បាទគឺសុំបញ្ជាក់ថា ប្រឡែងគ្នាលេង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីខ្លឹមសារនៃពាក្យថា “ប្រឡែងគ្នាលេង” ហ្នឹងគេធ្វើម៉េចខ្លះបានទេ ពីព្រោះដោយសារនៅក្នុងអង្គសវនាការយើងនេះគឺមានចៅក្រមបរទេស ដែលលោកអាចមិនយល់ពីខ្លឹមសារនៃពាក្យថា “ប្រឡែងគ្នាលេង” នេះបាទ?

**ឆ៖** បាទ ពាក្យថា “ប្រឡែងគ្នាលេង”នោះ គឺបុគ្គលដែលនៅឈឺនោះ គឺឃើញមានការរកចៃ ឬក៏ចាក់ក្រឡេកគ្នាទៅវិញទៅមកបាទ។

**ស៖** បាទសូមអរគុណ។ លោកប្រធានខ្ញុំឃើញហួសម៉ោងហើយ ប៉ុន្តែខ្ញុំមានមួយសំណួរទៀត ដូច្នេះខ្ញុំចង់បញ្ចប់នៅពេលនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តបាទ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទសូមអរគុណ។ សំណួរមួយទៀតទាក់ទងទៅនឹងទឹកជំនន់នៅឆ្នាំ១៩៧៨ តើលោកចាំបានពីស្ថានភាពហ្នឹងទេ នៅតំបន់របស់លោក?

**លោក កាន ថុល៖**

**ឆ៖** បាទ នៅចាំបាន។

**ស៖** លោកអាចរៀបរាប់ពីស្ថានភាពទឹកជំនន់ពេលហ្នឹងបន្តិចមើលថា តើវាធ្ងន់ធ្ងរយ៉ាងម៉េច ប៉ះពាល់យ៉ាងម៉េចខ្លះ?

**ឆ៖** បាទ នៅឆ្នាំ៧៨ ទឹកធំ លិចខាងក្រោមទំនប់ដែលគេហៅថា កូនអាងហ្នឹង គឺបាក់អស់។ ស្រូវចាប់ពីទៅខាងលិចស្ពានទី១ ប្រហែលជា១គីឡូ គឺទឹកហូររាបទៅដូចកន្ទេល។

[១១:៣៣:២៥]

**ស៖** បាទ សូមអរគុណ។ តើពេលហ្នឹងវាមាន ការប៉ះពាល់ទៅដល់ស្បៀងអាហារនៅក្នុងតំបន់របស់លោកដែរទេ?

**ឆ៖** បាទ ត្រង់នោះ ខ្ញុំមិនដឹងទេ។

**ស៖** លោកអាចបញ្ជាក់ផលដំណាំផ្សេងនៅក្នុងភូមិ ឬក៏សង្កាត់របស់លោកដែលលោករស់នៅ ឬធ្វើការនោះបានទេ ថាវាមានការប៉ះពាល់យ៉ាងម៉េចដែរ នៅពេលដែលមានទឹកជំនន់ហ្នឹង?

**ឆ៖** បាទ ពេលមានទឹកជំនន់នៅខាងលើ គឺខាងដំណាំដាំដុះមិនសូវប៉ះពាល់ទេ គឺប៉ះពាល់តែខាងវាលឯនេះឯង។

**ស៖** "វាល" លោកចង់សំដៅទៅលើអ្វី ជាវាលស្រែ ឬក៏វាលយ៉ាងម៉េច?

**ឆ៖** បាទ គឺវាលនៅក្រោមអាងទឹកហ្នឹង។

**ស៖** បាទ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ជាវាលអ្វី លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ សុំសួរម្តងទៀត។

[១១:៣៥:០០]

**ស៖** បាទ មុននេះលោកឆ្លើយបញ្ជាក់ថា ទឹកជំនន់ហ្នឹងធ្វើឲ្យប៉ះពាល់ដល់វាលនៅខាងក្រោមអាងទឹកហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរថា តើវាលហ្នឹងជាវាលអ្វី? ជាវាលដែល -- ជាស្រែ ឬមួយជាៗវាលដែលជាព្រៃទេបាទ?

**ឆ៖** បាទ គឺវាលក្រោមអាងហ្នឹងគឺសុទ្ធតែវាលស្រែ។

**ស៖** លោកអាចចាំពីទំហំដែលធ្វើឲ្យខូចខាតស្រូវនៅខាងក្រោមទំនប់អាងហ្នឹងដែរទេ?

**ឆ៖** បាទ ពុំចាំទេ។

**ស៖** បាទ បើប្រៀបធៀបទៅនឹងបណ្តោយអាងទំនប់ត្រពាំងថ្មនេះ តើវាមានទំហំប៉ុនណាដែរដែលកាលទឹកជំនន់ហ្នឹងធ្វើឲ្យខូចខាតដល់ស្រូវនៅក្នុងខាងក្រោមអាងហ្នឹង?

**ឆ៖** បាទ ខ្ញុំពុំដឹងប្រៀបទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

សវនាការស្តាប់សក្ខីកម្មសាក្សី កាន ថុល ដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះអរគុណលោក កាន ថុល ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃនេះ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ សូមលោកមានសំណាងល្អ មានសេចក្តីសុខ សេចក្តីចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅវិញ។ អរគុណ។

ឥឡូវនេះដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-889។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាល

សវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-889 និងមេធាវីប្រឹក្សាសាក្សី ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោកសាក្សី តើលោកឈ្មោះអី?

**លោក ឡុត ស្ងួយ៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ឡុត ស្ងួយ។

**ស៖** លោកកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

**ឆ៖** ខ្ញុំកើតនៅឆ្នាំ មិនដឹងប៉ុន្មានផង ដាក់អាយុ៥៥។

**ស៖** តើលោកប្រកបមុខរបរធ្វើអី? សូមលោកឆ្លើយម្តងទៀត។

**ឆ៖** បាទ ខ្ញុំធ្វើស្រែចម្ការ។

**ស៖** ឪពុកបង្កើត និងម្តាយបង្កើតរបស់លោក ឈ្មោះអីដែរ?

**ឆ៖** ម្តាយបង្កើតរបស់ខ្ញុំឈ្មោះ ឡុត ណុក -- ណុប ខួន ម្តាយឈ្មោះ ណាប់ ខួន។ ឪឈ្មោះ ឡុត ណុក ។

**ស៖** ប្រពន្ធលោកឈ្មោះអី ហើយមានកូនប៉ុន្មាននាក់ដែរ?

**ផ៖** ប្រពន្ធខ្ញុំឈ្មោះ ដាំ រ៉េត មានកូនប្រាំមួយនាក់។

**ស៖** អរគុណ លោក ឡុត សួយ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីកាលពីព្រឹកមិញ បានបញ្ជាក់ថា តាមសមត្ថភាព និងលទ្ធភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើមែនពិតទេ?

**ផ៖** បាទ ខ្ញុំអត់បាន មិនដែលបានស្គាល់គេផង។

[១៣:៣៤:០៩]

**ស៖** អរគុណ។ ហើយថា លោកបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែកមុននឹងចូលមកនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ។ តើពិតជាអ៊ីចឹងទេ?

**ផ៖** បាទ ខ្ញុំបាទបានស្បថនៅមុខលោកតាអស់ហើយ បានមកចូលមកកន្លែងនេះ។

**ស៖** សូមអរគុណ។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោក។ ក្នុងឋានៈលោកជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក ឡុត សួយ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តហេតុ ឬហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគីសួរចំពោះលោក។ លោកយល់ទេ លោក ឡុត សួយ?

**ផ៖** បាទ។

**ស៖** លោកសាក្សី តើលោកដែលផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងពេលកន្លងមក? ហើយប្រសិនបើបានធ្វើ តើធ្វើប៉ុន្មានដង ធ្វើនៅពេលណា ធ្វើនៅកន្លែងណា?

**ឆ៖** ខ្ញុំបានធ្វើ ខ្ញុំបាននិយាយជាមួយគាត់បានពីរដង។

[១៣:៣៧:០៦]

**ស៖** ធ្វើនៅកន្លែងណាដែរលោក?

**ឆ៖** មួយនៅហ្នឹងឃុំព្រះនេត្រព្រះ ពីរមកនៅនេះឯង។

**ស៖** អរគុណលោក។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអានន្ធូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទ បានអានរួចហើយ និងការនៅហ្នឹង ការចងចាំពីសម័យមុន។

**ស៖** អរគុណលោក។ ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹងវាពិតជាត្រឹមត្រូវ វាស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** បាទ បានស្របគ្នា។

**ប្រធានអង្គជំនុំ៖**

អរគុណលោក។ ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិ ៩១ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ឡូត ស្វយ នេះមុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលបីវគ្គក្នុងការសួរដេញដោលទៅសាក្សីរូបនេះ។

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកចៅក្រម មេធាវីការពារក្តី។

[១៣:៣៩:២៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរសំណួរលោកនៅរសៀលនេះ។ ខ្ញុំតំណាងឲ្យការិយាល័យសហ

ព្រះរាជអាជ្ញា ខ្ញុំចង់ចាប់ផ្តើមសួរសំណួរមួយចំនួនតូចទាក់ទងទៅនឹងប្រវត្តិរូបរបស់លោក និងនៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យនៅក្នុងកិច្ចសម្ភាសន៍លោកក៏បានឆ្លើយប្រាប់ថា តើលោកបានក្លាយទៅជាកងទ័ពខ្មែរក្រហមដោយរបៀបណានោះ នៅពេលដែលលោកមានអាយុ១៥ឆ្នាំ? ខ្ញុំសួរចង់សួរថាតើហេតុបានជាលោកបានចូលរួមនៅក្នុងជួរកងទ័ពខ្មែរក្រហម?

**លោក ឡុត សួយ៖**

**ឆ៖** បាទ កាលពីអាយុ ១៥ឆ្នាំនោះ គេបានរើសខ្ញុំដាច់ខាត។ ខ្ញុំក៏មិនដឹងថាដាច់ខាតហ្នឹងយ៉ាងណាដែរ។ គេឲ្យតែលើកតែទំនប់ ជីកប្រឡាយ។ ឮថាដាច់ខាត់ ក៏លើកដៃហ្នឹងគេ។ បានគេរើសខ្ញុំធ្វើជាកងទ័ព ខ្ញុំមិនដឹងថាកងទ័ពហ្នឹងកងទ័ពយ៉ាងណាទេ។ ខ្ញុំក៏បានគេដឹកទៅកណ្តាលព្រៃ។ ល្ងាចឡើងក៏យំរកម៉ែ រកម៉ែ។

**ស៖** លោកបានប្រើពាក្យ “ដាច់ខាត” ហើយខ្ញុំចង់សួរទៅលោកឲ្យបញ្ជាក់បន្តិចមើល នៅពេលដែលលោកត្រូវបានគេជ្រើសរើសចូលក្នុងជួរកងទ័ពខ្មែរក្រហម តើគេមានប្រាប់លោកថាគេជ្រើសរើសយកមនុស្សដាច់ខាត់ដែរឬទេ? ហើយលោកមានសួរគេថា តើពាក្យថា “ដាច់ខាត” ថាម៉េចដែរនៅពេលដែលគេជួបលោក ហើយគេប្រើប្រាស់ពាក្យនេះ?

**ឆ៖** គេអត់បានប្រាប់ថាដាច់ខាតនោះយ៉ាងណាទេ ដែលចំណោមប្រជាពលរដ្ឋច្រើនកំពុងជីកទំនប់ ជីកប្រឡាយ គេរើសអ្នកដាច់ខាត។ ដល់ហើយប្រជាជនយើងដែលលើកទំនប់ ជីកប្រឡាយ ជួបការលំបាកខ្លាំងពេក មិនដឹងថាដាច់ខាតហ្នឹងយ៉ាងណាទេ។ ម្ល៉ោះហើយគ្រាន់តែមាននារីយុវជនយើងនេះឯងលើកដៃ បានគេ ដាច់ខាតទៅគេដឹកយកទៅទុកម្តុំ។ មិនដឹងថា ដាច់ខាត ហ្នឹងគេយកទៅធ្វើអីទេ។

**ស៖** នៅពេលដែលលោកត្រូវបានចាត់តាំងឲ្យធ្វើជាកងទ័ពខ្មែរក្រហម តើលោកថា តើលោកដឹងខ្លួននេះលោកជាកងទ័ពចំណុះឲ្យតំបន់ណា ស្រុកណា ភូមិភាគណា ឬក៏អង្គភាពយោធាមួយណាទេ?

[១៣:៤២:៤៧]

**ឆ៖** អត់ បានគេដឹកទៅ ក៏គេរៀបពួកខ្ញុំជានៅកងទ័ពតំបន់៥១៣នេះ ទាំងនារី ទាំងយុវជននៅតំបន់៥ យើងនេះ។

**ស៖** លោកនិយាយអំពីពាក្យលេខ៥១៣ ហ្នឹងជា តើជាកងវរសេនាតូចរបស់លោកមែនទេ?

**ឆ៖** ជាវរសេនាធំរួមគ្នា។ ខ្ញុំនៅវរសេនាតូច។

**ស៖** នៅពេលដែលគេបំបែកកងវរសេនាតូចរបស់លោក រួមទាំងកងរបស់លោក គឺថាត្រូវបាន

យកទៅដាក់នៅចំណុះទ័ពស្រុក តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ បានគេជ្រើសរើសអ្នក១៧មេសា ដែលដាច់ខាតចូលទ័ពនេះ បានគេរើសមកដាក់នៅកងស្រុក – ស្រុកភ្នំស្រុកយើង ហើយនិងស្រុកព្រះនេត្រព្រះ គេបំបែកជាពីរ។

**ស៖** នៅពេលដែលអតីតកងវរសេនាតូចរបស់លោកត្រូវបំបែកទៅ តើលោកនេះត្រូវយកទៅឲ្យចំណុះកងទ័ពស្រុកមួយណា?

**ឆ៖** ខ្ញុំត្រូវគេចំណុះស្រុក នៅស្រុកភ្នំស្រុក។

**ស៖** លោកចាំទេថា កងវរសេនាតូចរបស់លោកហ្នឹងត្រូវបានគេបំបែកនៅពេលណា? ហើយលោកត្រូវបានយកទៅដាក់ឲ្យចំណុះកងទ័ពស្រុកភ្នំស្រុកហ្នឹងនៅពេលណាដែរ?

**ឆ៖** គេបានបំបែកនៅក្នុងឆ្នាំ៧៥ យើង ពាក់កណ្ដាលឆ្នាំ៧៥នេះ បានបំបែកៗអ្នក១៧មេសានេះឲ្យទៅនៅតាមស្រុក។

[១៣:៤៥:៥៦]

**ស៖** ហើយលោកដឹងថាមានកងទ័ពប៉ុន្មាននាក់នៅក្នុងអង្គភាពថ្មីរបស់លោកនេះ? តើមានកងទ័ពប៉ុន្មាននាក់ដែលត្រូវបានគេចាត់តាំងទៅនៅក្នុងអង្គភាពកងទ័ពថ្មីចំណុះឲ្យស្រុកភ្នំស្រុកហ្នឹង?

**ឆ៖** មានចំនួន៩០នាក់ ដែលឈរជើងនៅដីខាងស្រុកនេះ។

**ស៖** ហើយអ្នកណាជាមេកងនៃកងទ័ពស្រុកដែលមានកងទ័ពចំនួន ៩០នាក់នុ៎ង?

**ឆ៖** មេកងធំនោះគឺលោក តាជុង និង -- លោកតាជុង គាត់ប្រធានកងធំ ហើយនិង តាណាក គាត់អនុកងធំ ក្ដាប់ស្រុកភ្នំស្រុក។

**ស៖** លោកសាក្សីនៅក្នុងកិច្ចសម្ភាសន៍របស់លោកៗ បានបញ្ជាក់ឈ្មោះមនុស្សម្នាក់ឈ្មោះ តាណាក តើ តាណាក មានតួនាទីជាអ្វី? ហើយ ជឿន នេះមានតួនាទីជាអ្វីនៅក្នុងជួរកងទ័ពស្រុកភ្នំស្រុកនោះ?

**ឆ៖** តាណាក គាត់ជាមេ -- គាត់ជារងកងធំ។

**ស៖** ដូច្នេះ ការចងចាំរបស់លោកនៅពេលថ្មីៗនេះ ជឿន គឺជាមេបញ្ជាការ ហើយ ណាក គឺជាអនុបញ្ជាការ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬអត់ទេ?

**ឆ៖** បាទ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកសំណួរខ្លះៗទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតនៅក្នុងតំបន់

របស់លោក គឺថាដែលកើតឡើងនៅពេលដែលខ្មែរក្រហមចូលកាន់អំណាចនៅថ្ងៃទី១៧ មេសា ១៩៧៥។ ហើយបើអាចសូមជម្រាបតុលាការនៅពេលដែលខ្មែរក្រហមចូលកាន់កាប់អំណាចនៅតំបន់របស់លោក។ តើមនុស្សប្រភេទណាដែលគេចាត់ទុកថាជាអតីតអ្នករដ្ឋការ ឬក៏ជាអតីតទាហាននៃរបបលន់ នល់?

[១៣:៤៩:០១]

**ឆ៖** ថ្ងៃ១៧ មករា នេះជា១ថ្ងៃរំដោះ បានមកនេះ គឺវាបានចូលក្នុងភូមិឃុំ ក៏វាបានចម្រាញ់អ្នកណាដែលមានបងប្អូនទាហានក៏វាចាប់យកទៅសម្លាប់ចោលអស់។ ពួកខ្ញុំកភ័យ បងប្អូនខ្ញុំសុទ្ធតែអ្នករៀន ខ្ញុំភ័យខ្លាចជាប់ខ្សែចង្វាក់ដល់ពួកខ្ញុំ ក៏បានគេរើសពួកខ្ញុំឱ្យទៅនៅចល័ត កងចល័តនេះ។

**ស៖** លោកចង់និយាយថា យ៉ាងម៉េចដែរនៅពេលដែលលោកចេញមកពីគ្រួសារអ្នករៀនសូត្រនោះ?

**ឆ៖** ពីព្រោះពួកវា ឱ្យតែអ្នកណាចេះអក្សរ គឺវាសម្លាប់ចោល។ វាទុកតែអ្នកល្ងង់។

**ស៖** តើអ្នកណាខ្លះនៅក្នុងក្រុមគ្រួសាររបស់លោក ដែលត្រូវចាត់ទុកថាជាបញ្ញវន្ត ឬជាអ្នករៀនសូត្រ?

**ឆ៖** គឺបងប្អូនខ្ញុំគេនៅតាមភូមិសព្វថ្ងៃ គេ១រៀនបាននៅថ្នាក់ទី១ ទី២ ក៏គេក៏មិនហ៊ានថាចេះថាដឹងទេ ថាល្ងង់ទាំងអស់គ្នា។

**ស៖** អ្នកណាដែលជាអ្នកដើរពិនិត្យមើល តាមដានពិនិត្យមើលថាប្រជាជនណា ជាប់ខ្សែ លន់ នល់ ជាប់អីអ៊ីចឹងនោះ?

**ឆ៖** អានុ៎ង ជារបស់របបប្រធានភូមិរបស់គេ គឺប្រធានភូមិដែលរំដោះរបស់គេចូលមក។

**ស៖** នៅពេលនុ៎ងនោះ តើលោករស់នៅក្នុងភូមិ ឃុំណាដែរ?

**ឆ៖** ខ្ញុំពេលនោះ រស់នៅ១ភូមិកំណើត នៅភូមិជើងវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ។

[១៣:៥១:៥៧]

**ស៖** លោកដឹងថាប្រជាជនដែលត្រូវគេចម្រាញ់ហ្នឹង ហើយគេរកឃើញថាជាប់ខ្សែរយៈជាមួយអ្នកដែលចេញមកពីរបប លន់ នល់ តើអ្នកទាំងអស់ហ្នឹង គេ១យកទៅណាទៅ?

**ឆ៖** ខ្ញុំឮតែគេថាយកទៅសម្លាប់ចោល១ មិនដឹងគេយកទៅឯណា ចាប់ទៅក៏បាត់១។

**ស៖** លោកដឹងថា ប្រជាជនណាម្នាក់នៅក្នុងភូមិ ឬក៏ឃុំរបស់លោកដែលជាអតីតទាហាន លន់ នល់ ឬក៏អ្នកកាន់ការនៅក្នុងរបប លន់ នល់ ហើយត្រូវបានគេយក ត្រូវ១បានគេនាំខ្លួនចេញទៅបាត់ទេ?

**ឆ៖** នៅក្នុងភូមិខ្ញុំ គេចាប់ប្រធានភូមិចាស់ ដូចជាខ្មោចមា រៀម បានគេចាប់យកទៅសម្លាប់ទាំងប្ដី ទាំងប្រពន្ធ។ អានុំងខ្ញុំនៅកូនក្មេងដែរ ដើរឃ្វាលគោ មិនទាន់គេបាននាំមកចល័តទេ។

**សៈ** នៅក្នុងចម្លើយរបស់លោក លោកបានរៀបរាប់ថា លោកបានចូលរួមនៅក្នុងជួរកងទ័ពដោយរបៀបណានោះ។ លោកបានឆ្លើយថា លោកត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកយាមនៅកន្លែងមួយឈ្មោះថា ចម្ការខ្នុរ នៅឯស្វាយស៊ីសុផុន។ នៅពេលហ្នឹង គឺថាគេឲ្យលោកទៅយាមផ្លូវ។ លោកចាំទេ នៅពេលហ្នឹង មានបញ្ជា ឬការណែនាំដែលលោកបានទទួលនោះ គឺការបញ្ជា និងការណែនាំដែលលោកទទួលបាននៅពេលដែលគេឲ្យលោកទៅយាមផ្លូវនៅឯចម្ការខ្នុរ? លោកចាំសេចក្ដីណែនាំ និងការបញ្ជានោះទេ?

[១៣:៥៤:១៧]

**ឆ៖** រយៈកាលដែលគេឲ្យពួកខ្ញុំមកយាមនៅ--

**លោក គង់ សំអុន៖**

លោកប្រធានសូម--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់មួយ និងធ្វើការជំទាស់ផងដែរ ទាក់ទងទៅនឹងខ្សែសំណួរដែលសហព្រះរាជអាជ្ញាអន្តរជាតិរងបានសួរទៅសាក្សីកន្លងមកនេះ ទាក់ទងនឹងបញ្ហាដែលធ្វើជាទាហាន ធ្វើការសម្លាប់ទាហានរបស់សាក្សី បាទទាហានរបប លន់ នល់ ហើយទី២ គឺភាពមិនច្បាស់លាស់ទៅលើអង្គហេតុពីរយៈពេលដែលសាក្សីឆ្លើយ គឺដំបូងសាក្សីបញ្ជាក់ថា ក្រោយថ្ងៃ ០៧ មករា ១៩៧៩។ នេះជាចំណុចមួយដែលអាចមានការភ័ន្តច្រឡំទៅលើពេលវេលាដែលសហព្រះរាជអាជ្ញារងអន្តរជាតិមិនបានសួរបញ្ជាក់ទៅលើចំណុចនេះ។ ហើយទី២ គឺទាក់ទងទៅនឹងអង្គហេតុដែលសាក្សីបានបញ្ជាក់នេះ គឺស្ថិតនៅតក្រៅវិសាលភាពនៃសំណុំរឿងដែលយើងកំពុងសវនាការនេះ ពីព្រោះវាមិនមែនជារឿងដែលយើងត្រូវលើកអំពីអង្គហេតុសម្លាប់ទាហានរបប លន់ នល់ ដែលកើតឡើងនៅស្រុកសិរីសោភ័ណ ឬនៅកន្លែងណាផ្សេងទេ។ ហើយយើងអាចត្រឡប់មកថា ទាក់ទងនឹងអង្គហេតុនៃការសម្លាប់ទាហាននេះ គឺអាចទាក់ទងទៅនឹងបរិបទនៃស្រុកត្រាំកក់ ឬក៏កន្លែងសម្លាប់នៅត្រាំកក់។

បាទ ដូច្នេះ ខ្ញុំសូមជំទាស់ទៅលើការលើកឡើងការតាំងសំណួររបស់សហព្រះអាជ្ញា។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធានអនុញ្ញាតឲ្យខ្ញុំឆ្លើយតបសង្ខេបទេ។ ទី១ គឺថា មិនមានសំណួរពាក់ព័ន្ធទៅនឹង ១៧ មេសា ១៩៧៥ ដោយសារថាសាក្សីនេះបានឆ្លើយលម្អិតច្បាស់លាស់ហើយថា គាត់ត្រូវបានជ្រើសរើសឲ្យធ្វើជាកងទ័ព។ ទី២ វាមានដំណាក់កាលមួយនៃសវនាការដែលពាក់ព័ន្ធទៅនឹងការបោសសម្អាតអតីតទាហាន លន់ នល់។ នេះជាប្រធានបទមួយ វិសាលភាពមួយដែលត្រូវបានជំទាស់តវ៉ាដោយមេធាវីការពារក្តី ដូច្នេះយើងខ្ញុំចង់បង្ហាញឲ្យឃើញថា នេះគឺជាគោលនយោបាយជាប្រព័ន្ធដែលបានអនុវត្តនៅទូទាំងរបបនោះតែម្តង។ ដោយសារតែគាត់នេះជាទាហានស្រុក គាត់មាន តាមបង្ហាញអំពីការកំណត់គោលដៅមកលើអតីតទាហានលន់ នល់ ហើយវាពិតជាជាប់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃសវនាការនេះ។

[១៣:៥៧:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបសង្ខេបទៅនឹងការលើកឡើងរបស់សហព្រះអាជ្ញា ឬក៏ចម្លើយរបស់គាត់នេះ។ តាមដែលខ្ញុំយល់ ការសម្រេចអំពីវគ្គ ហើយនិងវិសាលភាពនៃការជំនុំជម្រះពាក់ព័ន្ធនឹងការប្រព្រឹត្តមកលើអតីតមន្ត្រីរដ្ឋការ និងទាហានលន់ នល់ យើងដឹងថាវាមានទីតាំងជាក់លាក់បី ស្រុកត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម និងមន្ទីរសន្តិសុខស-២១។ ឥឡូវអ្វីដែលសហព្រះរាជអាជ្ញាកំពុងតែយោងនេះ គឺវាមិនពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលនិយាយថា ត្រូវនិយាយបញ្ហាបី ទី១ ការប្រព្រឹត្តមកលើអតីតទាហាន និងអ្នករដ្ឋការលន់ នល់ ហើយនិងមន្ទីរសន្តិសុខ។ ខ្ញុំមិនមានសេចក្តីសម្រេចនៅចំពោះមុខខ្ញុំទេ ដូច្នេះសូមជ្រាប។

**លោក ឌេល លីសាក់៖**

លោកប្រធាន គោលនយោបាយជាបញ្ហាមួយហើយដោយសារនេះជាគោលនយោបាយរបស់របបនោះ។ ហើយភស្តុតាងដ៏ច្បាស់លាស់របស់សហព្រះរាជអាជ្ញា គឺថានៅគ្រប់តំបន់ទាំងអស់នៃប្រទេសកម្ពុជា ទាហានលន់ នល់ ត្រូវបានប្រមូលផ្តុំហើយយកទៅសម្លាប់ចោល។ បញ្ហានេះ ត្រូវបាន

លើកឡើងនៅគ្រប់ដំណាក់កាលទាំងអស់នៃការជំនុំជម្រះ មិនមែនតែពាក់ព័ន្ធទៅនឹងទីតាំងជាក់លាក់នៃទីតាំងនេះទេ។

[១៣:៥៩:០៤]

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីផ្អាកសិន យើងនឹងសម្រេចអំពីបញ្ហានេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០០:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធការជំទាស់ដោយហេតុថា អ្នកធ្វើការនៅទំនប់ត្រពាំងថ្មពាក់ព័ន្ធនឹងការបោសសម្អាតដែលជានយោបាយទូទៅ។

សូមបន្តសំណួរសហព្រះរាជអាជ្ញា!

**លោក វិចទ័រ កូប៉េ៖**

សូមអធ្យាស្រ័យលោកប្រធាន ខ្ញុំទើបតែរកបានឯកសារអម្បាញ់មិញនេះឯង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីៗ យើងបានសម្រេចហើយ។ សូមលោកព្រះរាជអាជ្ញាបន្តសំណួរ។

**លោក វិចទ័រ កូប៉េ៖**

នេះគ្រាន់តែជាសំណើមួយសុំការបញ្ជាក់ឲ្យបាន គឺឯកសារE315 ទាក់ទងទៅនឹងអតីតរដ្ឋការរបប លន់នល់ ការអនុវត្តគោលនយោបាយនៅសហករណ៍ត្រាំកក់ ទំនប់១មករា មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ប្រហែលជាខ្ញុំយល់ច្រឡំ ទៅលើការអានឯកសារ E315, ERN គឺ 01024938--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី កូប៉េ តើវាជារឿងថ្មីឬ?

លោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីលើកឡើងរឿងថ្មី ឬក៏រឿងដដែលដែលអង្គជំនុំជម្រះបានសម្រេចអម្បាញ់មិញនេះហើយ?

[១៤:០២:២០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំចង់បញ្ជាក់ជូនថា អត្ថិភាពនៃគោលនយោបាយនេះ ត្រូវបង្ហាញនៅថ្នាក់ជាតិ ក៏ប៉ុន្តែការអនុវត្តគោលនយោបាយនេះ គឺជាកម្មវត្ថុនៃផ្នែកជាក់លាក់មួយដែលមាននៅក្នុងឧបសម្ព័ន្ធដែលលើកឡើងដោយមេធាវីការពារក្ដី។ ហើយយើងនិយាយអំពីការអនុវត្តគោលនយោបាយ។ ក៏ប៉ុន្តែអត្ថិភាពនៃគោលនយោបាយនេះគឺត្រូវតែបង្ហាញនៅថ្នាក់ជាតិ។

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញាបន្តសំណួរ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំបានសួរលោកអំពីពេលវេលាដែលគេចាត់តាំងឲ្យលោកធ្វើជាអ្នកយាមនៅចម្ការខ្នុរ ហើយនិយាយដោយចំនោះ ខ្ញុំចង់ដឹងថាតើ លោកបានទទួលការណែនាំពីថ្នាក់លើរបស់លោកទេទាក់ទងទៅនឹងអតីតទាហានលន់នល់ ជាដើម?

**លោក ឡុត សួយ៖**

**ឆ៖** ថ្នាក់លើគេបានឲ្យខ្ញុំយាមនៅតាមផ្លូវ មិនដឹងថាគេឲ្យយាមធ្វើអីទេ ឲ្យខ្ញុំអង្គុយតាមផ្លូវឮគេថាចម្ការខ្នុរៗ ខ្ញុំមិនដែលបានឃើញចម្ការខ្នុរទេ។ នៅយាមតែតាមផ្លូវចម្ការគ យើងនេះ។

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់ទាក់ទងទៅនឹងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវី តើលោកកត់សម្គាល់ ឬក៏ជំទាស់ បើជំទាស់លោកការជំទាស់តែម្ដងបាទ។

**លោក គង់ សំអុន៖**

បាទ ជាការកត់សម្គាល់ ដើម្បីឲ្យសហព្រះរាជអាជ្ញាសួរបញ្ជាក់ទៅលើទីតាំងច្បាស់លាស់ទាក់ទងនឹងចម្ការខ្នុរនេះ ព្រោះយើងអត់ដឹងភូមិសាស្ត្រ ថាតើចម្ការខ្នុរ ស្ថិតនៅភូមិ ឃុំ ស្រុក ឬក៏ខេត្តឬក៏តំបន់ណានៅក្នុងពេលដែលសាក្សីធ្វើការនោះ។ ដូច្នេះ សូមឲ្យបញ្ជាក់ទីតាំងឲ្យបានច្បាស់ដើម្បីខ្ញុំ

អាចធ្វើការជំទាស់ ឬក៏មិនជំទាស់បាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញាបញ្ជាក់ឲ្យបានច្បាស់លាស់របស់មេធាវីការពារលោក ខៀវសំផន។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសួរសាក្សី។ លោកសាក្សី សូមលោកប្រាប់តុលាការថាតើ ទីតាំងចម្ការខ្នុរនោះ ដែលគេចាត់តាំងឲ្យលោកយាមនោះ តើទីតាំងនោះស្ថិតនៅកន្លែងណា?

[១៤:០៥:00]

**លោក ឡុត សួយ៖**

**ឆ៖** ដែលគេឲ្យខ្ញុំយាមនោះ គេអត់ប្រាប់ថាយាមចម្ការខ្នុរទេ គ្រាន់តែគេប្រាប់ថាឲ្យទៅយាមតាមផ្លូវ ខ្ញុំក៏យាមតាមផ្លូវ។

**ស៖** ទីតាំងដែលបានលោកបានកំណត់អត្តសញ្ញាណ ហើយពិភាក្សានៅក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ដែលលោកបានបញ្ជាក់ថាចម្ការខ្នុរជាទីតាំងមួយ។ តើចម្ការខ្នុរនៅស្ថិតនៅកន្លែងណា?

**ឆ៖** ខ្ញុំឮតែគេថាចម្ការខ្នុរៗ ប៉ុន្តែខ្ញុំអត់ដែលបានឃើញ ឮគេថាចម្ការខ្នុរនៅស្វាយៗ ប៉ុន្តែពួកខ្ញុំនៅតែតាមទីក្រុង នៅតាមថ្នល់យើងផ្លូវទៅថ្មពួកយើងនេះ។

**ស៖** តើលោកនិយាយពីទីប្រជុំជន ឬក៏ទីក្រុងណា នៅផ្លូវកន្លែងណា?

**ឆ៖** នៅតាមផ្លូវផ្សារថ្មីយើង គេហៅថា "ផ្លូវចម្ការគ"ៗ។

**ស៖** តើលោកបានដឹងអំពីទីកន្លែងសម្លាប់មនុស្សទេ ដែលគេហៅឈ្មោះថា "ចម្ការខ្នុរ"នោះ?

**ឆ៖** ខ្ញុំអត់ដែលបានឃើញបានអីទេ។ ឮតែគេថាសម្លាប់ៗ ប៉ុន្តែមិនដែលបានឃើញទីតាំង មិនដឹងកន្លែងនោះធំប៉ុនណាអី ចម្ការខ្នុរនោះយ៉ាងណាមិនដែលឃើញ ឮតែឈ្មោះ។

**ស៖** ខ្ញុំនឹងពិនិត្យមើលនូវសំណួរមួយចំនួនដែលទាក់ទងទៅនឹងរយៈពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម។ លោកបានរៀបរាប់នៅក្នុងបទសម្ភាសន៍របស់លោកអំពីនៅភ្នំស្រុកដែលថាលោកជាកងឃោធា គេចាត់តាំងឲ្យលោកធ្វើជាអ្នកយាមនៅទំនប់ត្រពាំងថ្ម។ តើលោកអាចប្រាប់ខ្ញុំបានទេ តើធ្វើការជាអ្នកយាមនៅត្រពាំងថ្ម នៅការដ្ឋាននោះរយៈពេលប៉ុនណា? តើលោកនៅចាំឆ្នាំណា ខែណាទេ

ដែលគេចាត់តាំងឲ្យលោកធ្វើការនៅកន្លែងនោះ?

**ឆ៖** ដែលឲ្យខ្ញុំមកយាមនៅអាងត្រពាំងថ្មនោះ នៅក្នុងឆ្នាំ៧៦ មកយាមខ្លាចទំនប់វាបាក់ ហើយនិងហៅកងចល័តយើងលើកដីបំពេញ។

[១៤:០៨:២០]

**ស៖** តើលោកធ្វើការជាអ្នកយាមនៅត្រពាំងថ្មនោះអស់រយៈពេលប៉ុន្មាន?

**ឆ៖** នៅចំនួនប្រហែលយើងថាមួយខែ។

**ស៖** ខ្ញុំចង់ឲ្យលោកបំភ្លឺអំពីកំណត់ហេតុស្តាប់ចម្លើយសាក្សី តើលោកធ្វើការនៅត្រពាំងថ្មនៅពេលពីរខុសគ្នា ឬក៏ទៅធ្វើការនៅកន្លែងហ្នឹងជាអ្នកយាមតែម្តងទេ ឬក៏ទៅពីរដង ឬក៏ប៉ុន្មានដង?

**ឆ៖** ខ្ញុំនៅធ្វើការនៅអាងត្រពាំងថ្មតែម្តងទេ។

**ស៖** តើលោកបាននៅទីនោះទេ នៅពេលដែលគេបញ្ចប់ការសាងសង់ទំនប់នោះរួច តើលោកនៅប្រចាំការនៅឡើយទេ?

**ឆ៖** ដែលគេលើកអាងត្រពាំងថ្មនេះរួច ខ្ញុំនៅនោះឯង។

**ស៖** សូមលោកបញ្ជាក់ពីការចងចាំដ៏ច្បាស់របស់លោកដែលអាចទៅបាននោះ ថាតើនៅក្នុងឆ្នាំណា ឬក៏ខែណាដែលគេបញ្ចប់ការសាងសង់ទំនប់ការដ្ឋានត្រពាំងថ្ម?

**ឆ៖** លើកទំនប់អាងត្រពាំងថ្មបញ្ចប់នៅក្នុង ប្រហែលជាចុងឆ្នាំ៧៦ ចូល៧៧នេះឯង។

**ស៖** បាទ យើងនឹងត្រឡប់មកចំណុចនេះដើម្បីបញ្ជាក់ពីកាលបរិច្ឆេទម្តងទៀតលោកសាក្សី។ ឥឡូវនេះ យើងនិយាយអំពីការងាររបស់លោកដែលគេចាត់តាំងឲ្យធ្វើជាយោធា ជាអ្នកយាមនៅទីតាំងនោះ។ ថាតើមានយោធាប៉ុន្មានមកពីកងយោធាភ្នំស្រុកហ្នឹង គេយកមកប៉ុន្មាននាក់ឲ្យមកយាមនៅការដ្ឋានត្រពាំងថ្មនោះ?

**ឆ៖** គេឲ្យមកយាមអាងត្រពាំងថ្មនេះ គេឲ្យមកយាមក្នុងមួយក្រុម ១០នាក់។

**ស៖** តើមានកង ឬក៏ក្រុមប៉ុន្មានទៀតដែលថាអាចហ្នឹងគេចាត់តាំងឲ្យមកយាមក្រៅពីកងរបស់លោកដែលមានគ្នា ១០នាក់ហ្នឹង តើមានកងណាផ្សេងទៀតដែរឬទេ?

**ឆ៖** អត់មានកងណាទៀតទេ ពួកកងគេនៅតាមកន្លែងរបស់គេ។ ដកតែពួកខ្ញុំដែលនៅជិតអាងនោះ គេឲ្យមកយាម។

[១៤:១១:៥៥]

**សៈ** តើនៅក្នុងកងរបស់លោកដែលមានគ្នា១០នាក់ ប្រធានឈ្មោះអ្វី?

**ផៈ** ប្រធានក្រុមឈ្មោះ ប៉ាន។

**សៈ** តើ ប៉ាន គាត់ស្ថិតនៅក្រោមការបញ្ជារបស់អ្នកណា? អ្នកណាជាមេរបស់ ប៉ាន ហ្នឹង?

**ផៈ** ជាមេរបស់លោក ប៉ាន មានលោកតា ណាក។

**សៈ** តើលោកនិយាយយោងទៅរក តាណាក ហ្នឹងដែលថាជា អនុបញ្ជាការនៃកងយោធានៅភ្នំស្រុកឈ្មោះ តាណាក ហ្នឹង តើមែនឬទេ?

**ផៈ** បាទ ពិតមែនហ្នឹងឯង។

**សៈ** លោកជាសមាជិកនៅក្នុងកងយោធាភ្នំស្រុក តើលោកបានដឹងថាតើមានយោធាមកពីថ្នាក់តំបន់ត្រូវបានគេចាត់តាំងឱ្យមកឈរជើង ឬក៏យាមនៅអាងត្រពាំងនេះដែរឬទេ?

**ផៈ** ខាងកងទ័ពតំបន់គេអត់បានចុះមកយាមតាមស្រុកទេ គេនៅតាម នៅកន្លែងស្វាយ កន្លែងតំបន់របស់គេ ហើយនិងគេយាមតាមព្រំដែនរបស់គេ។

**សៈ** តើនៅក្នុងផ្នែកណានៃទំនប់ត្រពាំងថ្មដែលក្រុមលោកដែលមានគ្នា១០នាក់ គេចាត់តាំងឱ្យយាមនៅត្រង់ផ្នែកណា? ចំណុចណានៃទំនប់ហ្នឹង?

[១៤:១៤:១៦]

**ផៈ** ឱ្យពួកខ្ញុំនៅហ្នឹងកន្លែងកែងអាង ហៅស្ពានទី១នោះ ឱ្យនៅយាមហ្នឹង ឱ្យដើរធ្វើការទៅដល់ភូមិពន្លៃ ខ្លាចទំនប់វាបាក់ទឹក ខ្លាចវាបាក់។

**សៈ** តើអ្នកណាជាអ្នកទទួលបន្ទុកនៅការដ្ឋានទំនប់ត្រពាំងថ្ម ប្រធានគេឈ្មោះអ្វី?

**ផៈ** គេទទួលក្ដាប់រួមនៅក្នុងចល័តអាងត្រពាំងថ្មនោះ គឺលោកតា វ៉ាល់។

**សៈ** តើមុខតំណែងរបស់ តាវ៉ាល់ ហ្នឹងលោកចាំទេគាត់មានតំណែងជាអ្វី?

**ផៈ** គាត់មុខតំណែងរបស់គាត់ក្ដាប់ចល័តមួយក្នុងតំបន់៥ហ្នឹង។

**សៈ** តើ តាវ៉ាល់ ធ្លាប់ជាសមាជិកនៃកងយោធាតំបន់៥ ដែរឬទេ មុននឹងគេចាត់តាំងឱ្យគាត់ធ្វើជាប្រធានចល័តនៅទីនោះ នៅតំបន់៥នោះ?

**ផៈ** បាទ គាត់អតីតគាត់ពីដើមមិញ គាត់ជាប្រធានវរៈនៅតំបន់៥យើង។ បានដល់គេដកគាត់ពីតំបន់ -- ពីយោធានោះទៅឱ្យគាត់ក្ដាប់កងចល័តមួយតំបន់៥។ ដឹកនាំចល័តលើកទំនប់ ជីកប្រឡាយ។

**សៈ** តើលោកស្គាល់ តាវ៉ាល់ ដែរឬទេនៅពេលដែលគាត់នៅជាកងទ័ពតំបន់ ហើយនិងពេល

ដែលគាត់ក្លាយមកជាប្រធានកងចល័តតំបន់នោះ តើលោកស្គាល់គាត់ច្បាស់ក្នុងលក្ខណៈបែបណាដែរ?

**ឆ៖** ខ្ញុំស្គាល់គាត់ច្បាស់ ដែលខ្ញុំរស់នៅកងតំបន់ជាមួយគាត់។

**ស៖** តើមានពេលណាមួយនៅពេលដែលលោករស់នៅ ឬស្នាក់នៅក្នុងកន្លែងជាមួយគ្នាជាមួយនឹង តាវ៉ាល់ ដែរឬទេ?

**ឆ៖** មានកន្លែងដែលគាត់រើសខ្ញុំធ្វើកងដាច់ខាតនោះ បានគាត់យកពួកខ្ញុំទៅទុកជិតកន្លែងគាត់។

**ស៖** នៅក្នុងបទសម្ភាសន៍របស់លោក ៗបាននិយាយអំពីថាធ្វើការជាមួយគាត់។ បានន័យថា លោកមានវត្តមាននៅពេលការ គាត់រៀបការនៅក្នុងឆ្នាំ១៩៧៥។ តើលោកបានចូលរួមក្នុងការរៀបការរបស់ តាវ៉ាល់ ក្នុងឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានចូលរួមនៅក្នុងរៀបការរបស់គាត់ទេ ពួកគ្នាខ្ញុំប្រាប់ថា តាវ៉ាល់ គាត់ទៅការប្រពន្ធនៅស្វាយយើងនេះ។ ដល់ពេលស្អែកឡើងបានខ្ញុំឃើញប្រពន្ធគាត់មកទាំងគាត់ គេហៅចាប់ដៃគ្នា។

**ស៖** តើលោកអាចជម្រាបតុលាការបានដូចម្ដេចខ្លះ ថាតើ តាវ៉ាល់ ហ្នឹងគាត់ជាមនុស្សលក្ខណៈបែបណា? ថាតើគាត់មានស្រុកកំណើតមកពីណា? តើឈ្មោះជាផ្លូវការ ឈ្មោះនាមត្រកូលគាត់ពេញឈ្មោះអ្វី?

[១៤:១៨:៥០]

**ឆ៖** ខ្ញុំអត់ដឹងៗថា ជា -- នាមត្រកូលគាត់ឈ្មោះអីទេ ដឹងតែគាត់នៅស្រុកឯកើតៗ មិនដឹងថាស្រុកឯកើតនៅដល់ណាទេ។

**ស៖** ចំពោះយើងខ្ញុំដែលមិនស្គាល់ទីតាំងតំបន់នោះ តើលោកអាចប្រាប់នៅក្នុងស្រុកណា? នៅក្នុងខេត្តណាបានដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងថាគាត់នៅខេត្តណា ស្រុកណាទេ។ ឮតែសម្ដីគាត់និយាយរាងអ៊ីចឹងៗ។

**ស៖** តើលោកអាចជម្រាបតុលាការបានទេនៅកាលណោះ តើ តាវ៉ាល់ គាត់មានអាយុប្រហែលប៉ុន្មានដែរនៅក្នុងរបបខ្មែរក្រហមនៅពេលដែលលោកស្គាល់គាត់កាលនោះ?

**ឆ៖** លោក តាវ៉ាល់ ពេលនោះគាត់អាយុប្រហែល ខ្ញុំប្រហែលស្មានទេ អាយុប្រហែល៥២-៥៣ ហ្នឹងឯង។

**ស៖** តើលោកបានជួប ឬក៏ឃើញ តាវ៉ាល់ គាត់ទៅមើលការដ្ឋានទំនប់ត្រពាំងថ្មដែរឬទេនៅពេលដែលលោកធ្វើការក្នុងឋានៈជាអ្នកយាមនៅទីនោះ?

**ឆ៖** ព្រោះខ្ញុំឃើញគាត់ ព្រឹកឡើង ឃើញគាត់មកមើលទំនប់ ហើយនិងមើលកងចល័តដែលៗ ធ្វើស្រែធ្វើអី។

**ស៖** តើគាត់មកញឹកញាប់ប៉ុនណា ដែលថាគាត់មកការដ្ឋានត្រពាំងថ្ម? តើគាត់មកជារៀងរាល់ថ្ងៃ ឬក៏មួយអាទិត្យប៉ុន្មានដង?

**ឆ៖** គាត់មកអាងត្រពាំងថ្ម គាត់មកៗមកពីរថ្ងៃម្តង ឬបីថ្ងៃម្តង។ ជួនកាលគាត់មកមួយថ្ងៃម្តងអត់ទៀងទាត់ទេ។

**ស៖** តើលោកដឹងថា កន្លែងគាត់ធ្វើការនៅកន្លែងណា? ជាកន្លែងដែលគាត់មុននឹងមកការដ្ឋានត្រពាំងថ្ម គាត់ចេញមកពីមន្ទីរ ឬក៏កន្លែងគាត់ធ្វើការពីណាមក?

**ឆ៖** កន្លែងគាត់ធ្វើការ រកអត់ -- ខ្ញុំអត់ដឹងកំណត់របស់គាត់ទេ ព្រោះគាត់បន្តិចគាត់ទៅមើលកន្លែងចល័តលើកដីនៅឯទំនប់រន្ទះបាញ់ បន្តិចមកមើលឯនេះ មិនដឹងថាគាត់សម្រាកឯណា ឯណីទេ។

**ស៖** តើលោកអាចប្រាប់តុលាការបានដូចម្តេច តើគាត់ជាមនុស្សមានបុគ្គលិកលក្ខណៈដូចម្តេចក្នុងឋានៈជាអ្នកត្រួតពិនិត្យ ឬក៏ជាអ្នកក្តោបក្តាប់ការដ្ឋានត្រពាំងថ្មហ្នឹង? អាចប្រាប់តុលាការបានទេអំពីបុគ្គលិកលក្ខណៈរបស់គាត់?

[១៤:២២:៣៨]

**ឆ៖** ជាលក្ខណៈរបស់គាត់ ដែលគាត់ក្តាប់រួមនោះ គឺគាត់ដឹកនាំៗគេរឹងប៉ឹង គាត់ធ្វើអ្វីមួយហើយ ឲ្យត្រូវតែកើតដូចគាត់។

**ស៖** តើលោកយល់ឃើញថា គាត់ជាមនុស្សម៉ឺងម៉ាត់ តឹងរ៉ឹង ឬយ៉ាងដូចម្តេច?

**ឆ៖** មនុស្ស តាវ៉ាល់ នេះគាត់ជាមនុស្សរឹងមាំ ជាមនុស្សម៉ឺងម៉ាត់ ហើយរឹងមាំណាស់។

**ស៖** តើកម្មករ ឬក៏ពលករនៅការដ្ឋានទំនប់នោះ មានការភ័យខ្លាចអ្វីពី តាវ៉ាល់ ដែរឬទេ?

**ឆ៖** ក្នុងកងចល័តដែលនៅធ្វើការនៅកន្លែងនោះ គឺឃើញ តាវ៉ាល់ មកគឺខ្លាចគ្រប់គ្នា ខំធ្វើការប្រឹង។

**ស៖** ដោយសារលោកជាអ្នកស្គាល់ តាវ៉ាល់ តាំងពីដំបូងមក តាំងពីគាត់នៅធ្វើជាយោធានៅតំបន់៥ តើលោកធ្លាប់មានឱកាសជជែកជាមួយគាត់ដែរឬទេ នៅពេលដែលលោកមកឃាមនៅត្រពាំងថ្មនោះ – អាងត្រពាំងថ្ម?

**ឆ៖** ខ្ញុំអត់ដែលមានពេលនិយាយជាមួយគាត់ទេ ប៉ុន្តែមុខគាត់ ខ្ញុំមិនហ៊ានមើលផង ខ្លាចគាត់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងទៅសំណួរមួយចំនួន អំពីការចាប់ខ្លួនពលករ នៅការដ្ឋានទំនប់ត្រពាំងថ្ម។ សូមលោកប្រាប់តុលាការជាបឋម ថាតើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការចាប់ខ្លួនពលករ ឬក៏អ្នកធ្វើការនៅការដ្ឋានត្រពាំងថ្មនោះ?

**ឆ៖** ការចាប់ខ្លួននៅក្នុងអាងត្រពាំងថ្មនោះ ជាខ្សែបណ្ដាញរបស់ៗតាវ៉ាល់ ជាកូនចៅរបស់គេ។

**ស៖** តើលោកអាចនិយាយឲ្យជាក់លាក់បន្តិចបានដែរឬទេ នៅពេលដែលលោកនិយាយថាអ្នកនៅក្រោមបង្គាប់របស់ តាវ៉ាល់ តើក្រុមអ្នកណា? ហើយអាចចាំឈ្មោះបានខ្លះដែរឬទេ?

**ឆ៖** ពេលនោះខ្ញុំក្ដាប់គេអត់ទេ ពេលឮថាកងនេះខុសអីចេះ កងនោះបាត់។ អាហ្នឹងជាការប្រធានវរៈចល័តរបស់គាត់ គេអ្នកកាត់ក្ដី ហើយគេអ្នកសម្លាប់គឺស៊ីសងលើពួកគេហ្នឹងឯង បានគេវាយការណ៍ឲ្យទៅៗកង តាវ៉ាល់។

[១៤:២៦:២៤]

**ស៖** តើលោកបានឮពាក្យនេះពីអ្នកណា?

**ឆ៖** ខ្ញុំឮពាក្យនេះមកពីកងចល័ត កូនចៅរបស់គេ។ យប់ឡើងវាបាត់មនុស្ស បានៗវាមកនិយាយលេងជាមួយខ្ញុំ ប្រាប់ខ្ញុំថា "យប់មិញបាត់ឈ្មោះឈយ មួយ មិនដឹងថានរណាចាប់យកទៅឯណា"។

**ស៖** ឥឡូវនេះត្រឡប់មកមនុស្សដែលនិយាយថា អ្នកដែលចាប់ខ្លួនមនុស្ស ដែលថាជាអ្នកក្រោមបង្គាប់របស់ តាវ៉ាល់ ហើយអ្នកទាំងនោះជាប្រធានកងវរសេនាតូច ហើយនិងកងអនុសេនាតូច និងឬក៏អាចនឹងជាក្រុមណាផ្សេងទៀតអ្នកដែលទទួលបន្ទុកក្នុងការចាប់នរណាម្នាក់ដែលគេធ្វើខុស ឬក៏ពលករនោះ?

**ឆ៖** ពេលនោះខ្ញុំក្ដាប់អត់បាន ពីព្រោះដែលបាត់មនុស្សក្នុងកងចល័តនោះ បាត់នៅក្នុង -- ជាមនុស្សរបស់ភូមិរបស់ខ្ញុំ។ បានអ្នកស្រុកខ្ញុំគេមកប្រាប់ខ្ញុំថា "យប់មិញបាត់ ឈយ មួយគេចាប់យកទៅបាត់" ហើយខ្ញុំក៏សួរថា "តើនរណាចាប់?" គេថា "ឃើញពួកប្រធានកងគេមកហ្នឹងនេះឯង"។ បានខ្ញុំថាប្រហែលជាពួកប្រធានៗវរៈ និងកងធំរបស់គេ គេចាប់យកទៅ។

[១៤:២៨:២៨]

**ស៖** អីចឹងគឺថា បុគ្គលម្នាក់ដែលលោកយោងទៅថាឈ្មោះ ឈយ ហ្នឹង តើគាត់ជា គាត់ក្នុងអង្គភាពភូមិឃុំ ឬក៏នៅក្នុងអង្គភាពយោធាណាមួយដែរ?

**ឆ៖** ព្រោះ ឈយ នោះជាកងចល័តស្រុក ជាកងចល័តភូមិ បានគេដកមកនៅកងចល័តតំបន់នោះ ព្រោះគាត់ៗមានជាប់ខ្សែបណ្ដាញទាហាន បានគេតាមដានគាត់ ចាប់គាត់យកទៅ។

**ស៖** តើលោកដឹងអំពីមូលហេតុនៃការចាប់ខ្លួនគាត់ហ្នឹងថា ដោយសារតែគាត់មានជាប់ខ្សែទាហានលន់ នល់ ហ្នឹងដូចម្ដេច លោកដឹងដោយរបៀបណាចំពោះ ឈយ នេះ?

**ឆ៖** ព្រោះ ឈយ នេះគាត់ធ្វើទាហានខ្លួនគាត់ គាត់ក្មេងអាយុប្រហែល២០ឆ្នាំ។ បានគាត់កុហកគេថាគាត់នៅក្មេងវត្ត ព្រោះគាត់ជាកូនកំព្រា។

**ស៖** ខ្ញុំចង់ឲ្យខ្ញុំយល់ឲ្យច្បាស់ ឈយ ជាអតីតទាហាន លន់ នល់ ប៉ុន្តែគាត់បានកុហកថាគាត់ជាក្មេងវត្ត។ តើលោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ ព្រោះគាត់អតីតគាត់ពីដើមមិញ គាត់នៅតែកូនសិស្សលោក។ ដល់ពេលដែលគេហាក់បញ្ចប់ហើយ ក៏បានគាត់ស្ម័គ្រធ្វើទាហាន គេក៏សន្តិភាពបណ្ដោយ។ បានគាត់ជាប់ឈ្មោះទាហានហ្នឹងគេ។

**ស៖** ខ្ញុំចង់សួរលោកសាក្សីអំពីក្រុមមនុស្សដ៏ជាក់លាក់ តើពលករ ឬកម្មករដែលព្យាយាមរត់គេចខ្លួនចេញពីការដ្ឋានត្រពាំងថ្ម ត្រូវគេចាប់ខ្លួនដែរឬទេ?

**ឆ៖** កងចល័តដែលយើងបានរស់នៅនៅក្នុងអាងត្រពាំងថ្មនោះ ឲ្យតែយើងរត់ចេញទៅ គេចាប់យើង បងប្អូនយើងរត់ទៅថៃ។

**ស៖** អ្នកណាជាអ្នកទៅចាប់ពលករ កម្មករដែលព្យាយាមរត់គេចខ្លួនហ្នឹង?

**ឆ៖** អានេះ ស៊ីសងគេរត់។ គេរត់ទៅមកចំខ្សែត្រៀមគេ គេចាប់ទៅ បើយើងរត់ទៅផុត ក៏ផុតទៅ មិនមានអ្នកណាចាប់បានទេ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសុំការអនុញ្ញាតបង្ហាញជូនសាក្សីមើលនូវចម្លើយពីរសំខាន់ៗ កំណត់ហេតុនៃការស្ដាប់ចម្លើយពីរសំខាន់ៗ។ ខ្ញុំចង់សួររំឭកការចងចាំរបស់ -- គឺឯកសារ E319/19.3.20 និងឯកសារ E3/9060 ជាឯកសារនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

សូមការអនុញ្ញាតបង្ហាញឯកសារទាំងពីរនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីរដ្ឋបាលតុលាការយកឯកសារពីព្រះរាជអាជ្ញា យកជូនសាក្សី។

[១៤:៣៣:២៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរលោកអំពីព័ត៌មានជាក់លាក់មួយចំនួនពាក់ព័ន្ធទៅនឹងការចាប់ខ្លួនកម្មករ ពលករដែលបានព្យាយាមរត់គេចខ្លួននៅក្នុងកិច្ចសម្ភាសន៍ទាំងពីរលើកនោះ។ ទី១ គឺឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/9060, ERNជាភាសាខ្មែរ 00733010, អង់គ្លេស 00728716, បារាំង 01123672។ អ្នកសម្ភាសបានសួរលោកសូមដកស្រង់ "សំណួរ៖ តើវាមានលក្ខណៈបែបណាដែរនៅពេលលោកទៅដល់ត្រពាំងថ្ម? ឆ្លើយ៖ នៅពេលខ្ញុំទៅដល់ការដ្ឋានលើកទំនប់ គឺមិនទាន់ចប់នៅឡើយទេ គឺថាមានកងចល័តជាច្រើន អ្នកខ្លះរត់មកផ្ទះ ហើយត្រូវបានសន្តិសុខចាប់ខ្លួន។ សន្តិសុខគឺថាគេបានបង្កើតជាកងកម្លាំងដើម្បីឈ្លបចាំចាប់ អ្នកដែលរត់គេចខ្លួន។" បញ្ចប់ការដកស្រង់។

លោកសាក្សី អ្វីដែលខ្ញុំចង់សួរលោកនៅពេលនេះគឺ សន្តិសុខភូមិដែលលោកបានលើកយកនិយាយពេលនេះ តើសន្តិសុខទាំងអស់នោះមកពីភូមិណា? ហើយអ្នកណាជាអ្នកបញ្ជាសន្តិសុខភូមិទាំងអស់នេះ?

**លោក ឡុត សួយ៖**

**ឆ៖** សន្តិសុខដែលកងចល័តយើងរត់ចូលទៅក្នុងភូមិ ឃុំនោះ គឺជាកងចល័តឈ្លបតាមភូមិដែលគេចាប់បានគេបញ្ជូនមកកន្លែងកងចល័តវិញ បើគេមិនបញ្ជូនមកទេ គេបញ្ជូនទៅកន្លែងឃុំ។ បើយើងនៅឃុំព្រះនេត្រព្រះ ក៏កងចល័តឈ្លបព្រះនេត្រព្រះគេចាប់ សូម្បីតែម៉ែឪយើង ក៏យើងជួយអត់រួចដែរ ត្រូវតែឈ្លបគេយកទៅ បញ្ជូនទៅដល់គេហៅកន្លែងមូលដ្ឋានរបស់គេនៅ។

[១៤:៣៥:៥៩]

**ស៖** បាទ នេះឯងខ្ញុំចង់ឲ្យលោកបញ្ជាក់ហ្នឹង គឺនៅពេលនិយាយអំពីសន្តិសុខភូមិ លោកនិយាយសំដៅទៅលើឈ្លបមូលដ្ឋាន។ អាចគេហៅថាឈ្លបមូលដ្ឋានបានដែរឬក៏យ៉ាងណា?

**ឆ៖** អាហ្នឹងគេហៅឈ្លបមូលដ្ឋាន ឈ្លបភូមិឃុំ។

**ស៖** លោកសាក្សី មានពេលខ្លះនោះកងរបស់លោកបានចុះទៅចាប់ខ្លួនមនុស្សដែលព្យាយាមរត់គេចខ្លួន។ ធ្លាប់ដែលធ្វើអ៊ីចឹង?

**ឆ៖** ព្រោះកងរបស់ខ្ញុំអត់ដែលបានចុះចាប់--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញារងអន្តរជាតិបញ្ជាក់អំពីឯកសារយោងដែលពាក់ព័ន្ធហ្នឹងផង ព្រោះកាលណាគាត់សួរដោយអត់បានបញ្ជាក់ពី ERN ទេ អ៊ីចឹងវាហាក់ដូចជាសំណួរនាំមុខហើយ។ ការលើកសួរនេះមិនដឹងថាសហព្រះរាជអាជ្ញាគាត់បានព័ត៌មានពីណាមកទេ។ សូមអរគុណ។

[១៤:៣៧:៣៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំបានសួរសំណួរបើកទៅកាន់សាក្សី ដោយយោងទៅលើចម្លើយរបស់គាត់នៅក្នុងកិច្ចសម្ភាសន៍ទាំងពីរជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តការតាំងសំណួរតទៅទៀត ឬក៏ថាដល់ម៉ោងឈប់សម្រាកហើយ សឹមបន្តសួរតទៅទៀត?

**ប្រធានអង្គជំនុំ៖**

ពេលនេះ ដល់ពេលសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីអញ្ជើញចូលមកវិញ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញឲ្យគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:៤៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមលោកព្រះរាជអាជ្ញាបន្តសំណួរ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យើងបានជជែកគ្នាអំពីការចាប់ខ្លួនមនុស្សដែលព្យាយាមរត់គេចខ្លួនពីការដ្ឋានទំនប់ត្រពាំងថ្ម។ ឥឡូវនេះ ខ្ញុំនឹងយោងទៅរកចម្លើយពីររបស់លោក ដែលលោកបានផ្តល់នៅក្នុងបទសម្ភាសន៍ៗការិយាល័យសហចៅក្រមស៊ើបអង្កេត ឯកសារ E319/19.3.20 នៅត្រង់ចម្លើយ៧៦ "សំណួរ៖ នៅពេលដែលលោកជាយោធា តើប្រធានរបស់លោកធ្លាប់ឲ្យបញ្ជីរបស់លោក ដែលបង្គាប់ឲ្យណែនាំឲ្យលោកចាប់ខ្លួននរណាម្នាក់នៅលើបញ្ជីនោះទេ? ចម្លើយ៖ ទេ ការងារហ្នឹងត្រូវបានធ្វើឡើងដោយឈ្លប កងខ្ញុំមិនដែលបានធ្វើទេ ប៉ុន្តែជួនកាលខ្ញុំបានទទួលបញ្ជាពីថ្នាក់លើ ដើម្បីចាប់ខ្លួនអ្នកណាម្នាក់ដែលៗរត់គេចខ្លួន។ ជួនកាល ខ្ញុំអាចចាប់គេបាន ប៉ុន្តែពេលខ្លះគេអាចរត់រួច។" ចប់សេចក្តីដកស្រង់។

[១៥:០០:២៥]

នៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាន -- នៅក្នុង E3/1960, ERN ខ្មែរ 00733024 -- ខ្មែរ ERN 733024, អង់គ្លេស 00728826, បារាំង-- "សំណួរ៖ ដូច្នេះ នៅក្នុងពេលដែលលោកនៅក្នុងកងទ័ព ដែលមានតួនាទីយាម ហើយនិងពិនិត្យទំនប់ តើលោកយាមអ្វីផ្សេងទៀតទេ? ចម្លើយ៖ គឺយាមអ្វីៗទាំងអស់ ប្រសិនបើគេទាក់ទងយើង ហើយយើងបានឃើញអ្នកណាម្នាក់រត់គេចខ្លួន យើងនឹងចាប់អ្នកទាំងនោះ ទោះបីក្រោយពីចាប់ខ្លួន យើងមិនអាចសម្លាប់គេទេ យើងអាចចាប់ខ្លួនពួកគេ ហើយបញ្ជូនទៅថ្នាក់លើ ដើម្បីឲ្យពួកគេដោះស្រាយ។" ចប់សេចក្តីដកស្រង់។

លោកសាក្សី តើលោកនឹកឃើញដែរឬទេ នៅពេលដែលការចាប់ខ្លួន មិនមែនជាមុខងារសំខាន់ទេ ប៉ុន្តែក្នុងកាលៈទេសៈខ្លះ លោក ហើយនិងកងរបស់លោកត្រូវបានគេចាត់តាំងឲ្យថា ចាប់ខ្លួនអ្នកណាម្នាក់ដែលរត់ចេញពីការដ្ឋាននោះផងដែរ?

**ឆ៖** បើដែលខ្ញុំដើរធ្វើការទៅ មានគេទាក់ទងឲ្យចាប់ ឬបងប្អូនដែលរត់ទៅចំពួកខ្ញុំ ក៏ខ្ញុំក៏ចាប់ទៅ ចាប់បានក៏បញ្ជូនទៅតាមកង តាមក្រុមរបស់គេវិញ ឲ្យមេកង មេក្រុមគេដោះស្រាយពីរឿងកូនចៅរបស់គេ។

**ស៖** នៅក្នុងចម្លើយដែលខ្ញុំបានអាននោះ លោកបានយោងទៅរកការទទួលបញ្ជាពីថ្នាក់លើដើម្បីចាប់ខ្លួនអ្នកណាម្នាក់ ដែលរត់គេចខ្លួន។ នៅពេលដែលលោកនិយាយថា "ថ្នាក់លើ" តើអ្នកណា តើ

បញ្ហានោះចេញមកពីអ្នកណាមុនមកដល់កងរបស់លោក អ្នកណាជាអ្នកផ្ដល់បទបញ្ជាហ្នឹងមក?

**ឆ៖** បទបញ្ជានេះ គឺមកពីៗ តាណាក គាត់បញ្ជា ប្រាប់ថាកងចល័តរត់ បានពួកខ្ញុំដើរធ្វើការតាមទំនប់ទៅ ចាប់បាន បានបញ្ជូនទៅឲ្យថ្នាក់លើគេដោះស្រាយវិញ។

**ស៖** និយាយដោយជាក់លាក់ នៅពេលដែលត្រូវកម្មករដែលចាប់បាន តើគេប្រគល់ទៅឲ្យអ្នកណា? ដែលគេនិយាយថាឲ្យទៅថ្នាក់លើ ឬក៏ឲ្យទៅមេនោះ ថាតើយើង -- ពេលដែលគេចាប់បាន គេប្រគល់ទៅឲ្យអ្នកណា?

**ឆ៖** គេប្រគល់ទៅឲ្យមេកងវរៈរបស់គេ កងចល័តរបស់គេ។

[១៥:០៤:១៥]

**ស៖** តើលោកបានដឹងដែរឬទេ លោកសាក្សី អំពីករណីណាដែលថា កម្មករត្រូវបាន ឬក៏ពលករត្រូវបានស្លាប់ ឬក៏គេសម្លាប់នៅការដ្ឋានត្រពាំងថ្មដែរឬទេ?

**ឆ៖** អត់ទេ កាប់សម្លាប់នៅក្នុងអាងត្រពាំងថ្មនេះ គឺខ្ញុំយល់អត់ដល់ ពីព្រោះអត់មានភារកិច្ចរបស់ពួកខ្ញុំ។ ពួកខ្ញុំ គឺទិសបញ្ញត្តិឲ្យយាមតែអាងត្រពាំងថ្ម។ បើបាក់ គឺមានតែពួកខ្ញុំស្លាប់ប៉ុណ្ណឹងឯង។

**ស៖** ខ្ញុំយល់លោកសាក្សី ប៉ុន្តែនិយាយដោយជាក់លាក់ តើលោកអាចជម្រាបតុលាការបានដែរឬទេ តើពលករនៅត្រពាំងថ្មនោះ អ្នកដែលនិយាយថា គេមិនអាចធ្វើការពេលយប់បានទេ ព្រោះពួកគេខ្វាក់មាន់។ តើអ្នកទាំងអស់នោះគេឲ្យធ្វើអី ឬក៏មានបញ្ហាអ្វីដែរ?

**ឆ៖** ប៉ុន្តែដែលខ្ញុំដឹង ដែលពួកចល័តដែលគ្នាវានិយាយ វាថាអ្នកដែលខ្វាក់មាន់នោះ អ្នកខ្លះអត់ខ្វាក់មាន់ទេ ធ្វើជាខ្វាក់មាន់។ ម្ល៉ោះហើយ បានមេចល័តគេៗដឹកដៃយកទៅទម្លាក់អន្លង់។ អ្នកណាដែលខ្វាក់មាន់មែនទែន អានុ៎ងគេយកមកវិញ។ អ្នកណាដែលមិនខ្វាក់មាន់ ធ្វើជាខ្វាក់មាន់ អានោះគេចាប់គេជំរុញឲ្យធ្លាក់គ្រហុកតែម្ដង។

**ស៖** ខ្ញុំយោងទៅរកកំណត់ហេតុស្ដាប់ចម្លើយសាក្សីរបស់លោក គឺថាE3/-- ឯកសារឌី.ស៊ី.ខេមទេបាទៗ E3/9060, ERN ជាភាសាខ្មែរ 00733020 រហូតទៅដល់ 021, អង់គ្លេស 00728724, បារាំង 01123679 រហូតទៅដល់ 3680។ ហើយខ្ញុំសូមដកស្រង់ចម្លើយរបស់លោកដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា "នៅពេលដែលអ្នកណាខ្វាក់មាន់ គេចោទថាអ្នកនោះគឺមានជំងឺសតិអារម្មណ៍ថាខ្វាក់មាន់ ហើយដោយនៅក្នុងកងតូច ហើយបើសិនជាសមាជិកនៅក្នុងកងនោះ ហើយគេយកអ្នកហ្នឹងទៅដាក់រណ្ដៅ។ ប្រសិនបើអ្នកទាំងអស់ហ្នឹងដើរគេចរណ្ដៅ គឺថាគេ ចាត់ទុកថាអ្នកហ្នឹង

មិនខ្វាក់មាន់ទេ ហើយបើសិនជាអ្នកណាធ្លាក់ទៅ គឺថាអាចនឹងធ្លាក់ស្លាប់"។

[១៥:០៧:៤០]

ហើយតទៅក្រោមទៀតនៅក្នុងទំព័រដដែល "ប្រសិនបើគេនាំអ្នកណាម្នាក់ទៅរណ្ដៅនោះ ហើយគេចពីរណ្ដៅនោះ គឺអ្នកហ្នឹងគេច គឺប្រធានកងរុញអ្នកហ្នឹងចូលទៅក្នុងរណ្ដៅ។ សំណួរ៖ តើលោកបានឃើញហេតុការណ៍ហ្នឹងទេ? ចម្លើយ ឆ្លើយ លោកឆ្លើយថា៖ ខ្ញុំបានឃើញ ពីព្រោះ គឺថាកងទ័ពមិនធ្វើការងារហ្នឹងទេ គឺពួកគេធ្វើការងារដោយខ្លួនគេ គឺការសម្លាប់មនុស្សបែបនេះ គឺធ្វើឡើងដោយកងវរសេនាធំ កងវរសេនាតូចរបស់ពលករនោះខ្លួនឯង"។ ចប់សេចក្ដីដកស្រង់។ លោកសាក្សី តើត្រឹមត្រូវដែរឬទេ ដែលថាលោកសាក្សីប្រាប់ទៅមជ្ឈមណ្ឌលឯកសារថាលោកបានឃើញហេតុការណ៍ដែលគេធ្វើបែបនេះនោះ?

**ឆ៖** ហេតុការណ៍នេះ គាត់ធ្វើគាត់ត្រឹមត្រូវរបស់គេ ព្រោះ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៥:០៨:៤៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ចំពោះការដកស្រង់របស់តំណាងសហព្រះរាជអាជ្ញារង។ ជាភាសាខ្មែរ នៅពេលចម្លើយរបស់សាក្សីនេះ គឺមិនបានបញ្ជាក់ថា ការធ្លាក់អន្លង់នេះ ធ្វើឱ្យស្លាប់ទេ គឺគ្រាន់តែថាធ្វើឱ្យធ្លាក់អន្លង់នៅពេលដែលអ្នកណាម្នាក់ មិនខ្វាក់មាន់ ឃើញអន្លង់នៅពីមុខ ហើយក៏ដើរគេច មានអ្នកផ្សេងទៀត ច្រានៗឱ្យធ្លាក់អន្លង់ មិនមែនថាច្រានដើម្បីសម្លាប់ទេ បាទ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

សូមអរគុណមេធាវី។ ខ្ញុំឃើញភាសាអង់គ្លេស ខ្ញុំមិនដឹងថាមានភាពខុសគ្នាពីអត្ថបទខ្មែរ និងអង់គ្លេសទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ៊ីចឹងលោកសាក្សី ខ្ញុំសួរលោកអំពីរណ្ដៅហ្នឹង។ តើរណ្ដៅហ្នឹងនៅកន្លែងណា នៅជិតការដ្ឋាន? តើជម្រៅរណ្ដៅនោះ ប្រហែលប៉ុន្មាន ជម្រៅប៉ុន្មានម៉ែត្រ?

**លោក ឡូត សួយ៖**

**ឆ៖** រណ្ដៅនោះវាមិនជាឆ្ងាយកន្លែងដែលយើងលើកដីហ្នឹងឯង ជម្រៅប្រហែល១ម៉ែត្រ ហើយប្រធានកងគេដាក់ទៅ បើអ្នកណាវា គេហៅ--

[១៥:១០:00]

**ស៖** ហើយចម្លើយរបស់លោកនៅចំណុចនេះចង្អុលបង្ហាញថា ប្រសិនបើអ្នកណាដើរគេចរណ្ដៅនោះ ហើយគឺមានអ្នកកងគេហ្នឹងគេរុញទម្លាក់ចូលរណ្ដៅនោះ។ តើត្រឹមត្រូវទេ លោកបានឃើញបែបនោះ បានឃើញហេតុការណ៍នោះ?

**ឆ៖** បាទ ខ្ញុំបានឃើញ បើអ្នកណាដែលគេៗថា គេហៅថា សតិអារម្មណ៍ បើអ្នកណាដែលជំងឺសតិអារម្មណ៍នោះគេដឹកទៅទម្លាក់គ្រហុកនោះ – គ្រហុកនោះជម្រៅប្រហែល១ម៉ែត្រ បើធ្លាក់ទៅវាគ្រេចកជើង។ ម្ល៉ោះហើយគេដឹងថាមនុស្សនេះ គេថាគេចកម្លាំងពលកម្ម។ បើអ្នកណាដែលគ្នាខ្វាក់មាន់មែន ដឹកទៅធ្លាក់អន្លង់ អានោះគេថាខ្វាក់មាន់មែន គេឲ្យសម្រាក។ បានគេមនុស្សមកអប់រំអ្នកណាដែលកុហកគេហ្នឹង។ គឺធ្លាក់នោះអត់បានដល់ងាប់ទេ។

**ស៖** *(គ្មានការបកប្រែ)*

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ធ្វើសេចក្ដីសង្កេតមួយ បន្ទាប់ពីសេចក្ដីសង្កេត ឬការជំទាស់ពីសហមេធាវីរបស់លោក ខៀវ សំផន។ ប្រសិនបើ តាមពិតនៅក្នុងអត្ថបទភាសាអង់គ្លេសខ្ញុំយល់ស្រប ជាមួយសហព្រះរាជអាជ្ញា គឺថារណ្ដៅទាំងអស់នោះអាចនឹងនាំឲ្យស្លាប់ បើធ្លាក់ចុះទៅ។ បើសិនជាអត្ថបទភាសាដើមខ្មែរអត់មានទេ គឺថាអាចនឹងមានបញ្ហា។ ដូច្នេះ ខ្ញុំចាប់អារម្មណ៍និងពិនិត្យមើលដោយសារភស្តុតាងនេះត្រូវផ្ដល់ឲ្យសាក្សី គឺថាគឺរណ្ដៅជម្រៅតែ១ម៉ែត្រទេ។ នេះហើយជាចំណុចខុសគ្នាដែលយើងចង់ឲ្យមានភាពច្បាស់លាស់នៅពេលនិយាយពីអត្ថបទបកប្រែទៅជាភាសាអង់គ្លេស។ អ៊ីចឹងយើងត្រូវពិនិត្យមើលថា តើភាសាខ្មែរនិយាយដូចម្ដេច? តើនៅក្នុងអត្ថបទភាសាខ្មែរនិយាយថារណ្ដៅនោះជម្រៅ បើសិនជាធ្លាក់អាចស្លាប់ហ្នឹងដូចអង់គ្លេសដែរឬទេ?

**លោក ឌេល លីសាក់៖**

ភាគីគឺអាចនឹងពិនិត្យមើលភាសាខ្មែរ។ ហើយនៅទីនេះ ខ្ញុំមិនអាចធ្វើបែបនោះទេ ឥឡូវខ្ញុំមើលអត្ថបទដែលខ្ញុំ ជាភាសាអង់គ្លេស ដើម្បីជាប្រយោជន៍នៃការសួររបស់ខ្ញុំនេះ។

[១៥:១២:៤៥]

**ប្រធានអង្គជំនុំ៖**

យល់ឃើញថាសាក្សីនៅចំពោះមុខហើយ សូមភាគីសួរទៅសាក្សីទៅ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយខ្ញុំនឹងសួរបញ្ជាក់អំពីសាក្សី ប៉ុន្តែបើសិនជានៅក្នុងប្រតិចារឹត យើងនឹងពិនិត្យមើលដោយផ្ទៀងផ្ទាត់ទៅលើឯកសារខ្មែរជាច្បាប់ដើម។ អ៊ីចឹងលោកសាក្សី ខ្ញុំចង់ឲ្យប្រាកដត្រង់ចំណុចនេះ។ ចំពោះមនុស្សដែលដើរគេចរណ្ដៅ ហើយគេរុញទម្លាក់ចូលថា តើមាននរណាស្លាប់ដោយសារគេរុញទម្លាក់ចូលទេ តាមអ្វីដែលលោកដឹងនោះ?

**លោក ឡុត សួយ៖**

**ឆ៖** តាមដែលខ្ញុំដឹងមិនដែលឃើញស្លាប់ទេ ប៉ុន្តែគេចង់ដឹងថាមនុស្សដែលគេចវេសពីការលើកទំនប់នេះ អ្នកខ្លះដល់នឿយទៅកុហកគេថា ឈឺងងឹតមាន់ ម៉្លោះហើយធ្វើជាងងឹតមាន់ បានគេដឹកទៅៗតម្រង់ទៅរណ្ដៅដែលជីកវែកសព្វថ្ងៃនេះ។ បើងងឹតមាន់មែនដើរទៅធ្លាក់អន្លង់ អានោះគេឲ្យយើងសម្រាក បើអ្នកណាដើរទៅដើរឃើញអន្លង់ហើយដើរគេច គេថាយើងសតិអារម្មណ៍។ បានន័យថាមនុស្សនោះអត់មានងងឹតមាន់ទេ។ បានគេ ប្រធានគេកសាងយើង អប់រំយើងតែម្ដង ពីរដង បីដងមិនបានគេក៏សម្លាប់យើងចោល បើយើងកុហកគេទៀត។

**ស៖** ឥឡូវនេះយើងនឹងចាប់ផ្ដើមដំបូងគឺថា អំពីអ្នកដែលមានជំងឺខ្វាក់មាន់មែន ហើយគេឲ្យដើរសាកចុះរណ្ដៅ ហើយអ្នកណាដែលធ្លាក់ក្នុងរណ្ដៅហ្នឹង ថាតើមានអ្នកណាធ្លាក់ហើយរបួសក្នុងលក្ខណៈណាទេ អ្វីដែលលោកបានឃើញកាលណោះនោះ?

**ឆ៖** បើអ្នកដែលខ្វាក់មាន់មែន ឃើញរណ្ដៅដើរចុះ ឈានជើងនឹងចុះ បានគេមេគេពីក្រោយគេចាប់ទាញមកវិញ។ បានន័យថាមនុស្សនោះងងឹតមាន់មែន អ្នកដែលមិនមែន ដល់ឃើញដល់ពេលមេគេដើរតម្រង់អន្លង់នោះ ដល់គេដល់ឈានដល់មាត់អន្លង់វាដើរគេចចេញ គឺបានន័យថាមនុស្សនោះកុហកគេ អត់មានងងឹតមាន់ទេ។ គេដកពិសោធយើងថាយើងកុហកគេ អានេះគេយកមកកសាងអប់រំយើងថ្ងៃមុខ ថ្ងៃក្រោយកុំកុហកគេ។

[១៥:១៥:៣៥]

**ស៖** ចំពោះមនុស្សដែលគេថាធ្វើពុតនោះ ហើយគេបញ្ជូនទៅឲ្យអប់រំ តើលោកដឹងថាក្រោយពី

គេបញ្ជូនទៅអប់រំហ្នឹង តើអ្នកហ្នឹងមានបញ្ហាអ្វីដែរឬទេ? ឬក៏លោកបានចូលរួមឬក៏បានដឹងអ្វីអំពីដំណើរការនៃការអប់រំអ្នកដែលធ្វើពុតហ្នឹងទេ?

**ឆ៖** រឿងការអប់រំអ្នកដែលកុហកគេហ្នឹង អាហ្នឹងជាភារកិច្ចរបស់កងចល័តរបស់គេ មេរបស់គេ តាមក្រុម តាមកងរបស់គេ គេទិតៀនឱ្យយើងកសាងខ្លួន បើយើងកែប្រែគំនិតកុំកុហកគេ។

**ស៖** ចុះអ្នកដែលគេបញ្ជូនទៅហើយមិនអាចកសាងខ្លួនបាន តើជួបហេតុការណ៍អ្វីដែរ?

**ឆ៖** បើយើងគេបញ្ជូនទៅហើយ យើងមិនកសាងខ្លួនមិនកែប្រែ ប្រធានកងគេអ្នកដោះស្រាយខ្លួនគេ។

**ស៖** តើប្រធានកងដោះស្រាយយ៉ាងដូចម្តេចចំពោះស្ថានភាពបែបនោះ?

**ឆ៖** ស្ថានភាពបែបនោះគេដោះស្រាយ មានតែគេវាយយើងចោលប៉ុណ្ណឹងឯង។

**ស៖** លោកសាក្សី តើលោកដឹងពីទីតាំងណានៅជិត ឬក៏នៅក្បែរការដ្ឋានត្រពាំងថ្ម ដែលគេយកមនុស្សទៅទីនោះដើម្បីសម្លាប់ចោលដែរឬទេ?

**ឆ៖** ក្នុងទីតាំងអាងត្រពាំងថ្មនេះ មិនដែលឃើញ ដែលមានទេ មិនដែលឮ។

[១៥:១៧:៥៥]

**ស៖** តើមានមន្ទីរសន្តិសុខដែរឬទេនៅភ្នំស្រុកនោះ?

**ឆ៖** ភ្នំស្រុកមានមន្ទីរសន្តិសុខរបស់ស្រុក។

**ស៖** តើមន្ទីរសន្តិសុខថ្នាក់តំបន់ដែរឬទេ? តើមន្ទីរសន្តិសុខនោះនៅកន្លែងណា?

**ឆ៖** មន្ទីរសន្តិសុខកន្លែងស្រុក គឺនៅកន្លែងសាលាស្រុកយើង សាលាស្រុកសព្វថ្ងៃនេះ។ គេដាក់ក្នុងផ្ទះថ្ម – ផ្ទះថ្មសាលាស្រុក។

**ស៖** ចង់សួរបំភ្លឺលោកសាក្សី ទីតាំងដែលលោកនិយាយនោះ ដែលថាផ្ទះថ្មហ្នឹងជា ដែលជាទីតាំងស្រុកមន្ទីរស្រុកបច្ចុប្បន្ននេះ ជាទីតាំងមន្ទីរសន្តិសុខស្រុកភ្នំស្រុក ឬក៏ជាមន្ទីរសន្តិសុខ នៅតំបន់៥ តើលោកអាចបំភ្លឺបានដែរឬទេ?

**ឆ៖** ទីតាំងដែលនៅស្រុកភ្នំស្រុកនេះ ជាទីតាំង ជាកន្លែងសន្តិសុខរបស់ស្រុក សន្តិសុខរបស់តំបន់៥ គឺនៅឯស្វាយ។

**ស៖** នៅពេលដែលលោកនិយាយថា “ស្វាយ” នោះ គឺលោកនិយាយថាស្វាយស៊ីសុផុន ជាទីក្រុងស្វាយស៊ីសុផុនហ្នឹង?

**ឆ៖** នៅហ្នឹងស្វាយស៊ីសុផុនយើងនេះឯង គេហៅសន្តិសុខតំបន់៥។

**ស៖** ខ្ញុំចង់ត្រឡប់ទៅសំណួរទូទៅអំពីលក្ខខណ្ឌ ឬក៏ជីវភាព លក្ខខណ្ឌការងារនៅត្រពាំងថ្ម ហើយយើងនិយាយអំពីពេលម៉ោងធ្វើការនៅការដ្ឋាននោះ។ តើលោកអាចជម្រាបតុលាការបានទេថាតើនៅពេលដែលលោកធ្វើការនៅត្រពាំងថ្មនោះ ពេលម៉ោងគេធ្វើការ កម្មករគេធ្វើការនោះចាប់ផ្តើមពីពេលណាទៅពេលណា ព្រឹកល្ងាចជាដើម?

**ឆ៖** កងចល័តដែលធ្វើការក្នុងអាងត្រពាំងថ្មនោះ គឺចាប់ពីម៉ោងប្រាំពីរព្រឹក ទៅទល់នឹងម៉ោងមួយដណ្តប់។ ចាប់ពីម៉ោងមួយដណ្តប់ -- ចាប់ពីម៉ោងមួយទល់ម៉ោងប្រាំ។ ចាប់ពីម៉ោងប្រាំមួយយប់ទៅទល់ម៉ោងដប់យប់។

[១៥:២១:៣៧]

**ស៖** ខ្ញុំសួរបំភ្លឺលោកនៅក្នុងបទសម្ភាសន៍ អូ.ស៊ី.អាយ.ជេ គឺ E319/19.3.20 លោកបាននិយាយត្រង់ចម្លើយ៨១ លោកបានបញ្ជាក់ថា ការងាររបស់លោកចាប់ផ្តើមពីម៉ោងប្រាំមួយ។ សូមលោកតាមការដែលចងចាំរបស់លោក និយាយពីការងាររបស់លោកផ្ទាល់ថាតើលោកចាប់ផ្តើមធ្វើការពីម៉ោងប៉ុន្មាននៅពេលព្រឹកនោះ?

**ឆ៖** ពួកខ្ញុំព្រឹកឡើង គឺដើរធ្វើការពីម៉ោងប្រាំទៅទល់ម៉ោងមួយដណ្តប់ ពីរដណ្តប់បានចូលមកកន្លែងហូបបាយវិញ។

**ស៖** ពាក់ព័ន្ធទៅនឹងការងារនៅពេលយប់ តើគេឲ្យពលករ ឬកម្មករធ្វើការពេលយប់ហ្នឹងញឹកញាប់ប៉ុនណា? ឲ្យធ្វើការរៀងរាល់យប់ ឬក៏យប់ខ្លះទេក្នុងសប្តាហ៍ជាដើម។

**ឆ៖** គឺធ្វើការជារៀងរាល់ថ្ងៃ ទាល់តែទំនប់នោះរួចបានគេឲ្យយើង ផ្លាស់កន្លែងយើង។

**ស៖** តើលោកអាចប្រាប់តុលាការបានដូចម្តេចអំពីរបបអាហារ ហើយនិងផែនការការងារដែលគេកំណត់ឲ្យធ្វើនៅការដ្ឋានទំនប់ត្រពាំងថ្មកាលនោះ?

**ឆ៖** ធ្វើការងារដែលលើកទំនប់នោះ គេឲ្យហូបមួយកំប៉ុងក្នុងមួយថ្ងៃ។

**ស៖** តើលោកដឹងដែរឬទេ ថាតើផែនការការងារដែលគេឲ្យធ្វើលើកដីនោះប៉ុន្មានក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃនោះ ម្នាក់ៗជាដើម?

**ឆ៖** គេ បើនិយាយរួមទៅគេអត់គិតពីរឿងក្នុងម្នាក់ទេ គេគិតក្នុងមួយកង។ មួយកងគេគិតឲ្យយើងកម្ពស់ដី វាកម្ពស់១៥ម៉ែត្រឡើងលើ ទទឹង១០ម៉ែត្រ។ គេឲ្យយើង ដាក់ឲ្យយើងរែក បើកាលណា

រែកបានលឿនទៅ យើងបានរបបស៊ីម្នាក់មួយកំប៉ុង បើកងណារែកមិនបានយូរទេអាហ្នឹងគេបន្ថយរបប យើងហូប។

[១៥:២៥:០០]

**ស៖** នៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានយោងទៅរកចំណុចមួយអ្វី ដែលលោកហៅថា កងពិសេសដែលទទួលផែនការខុសពីអ្នកដទៃ ហើយនិងរបបអាហារខុសពីអ្នកដទៃ ពីអ្នកកម្មករធម្មតា។ ថាតើលោកអាចពន្យល់បាន ថាតើកងពិសេសហ្នឹងមានលក្ខណៈយ៉ាងដូចម្តេច?

**ឆ៖** បានយូរបន្តិច បានគេរើសនារី យុវជន កងពិសេស។ កងពិសេសនោះ ក្នុង១ម៉ែត្រគូបគឺ គេរែកតែ ១០អម្រែកទេ អស់ដី។ បានគេឲ្យរបបស៊ីមួយថ្ងៃគេឲ្យហូបពីរកំប៉ុងក្នុងមួយថ្ងៃ កងពិសេស។ បើក្រៅពីកងពិសេស គេឲ្យហូបមួយកំប៉ុងក្នុងមួយថ្ងៃ។ ក្នុង១ម៉ែត្រគូបគឺរែកតែ១០បង្គីទេ ១០អម្រែក ទេ។

**ស៖** ខ្ញុំនឹងយកទៅរកបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា E3/9060, ខ្មែរ ERN 0073 3011 បាទ 00733011, អង់គ្លេស 00728716 រហូតដល់ 17, ហើយនិងបារាំង ERN 01123673។ ខ្ញុំសុំដកស្រង់៖ "សមាជិកកងពិសេស ត្រូវបានគេផ្តល់ឲ្យអង្ករពីរកំប៉ុងក្នុងមួយថ្ងៃ។ សមាជិកក្នុងកង ជើងទទេ ត្រូវបានគេផ្តល់អង្ករមួយកំប៉ុងក្នុងមួយថ្ងៃ ហើយកងពិសេសអាចបញ្ចប់១ម៉ែត្រគូបនៃដី១ម៉ែត្រ គូបក្នុងប្រាំបីជើង ស្ត្រីគឺអាចនឹងរត់នៅពេលដែលគេរែកបង្គី ហើយត្រឡប់ឡើង ត្រឡប់ចុះ ហើយពួកគេ សុទ្ធតែជាកងពិសេស"។ ខ្ញុំចង់យល់ឲ្យច្បាស់ថា តើកងពិសេសនេះ ទទួលបានរបបអាហារច្រើន ជាងគេ ហើយត្រូវធ្វើការច្រើន ឬក៏ខ្ញុំយល់ហ្នឹងត្រូវ ឬក៏មិនត្រឹមត្រូវ? បាទ សូមលោកបំភ្លឺថាតើ កងពិសសេសដែលទទួលផែនការការងារច្រើន ហើយក៏ទទួលរបបអាហារច្រើនជាងអ្នកធម្មតា កម្មករ ធម្មតាហ្នឹងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** កងពិសេសនេះគឺគេធ្វើការជឿនលឿន គឺគេបានរបបហូបច្រើន ច្រើនជាងកងថ្មើរជើង យើង ខោអាវអី សម្លៀកបំពាក់អីគឺគេបានល្អជាងកងថ្មើរជើង គឺគេត្រូវ គឺថាការងារគំរូរបស់យើង។

**ស៖** ហើយថាតើមានអ្នកធ្វើការនៅត្រពាំងថ្មប៉ុន្មាននាក់ដែរនៅក្នុងកងពិសេសនុ៎ង ដែលបាន ទទួលរបបអាហារច្រើនជាង ហើយត្រូវធ្វើការឲ្យបានច្រើនជាងនោះ?

**ឆ៖** ក្នុងកងពិសសេស គឺមានកម្លាំងរបស់គេ គឺចំនួនមួយវរៈរបស់គេ ពួកស្រីៗ ពួកនារី។

**ស៖** កងពិសេសនារីនេះ តើមាននារីទាំងអស់ប៉ុន្មាននាក់ដែរនៅក្នុងកងនេះ?

**ឆ៖** ក្នុងនារីក្នុងកងហ្នឹងមាននារីពីរកងធំ និងបុរសមួយកងធំ។ អានេះគេដាច់ខាតចូលកងពិសេស។

[១៥:៣០:២០]

**ស៖** ខ្ញុំសូមអានសម្រង់មួយទៀតឱ្យលោកស្ដាប់ ឲ្យឯកសារ E3/9060 ត្រង់ខ្មែរ ERN 00733030, អង់គ្លេស 00728730 និងបារាំង 01123684 ដល់ 85 សូមដកស្រង់៖ “កងពិសេសនេះគឺមានសមាជិកតែ១០០នាក់ទេ ក្រៅពីនេះគឺស្ថិតនៅក្នុងកងចល័តធម្មតា ដែលមានគ្នាទៅដល់រាប់ពាន់នាក់ឯណោះ។ សមាជិកកងពិសេសបួនទៅប្រាំនាក់នេះ គឺថាត្រូវរែកពី១ម៉ែត្រគូប ឯអ្នករាប់រយពាន់ទៀត គឺថាផ្ដល់អាហារតែមួយកំប៉ុងទេក្នុងមួយថ្ងៃសម្រាប់ម្នាក់”។ បញ្ចប់ការដកស្រង់។ តើការអានហើយហ្នឹងវាជួយរំឭកដល់ការចងចាំរបស់លោកថា កងពិសេសនេះគឺមានសមាជិកតែ១០០នាក់ទេ តើត្រឹមត្រូវអ៊ីចឹងដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ គឺកងពិសេសគឺពួកស្រីៗគេធ្វើកងពិសេស។ ហើយហូបរបបបានតែក្នុងម្នាក់មួយកំប៉ុង បើថ្មើរជើងម្នាក់កន្លះកំប៉ុងនៅក្នុងមួយថ្ងៃ។

**ស៖** តើប្រជាជនដែលធ្វើការនៅការដ្ឋាននៅទំនប់ត្រពាំងថ្មហ្នឹងបានទឹកមកពីណាហូប?

**ឆ៖** ទឹកអាងត្រពាំងថ្មនោះ គឺទឹកគេដឹកយកមកឲ្យផឹក ព្រោះឡានពួកកម្មករគេដឹក ហើយនិងបងប្អូនយើងក៏ដឹកផឹកទឹកតាមត្រពាំងខ្លះ។

**ស៖** លោកសាក្សី តើប្រជាជនធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មហ្នឹងធ្លាក់ខ្លួនឈឺញ៉ើកញ៉ាប់ដែរទេ? តើលោកកត់សម្គាល់ឃើញយ៉ាងម៉េចដែរចំពោះបញ្ហាសុខភាពរបស់កម្មករ ពលករនៅឯការដ្ឋាននោះ?

**ឆ៖** កម្មករដែលរស់នៅក្នុងអាងត្រពាំងថ្មនោះគឺសម្បូរដោយអ្នកជំងឺដែលគ្នាហូបមិនដិតដល់ទៅអ្នកខ្លះក៏ហូបផ្សិតពុលផ្សិតអីទៅ ហូបស្មៅហូបអីទៅ ច្រឡំថា ដើមហូបកើតក៏ស្លហូបក៏ពុល។ សម្បូរជំងឺច្រើន សម្បូរហើម។

**ស៖** ខ្ញុំសូមបង្ហាញនូវកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា E3/9060 ដដែលនេះ។ ERN ជាភាសាខ្មែរ 00733030-331, អង់គ្លេស 00728731, បារាំង 01123685។ សូមដកស្រង់ លោកសាក្សីនេះគឺជាអ្វីដែលលោកនិយាយឆ្លើយទៅប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ “គឺថាប្រជាជនមិនមានរបបអាហារគ្រប់គ្រាន់ទេ ខ្វះអនាម័យ បាក់កម្លាំង អ្នកខ្លះគឺថាក្បាលជង្គង់ហ្នឹងធំ

ៗជាងក្បាលរបស់ខ្លួនទៅទៀត"។ លោកសាក្សី តើនេះជាករណីដែលកើតមានឡើងនៅពេលដែលលោកនៅឯការដ្ឋានទំនប់ត្រពាំងថ្ម ហ្នឹងអ៊ីចឹងមែនឬ?

**ឆៈ** បាទ ដែលៗវាកើតឡើងនៅក្នុងដែលការគ្នាស្គមខ្លាំងនោះ ដោយសារអ្នកខ្លះដល់គេនៅកងពិសេសទៅខំរែកទៅ ដូចពួកនារីដែលខំរែកយកគុណសម្បត្តិទៅ ប្រឹងទៅដាច់សរសៃចន្លក ងាប់ក៏មានអ្នកខ្លះទៅក៏ កងថ្មើរជើងដែលគ្នាហូបមិនបានដិតដល់ទៅក៏ អ្នកខ្លះទៅក៏វាហើមស្គម។ អ្នកខ្លះទៅដើរអត់រួចក្បាលជង្គង់ធំជាងក្បាលទៀត។ សុំថ្នាំគេលេបៗ គេឲ្យតែថ្នាំអាចម៍ទន្សាយលេប ម៉េចនឹងបាត់។

[១៥:៣៥:០០]

**សៈ** សូមអរគុណលោកសាក្សី។ ខ្ញុំក៏ចង់សួរលោកអំពីអនាម័យនៅឯការដ្ឋាននោះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា កម្មករ ពលករទាំងអស់ហ្នឹង គាត់ទៅបត់ដៃ បត់ជើង ទៅជុះនៅឯណាទៅ ហើយមានបង្គន់ មានអីឲ្យប្រើប្រាស់ដែរ ឬក៏អត់ទេ?

**ឆៈ** ពេលនោះបានថ្នាក់លើគេធ្វើបង្គន់ឲ្យ គេវាយជាឡាំង តាមកងៗឲ្យយើងៗបត់ជើង បត់ដៃទៅ។ ប៉ុន្តែទន្ទឹមនឹងនោះអ្នកខ្លះគ្នាបត់ដៃ បត់ជើងមិនដល់បង្គន់ ពួយតែកៀនរោងហ្នឹងឯង។ បានមេរោគវាឆ្លងមួយទៅមួយ ឈឺ។

**សៈ** តើមានរុយ និងសត្វល្អិតច្រើនទេ នៅឯការដ្ឋាននោះ?

**ឆៈ** គឺកន្លែងនោះ គឺសម្បូររុយណាស់ សម្បូររុយ មូស។ យប់ឡើងយើងអត់មុង ក៏ដេកមូសហាលអី ណាមួយដេកមិនឆ្អែត ក្រោកធ្វើការពីយប់។

**សៈ** ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត នៅក្នុងពេលដែលយើងសេសសល់បន្តិចបន្តួចនេះ។ តើលោកនៅចងចាំអំឡុងពេលដែលកម្មាភិបាលមកពីភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន ហើយត្រូវបានដាក់ជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី។ តើលោកនៅចងចាំនូវចំណុចនេះទេ? ហើយតើមានអ្វីកើតឡើងចំពោះកម្មាភិបាលភូមិភាគពាយ័ព្យនៅពេលនោះ?

**ឆៈ** ពេលហ្នឹងដែលខ្ញុំនៅៗក្នុងអាងត្រពាំងថ្មនោះ បានឮពួកថ្នាក់លើគេនិយាយ ពួកតាណាកគាត់ប្រាប់ថាគេចាប់ភូមិភាគពាយ័ព្យ ចាប់ពួកភូមិភាគពាយ័ព្យទៅប្រជុំ ពួកភូមិភាគនិរតីចាប់។ គេចោទថាភូមិភាគពាយ័ព្យក្បត់។

[១៥:៣៩:១០]

**សៈ** នៅពេលដែលលោកនិយាយថា ថ្នាក់លើបានប្រាប់លោកថា ពួកគេនឹងចាប់ខ្លួនកម្មាភិបាល

ទាំងនោះ តើនរណាជាអ្នកនិយាយហ្នឹង? លោកចង់និយាយសំដៅទៅលើនរណាថាថ្នាក់លើហ្នឹង?

**ឆ៖** គឺលោកតាណាក ដែលគាត់ជាមេ គាត់ដឹងៗបានគាត់ប្រាប់តាមកូនចៅដែលនៅក្រោមនេះ ឲ្យការប្រុងប្រយ័ត្ន ប្រុងរត់។ បានរយៈកាលកន្លងមក បានពួកនិរតីគេចូលមកដល់ភូមិភាគពាយ័ព្យ ភ្លាម។

**សៈ** ហើយលោកបានឆ្លើយថា អ្នកដែលគេចាប់ខ្លួននោះ គឺត្រូវបានគេហៅទៅប្រជុំ ឬក៏ចូលទៅ ឲ្យទៅរៀនសូត្រ។ លោកអាចជម្រាបអង្គជំនុំជម្រះបានទេនៅពេលដែលអ្នកទាំងនេះត្រូវបានគេហៅឲ្យទៅរៀនសូត្រហ្នឹង អ្នកណាជាអ្នកមកហៅឲ្យទៅរៀនសូត្រ ហើយទៅរៀនសូត្រនៅឯណាដែរ?

**ឆ៖** ខ្ញុំដឹងអត់ -- ខ្ញុំអត់ដឹងទេ ឮតែគេថាហៅទៅរៀនៗ ទៅរៀនបាត់ខ្លួនៗ មិនដឹងថានរណាមកហៅ។ អានេះតាមខ្ញុំស្មាន គឺគេឲ្យនីរសារមកហៅ។

**សៈ** ខ្ញុំសូមអានសម្រង់ចេញពី -- លោកឆ្លើយមកមជ្ឈមណ្ឌលឯកសារ E319/19.3.20, អង់គ្លេស 00728742 ដល់ 743, បារាំង 01123695, សូមដកស្រង់ -- ខ្ញុំសូម ERN ជាភាសាខ្មែរឡើងវិញ 00733047។ បាទ នេះគឺជាអ្វីដែលលោកបានឆ្លើយលោកសាក្សី៖ "អ្នកមកពីភូមិភាគនិរតីនោះគឺថាគេមិនចាំបាច់ទាំងកាន់កាំភ្លើងផង គេគ្រាន់តែហៅយើងទៅនិយាយគ្នា ហើយគេហៅយើងទៅកាន់ផ្ទះថ្មមួយ ហើយចាប់ពួកយើងតែម្តង។ គេដាក់យើងចូលទៅក្នុងឡានធំ ហើយដឹកយើងទៅកន្លែងស្ងាត់ៗ។ នៅឯស្វាយស៊ីសុផុន គឺជាកន្លែងនគរបាល ឬកន្លែងសន្តិសុខរបស់លោក ឡុន"។ លោកសាក្សី ឡុន នេះជាអ្នកណា? ហើយតើគាត់មានមុខងារទទួលខុសត្រូវអ្វីដែរនៅក្នុងមន្ទីរសន្តិសុខមួយនេះនៅឯស្វាយស៊ីសុផុននោះ?

[១៥:៤២:៣៨]

**ឆ៖** ក្នុងសន្តិសុខស្វាយស៊ីសុផុន គឺសន្តិសុខតំបន់៥ នោះ គឺខ្ញុំឮតែឈ្មោះ តាហឿនៗ គេអ្នកក្តាប់សន្តិសុខ។

**សៈ** ខ្ញុំចង់សួរលោកអំពីកម្មាភិបាលភូមិភាគមួយចំនួនដែលលោកបានបញ្ជាក់អត្តសញ្ញាណពួកគាត់ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្វីដែលបានកើតឡើងទៅអ្នកទាំងនោះនៅក្នុងអំឡុងពេលនោះ។ ដំបូងលោកបានបង្ហាញអត្តសញ្ញាណបុគ្គលម្នាក់ឈ្មោះ តាហុង ហើយតើមានអ្វីកើតឡើងចំពោះ តាហុង នៅពេលដែលកម្មាភិបាលមកពីភូមិនិរតីនោះទៅដល់?

**ឆ៖** ដល់ភូមិភាគនិរតីនោះមកដល់ គឺហៅតាហ៊ីង្ស នេះទៅប្រជុំ ក៏ចាប់ តាហ៊ីង្ស។ ចាប់

តាហ៊ីង្ស ទៅបានថ្នាក់ក្រោមដឹងថា ភូមិភាគនិរតីចាប់ភូមិភាគពាយ័ព្យអស់។ បានគេប្រមូលចាប់អស់កម្មាភិបាល ជួរកម្មាភិបាលអស់មួយតំបន់៥នេះ។

**ស៖** តើ តាហ៊ីង្ស ហ្នឹងគាត់មានតួនាទីអ្វីដែរ?

**ឆ៖** គាត់ប្រធានតំបន់៥។

**ស៖** តើលោកស្គាល់កម្មាភិបាលម្នាក់ឈ្មោះ តាម៉ោង មកពីព្រៃព្រះនិព្វាននោះដែរទេ? ហើយតើមានអ្វីកើតឡើងចំពោះ តាម៉ោង នៅពេលកម្មាភិបាលនិរតីទៅដល់ តើមានអ្វីកើតឡើងចំពោះតាម៉ោង?

[១៥:៤៥:00]

**ឆ៖** ពេលដែលនិរតីចូលមកដល់ ក៏ហៅ តាម៉ោង គាត់មកប្រជុំ បានពេលនោះគេក៏ចាប់តាម៉ោងមុន។

**ស៖** ថ្ងៃនេះ យើងក៏បាននិយាយគ្នាខ្លះៗពីឈ្មោះ តាវ៉ាល់ ដែលជាប្រធានកងចល័តនៅតំបន់៥ គ្រប់គ្រងអ្នកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។ តើមានអ្វីកើតឡើងចំពោះ តាវ៉ាល់ ដែរនៅពេលដែលកម្មាភិបាលនិរតីទៅដល់?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានបញ្ហាខ្លះៗពាក់ព័ន្ធទៅនឹងការតាំងសំណួររបស់សហព្រះរាជអាជ្ញានៅពេលដែលកម្មាភិបាលនិរតីទៅដល់ ទាក់ទងទៅនឹងកម្មាភិបាលនៅពាយ័ព្យពីរនាក់ ហើយមានន័យថា គេចាប់ខ្លួននាក់ទាំងនេះគឺថាបីខែឬក៏បួនខែក្រោយមក ពេលដែលកម្មាភិបាលនិរតីទៅដល់ ហើយកម្មាភិបាលពាយ័ព្យត្រូវបានគេចាប់ខ្លួននៅរយៈពេលមួយឆ្នាំក្រោយមក។ ដូច្នេះ កាលណាយើងនិយាយអំពីរលកនៃការចាប់ខ្លួន ចរន្តនៃការចាប់ខ្លួននេះគឺថា គាត់សួរនេះមិនត្រឹមត្រូវទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន មេធាវីការពារក្តីមិនមែនជាអ្នកផ្តល់ភស្តុតាងទេ។ ខ្ញុំមានភស្តុតាងពីមន្ទីរសន្តិសុខស-២១ ហើយយើងមានកំណត់ត្រាសល់ពីមន្ទីរសន្តិសុខស-២១ផងដែរ។ ដូច្នេះ ការដែលខ្ញុំផ្តល់ឯកសារយោងនេះ ដើម្បីចង់រំឭកដល់ការចងចាំរបស់សាក្សីតែប៉ុណ្ណោះ ហើយនៅក្នុងពេលនេះ ខ្ញុំគ្រាន់តែសួរទៅសាក្សី ថាតើមានអ្វីកើតឡើងនៅពេលដែលកម្មាភិបាលភូមិភាគនិរតីទៅដល់ដើម្បីរំឭកទៅដល់ការចងចាំរបស់គាត់ ហើយខ្ញុំនឹងសួរថាតើព្រឹត្តការណ៍ទាំងឡាយនោះវាកើតឡើងនៅពេលណា។ ដូច្នេះ

ខ្ញុំគ្រាន់តែសួរថាមានអ្វីកើតឡើងចំពោះ តាវ៉ាល់ នៅពេលកម្មាភិបាលនិរតីទៅដល់? ដូច្នេះ អនុញ្ញាតឲ្យខ្ញុំបន្តសំណួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី តើមានអ្វីកើតឡើងចំពោះ តាវ៉ាល់?

**លោក ឡុត ស្លួយ៖**

**ឆ៖** តាវ៉ាល់ ដល់ពេលគេចាប់ -- តាម៉ោង ហៅ តាម៉ោង ទៅប្រជុំក៏បាត់។ ដល់ពេលនេះ គឺរយៈកាលបានប្រហែលបួនដប់ថ្ងៃ បានគេហៅពួក តាវ៉ាល់ ទៅចាប់ទៀត។ គេហៅទៅប្រជុំ។

**ស៖** ធ្វើម៉េចបានជាលោកដឹងថា តាវ៉ាល់ ត្រូវបានគេចាប់ខ្លួន?

[១៥:៤៨:២០]

**ឆ៖** ពីព្រោះគាត់ដឹងអំពី តាណាក ដែលគាត់រត់មកនៅជាមួយពួកខ្ញុំនៅឯអាងត្រពាំងថ្មឯណោះ បានគាត់ប្រាប់ថា កម្មាភិបាលភូមិភាគពាយ័ព្យគេចាប់អស់ហើយ នៅសល់តែគណៈស្រុកភ្នំស្រុកមួយទេមិនទាន់ចាប់។

**ស៖** មនុស្សចុងក្រោយដែលខ្ញុំចង់សួរលោកនោះគឺឈ្មោះ តាហាត់ ហើយតើមានអ្វីកើតឡើងចំពោះ តាហាត់ ដែរនៅពេលដែលកម្មាភិបាលនិរតីទៅដល់?

**ឆ៖** ពេលដែលនិរតីមកដល់គឺគេហៅ តាហាត់ ទៅប្រជុំនៅឯស្វាយ។

**ស៖** តើលោកនៅចាំខែឆ្នាំនៅពេល តាហឹង្ស តាវ៉ាល់ តាហាត់ ត្រូវបានគេចាប់ខ្លួនដែរទេ? ហើយនិងរួមទាំង តាម៉ោង ផងដែរ ទាំងបួននាក់ហ្នឹង លោកដឹងថាតើគេចាប់ខ្លួននៅក្នុងខែណាឆ្នាំណាដែរទេ?

**ឆ៖** ព្រោះខ្ញុំចាំដូចជាខែដែល ព្រោះដូចដើមឆ្នាំ ដល់ចុងឆ្នាំយើងសន្តិភាព។

**ស៖** បាទ ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកបន្តិច គឺថាមានឯកសារនៅសេសសល់ច្រើនដែរពាក់ព័ន្ធទៅនឹងបុគ្គលដែលខ្ញុំបានសួរអម្បាញ់មិញនេះ។ ទី១ គឺឯកសារ E3/1181ៗ ជារបាយ-ការណ៍មានចំណងជើងថា “ទស្សនៈទូទៅនៅតំបន់៥ ចុះថ្ងៃទី៧ មិថុនា ១៩៧៧” ហើយនៅក្នុងកំណត់ហេតុនេះគឺថា លេខាតំបន់៥ ហឹង្ស នេះត្រូវបានចាប់ខ្លួននៅខែមិថុនា ១៩៧៧។ យើងមានឯកសារ

E3/19100 គឺជាបញ្ជីឈ្មោះអ្នកទោសស-២១ ឈ្មោះថា "ឈ្មោះអ្នកទោសដែលត្រូវបានកម្ទេចនៅថ្ងៃទី៦ មីនា ១៩៧៨" លេខរៀងទី១២ នៅបញ្ជីនេះ។

[១៥:៥១:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

យើងទទួលបានព័ត៌មានគឺខុសគ្នា នៅពេល ម៉ែន ជឿន ហៅ ហឹង្ស នេះត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧។

**លោក ឌេល លីសាក់៖**

ដោយសារវាមានឯកសារច្រើន កាលបរិច្ឆេទរបស់ខ្ញុំខែមិថុនា ១៩៧៧ ហើយក៏មានចម្លើយសារភាពរបស់គាត់នៅស-២១ ដែរ មានកាលបរិច្ឆេទច្បាស់លាស់គឺខែមិថុនា ឆ្នាំ៧៧។ ប៉ុន្តែប្រសិនណាជាលោកមានឯកសារផ្សេង លោកមានសិទ្ធិសួរទៅកាន់សាក្សីរូបនេះនៅពេលដល់វេនដែលលោកត្រូវតាំងសំណួរ។ លោកប្រធាន តើខ្ញុំបន្តទៅមុខទៀតបានទេ?

**ប្រធានអង្គជំនុំ៖**

សូមលោកចៅក្រមមានសំណួរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ តើលោកអាចផ្តល់លេខយោងឯកសារដែលលោកបាននិយាយអម្បាញ់មិញនេះទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បើសិនជាលោកចៅក្រមអនុញ្ញាត គឺថាមិនអាចរកលេខនៅពេលនេះបានទេ ខ្ញុំអាចជូននៅស្អែកព្រឹក។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ ខ្ញុំសូមបន្តបន្ថែមទៅលើឯកសារពាក់ព័ន្ធទៅនឹងលេខាតំបន់៥ គឺឯកសារ E3/19100 ឈ្មោះ អ៊ុក ឱក, ហុន ហៅ វ៉ាល់ ត្រូវបានកំណត់ថាជាជំនួយការនៅតំបន់៥ ត្រូវបានចូលខ្លួនមកស-២១ នៅថ្ងៃទី២៩ មិថុនា ១៩៧៧។ ហើយពាក់ព័ន្ធទៅនឹងលេខាឈ្មោះ ម៉ោង នេះឯកសារ E3/342

ជាបញ្ជីឯកសារអ្នកទោសស-២១ ដែលត្រូវបានកែប្រែគឺលេខរៀងទី៥១ នៅលើបញ្ជីនេះថា "ម៉ោង បាន ចូលមកដល់ស-២១ នៅថ្ងៃទី២៨ មិថុនា ៧៧"។ ដូច្នេះយើងមានឯកសារបី ដែលឯកសារទាំងបីនេះគឺ មានកាលបរិច្ឆេទថ្ងៃទី២៧, ២៨, ២៩ មិថុនា ១៩៧៧។ លោកសាក្សី ខ្ញុំដឹងថារយៈពេលវាយូរយារ ណាស់មកហើយ ប៉ុន្តែតើវាជួយរំឭកដល់ការចងចាំរបស់លោកទេ ដែលថាអ្នកទាំងនេះត្រូវបានចាប់ខ្លួន នៅពាក់កណ្តាលឆ្នាំ១៩៧៧ អាចនៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ នេះតែម្តង?

[១៥:៥៤:៥២]

**លោក ឡូត ស្វយ៖**

**ឆ៖** ពេលកាលណោះគឺចាប់ខ្លួន គឺចាប់ខ្លួនបណ្តើរគ្នា គឺអង្កាល់ណោះខ្ញុំវានៅក្មេងដែរ ព្រោះខ្ញុំ ដឹងថាចាប់ខ្លួន ចាប់ពួក តាម៉ោងរួច ចាប់តាវ៉ាល់ៗរួច ចាប់តាហាត់ ចាប់នៅក្នុងឆ្នាំតែមួយគ្នាទាំងអស់។ បានគាត់ចាប់ពួក តាណាក តាអីមួយខ្សែគាត់ទាំងអស់។

**ស៖** លោកបាននិយាយអំពីអនុបញ្ញាការស្រុក ឈ្មោះតាណាក តើមានអ្វីកើតឡើងចំពោះ តាណាកនេះ – តាណាក។

**ឆ៖** គឺកើតឡើងចំពោះ តាណាកនេះ គឺចាប់តាហាត់រួច បានគេហៅតាណាកកងធំនេះឲ្យទៅ រៀន។ ឲ្យទៅរៀន គឺពួកខ្ញុំដែលជាកូនចៅខ្ញុំដឹងថា ខ្ញុំក៏ប្រាប់ថា "បងឯងទៅគេចាប់ហើយ" គាត់ថា "មិនដែលមែនទេ" ថា "មិនដែលមែន បងឯងទៅរៀនទៅ ចេះតែប្រជុំទៅ"។ ដល់ពេលទៅប្រជុំ គឺខ្ញុំចាំ មើលគាត់ហូបបាយ ចាំបាយបាត់ៗ ព្រឹកឡើងបានប្រពន្ធគាត់ថា ចាប់តាណាកបាត់ហើយ អ៊ីចេះ។

**ស៖** លោកសាក្សី តើមានពេលណាមួយ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាន សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យតំណាងសហព្រះរាជអាជ្ញា បញ្ជាក់ទៅលើឯកសារ មួយដែលស្តាប់តាមការបកប្រែគឺឯកសារ E3/19100 ហើយឯកសារនេះ ដូចជាពុំមាននៅក្នុងសំណុំ រឿងទេ អ៊ីចឹងសូមឲ្យសហព្រះរាជអាជ្ញាជួយបញ្ជាក់ពីភាពត្រឹមត្រូវនេះផងបាទ សូមអរគុណ។

[១៥:៥៧:១១]

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញាបញ្ជាក់លើឯកសារនេះ។

**លោក ឌេល លីសាក់៖**

បាទ ខ្ញុំគិតថាឯកសារដែលខ្ញុំលើកឡើងប្រាំនាទី គឺ ឯកសារ E3/1900ៗ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរបន្ទាប់របស់ខ្ញុំគឺសួរអំពីលោកផ្ទាល់ តើមានពេលណាមួយដែលកម្មាភិបាលភូមិភាគនិរតីព្យាយាមចាប់ខ្លួនលោកដែរទេ? ហើយបើសិនណាជាគេមានចង់ចាប់លោកមែន តើដោយសារមូលហេតុអ្វី?

**លោក ឡុត សួយ៖**

**ឆ៖** ពេលដែលគេចាប់ជួរកម្មាភិបាលអស់ ក៏ពួកខ្ញុំក៏បែកគ្នា ខ្ញុំក៏រត់ទៅលេងផ្ទះ បានពួកនិរតីគេចាប់ខ្ញុំ ៗក៏វាយនឹងគេ ក៏រត់បានចេញរត់រួច។

**ស៖** នៅពេលដែលគេចាប់ខ្លួនលោកហ្នឹង គេបញ្ជូនលោកទៅទីណា?

**ឆ៖** គេចាប់ខ្ញុំបាន គេបញ្ជូនខ្ញុំមកកន្លែងឃុំរបស់គេ ឃុំព្រះនេត្រព្រះ។

**ស៖** តើធ្វើម៉េចបានជាលោកអាចមានលទ្ធភាពអាចរត់គេចខ្លួនបាន?

**ឆ៖** ពេលនោះខ្ញុំក៏ប្រើក្បាច់គុណបុរាណខ្មែរ ក៏វាយជាមួយគេ១០នាក់ ខ្ញុំក៏បានវាយគេសន្លប់ ខ្ញុំក៏បានរត់ឡើងភ្នំ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំមុនឈប់សម្រាក។ ក្រោយពីការចាប់ខ្លួនមេរបស់លោក ណាក ហើយនិង ជុន តើមានអ្វីកើតឡើងទៅដល់កងយោធាទាំងនោះ ក្រោយពេលដែលមេរបស់លោកត្រូវបានគេចាប់ហើយ?

[១៦:០០:០០]

**ឆ៖** ពេលដែលគេចាប់មេខ្ញុំអស់ទៅ គេក៏ចោទពួកពាយ័ព្យថា សុទ្ធតែពួកក្បត់។ ផែនការពួកគេបម្រុងចាប់ខ្ញុំដឹកមកស្វាយ ពួកខ្ញុំក៏រត់ នាំគ្នារត់ចូលព្រៃ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំអាចបន្តសួរសំណួរតទៅទៀត ប្រសិនណាបើអនុញ្ញាត ប៉ុន្តែខ្ញុំឃើញដល់ម៉ោងហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកព្រះរាជអាជ្ញា ឥឡូវដល់ពេលវេលាសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកបន្តធ្វើនៅថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០១៥ ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឡុត សួយ ហើយនិងផ្តើមស្តាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-937 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ឡុត សួយ ដំណើរការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ឡុត សួយ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមអញ្ជើញឲ្យគាត់ និងមេធាវីប្រឹក្សាត្រឡប់មកចូលរួមក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មករួមសវនាការ ថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*